BIBLIOTHÈQUE NATIONALE DU CAMBODGE
P-K - 1
1967 - 5

~~R-213~~ A
R-216

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ទំព័រ

*ផ្នែកសាសនា*

១– បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ចាំង ប្រែ-រៀបរៀង (ត) . . . ៤៥៧

២– ព្រះពុទ្ធសាសនា និង ផ្លូវលោក ព្រះមហា អេង ខេមី រៀបរៀង . . . . . ៤៦៧

*ផ្នែកអក្សរសាស្ត្រ*

៣– ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន គីមសៀ រៀបរៀង (ត) . . . ៤៨៣

៤– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . . . ៤៩៣

៥– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឧ. ពាម ស្រាវជ្រាវ (ត) . . . . . . ៤៩៧

៦– ឯកសារ សាស្ត្រាស្ទឹករីតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . . ៥០៥

៧– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . . ៥១១

៨– ឯកសារកម្ពុជសុរិយា លោក ឧ.ពាម ប្រមូលរៀបរៀង (ត) . . . . . . ៥១៩

៩– ចិត្តមិនព្រមចាស់ លោក ញូង-សឿង រៀបរៀង . . . . . . . . . ៥២៥

១០– ជីវប្រវត្តិរបស់ខ្ញុំ ឈ្មោះ អៀង-សាយ (ត) . . . . . . . . . . . ៥៣០

ផ្នែកកំណាត់ និង ប្រវត្តិការណ៍

១១ – ពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ . . . . . . . . ៥៤០
– សុន្ទរកថា សហជីវិន គុយ-ពៅ អនុរដ្ឋលេខាធិការក្រសួងធម្មការ. . . . ៥៤២
១២ – ពិធីបុណ្យរំឭកថ្ងៃកំណើតវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ . . . . . ៥៤៩
១៣ – បុគ្គហ្នាយនៃពុទ្ធសាសនបណ្ឌិត្យ . . . . . . . . ៥៥៣

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០ ។

COMMISSION DES MOEURS & COUTUMES

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក, ឲ្យធ្វើល្អទៅ,
ឲ្យជុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។
ប.ព.

## បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(ក)

លោក សម-ថាំង ប្រែ - រៀបរៀង

ប្រ. *បើដូច្នេះ ផ្លែនៃព្រះពុទ្ធសាសនា មិនគឺសំដៅថា ផលទាំងអស់សុទ្ធតែកើតឡើងអំពីហេតុហើយឬ?*

វិ. *ពិតដូច្នោះមែន ផលទាំងឡាយតែងអាស្រ័យនូវហេតុជាបច្ចុប្បន្ន ឬអំពីអតីត ។*

ប្រ. *ឯពាក្យថា "ហេតុ" នោះ គេហៅថាអ្វីបានទៀត?*

វិ. *បើពោលសំដៅមនុស្សសត្វ គេហៅថាកម្ម ឬអំពើ គឺថា អំពើដែលយើងធ្វើហើយ អាចនាំមកនូវសេចក្ដីសុខ ឬទុក្ខទោស តាមដំណើរដែលយើងបានប្រព្រឹត្ត ។*

ប្រ. *មនុស្សប្រព្រឹត្តទុច្ចរិត អាចគេចចៀសរួចអំពីផលនៃកម្មរបស់ខ្លួនបានឬទេ? ។*

វិ. គម្ពីរធម្មបទសំដែងថា ទោះលើផែនដីក្ដី លើអាកាសក្ដី ក្នុងសមុទ្រក្ដី ក្នុងចន្លោះថ្មភ្នំក្ដី បុគ្គលទុច្ចរិត ពុំអាចនឹងជ្រកពួនដើម្បីចៀសឲ្យផុតអំពីផលនៃកម្មរបស់ខ្លួនបានឡើយ ។

បុ. មនុស្សសុចរិត ចៀសវាងមិនទទួលផលនៃកម្ម ដែលខ្លួនធ្វើហើយនោះបានឬទេ?

វិ. ដោយអំណាចផលកម្មជាកុសលដ៏ច្រើន បុគ្គលនោះ នឹងត្រូវបានទទួលការបរិបូរណ៌ដោយគតិ គឺទីកើតរូបកាយ, ពេលវេលា និងចំណេះវិជ្ជាទៅអនាគត ដែលជាហេតុអាចឲ្យចៀសចេញឆ្ងាយពីផលនៃកម្មជាអកុសល ហើយជាជំនួយដល់ការប្រព្រឹត្តិឲ្យបានរឹងរឹតតែប្រសើរខ្ពង់ខ្ពស់តទៅទៀតផង ។

បុ. មនុស្សបែបនេះ គេហៅថាដូចម្ដេច ?

វិ. គេហៅថា ជាអ្នកមានគតិសម្បត្តិ, ឧបធិសម្បត្តិ, កាលសម្បត្តិ និងអាយោគសម្បត្តិ ។

បុ. រឿងនេះ មានទំនងស្របគ្នានឹងការសិក្សា ខាងវិទ្យាសាស្ត្រសម័យនេះឬទេ ?

វិ. មានទំនងស្របគ្នាណាស់ មិនគួរសង្ស័យឡើយ ។

បុ. មនុស្សទាំងអស់ អាចនឹងត្រាស់ដឹងជាព្រះពុទ្ធបានឬទេ ?

វិ. ការត្រាស់ដឹង ពុំមែនមានពល់មនុស្ស ក្នុងកល្បតែមួយទេ

ព្រោះថា ដែលនឹងបានជាព្រះពុទ្ធមួយព្រះអង្គ ៗ នោះ ត្រូវកសាងបារមីជាយូរអង្វែងឆ្នាំណាស់ ហើយសត្វលោកទៀត ក៏ត្រូវការនឹងព្រះសាស្តាជួយប្រោះផង ទើបមានព្រះពុទ្ធមួយព្រះអង្គទ្រង់ចុះមកចាប់បដិសន្ធិ ដើម្បីនឹងពន្យល់ផ្លូវទៅកាន់ព្រះនិព្វាន ដែលមនុស្សក្នុងលោក ភ្លេចបោះបង់ចោលហើយនោះ ជាថ្មីម្តងទៀត ។

បុ. ច្បាប់ព្រះពុទ្ធសាសនាសំដែងថា មនុស្សនឹងកើតតែលើផែនដីនេះទេ ឬដូចម្តេច ?

វិ. តាមសភាវៈធម្មតា មនុស្សមិនមែនយកកំណើតតែលើផែនដីនេះទេ បុគ្គលទីមួយ ៗ អាចនឹងមានកំណើតខ្ពស់ឬទាប មានភាពល្អឬអាក្រក់លើសពីមនុស្សលោកនេះបានតាមកម្លាំងចិត្ត និងកុសលអកុសល ព្រោះភពដែលមនុស្សសត្វត្រូវយកបដិសន្ធិ និងទីតាំងនៃបដិសន្ធិ មានច្រើនជាអនេក ។ ឯគម្ពីរវិទ្យាសាស្ត្រក៏មានថ្លែងថា បដិសន្ធិរបស់សត្វរមែងស្របទៅតាមកម្លាំងទឹកចិត្ត ឬកម្លាំងកម្ម ដូចគ្នានឹងសេចក្តីពន្យល់ក្នុងច្បាប់ព្រះពុទ្ធសាសនាដែរ ។

បុ. មានភពដទៃទៀត ដែលវិសេស ឬដែលថោកទាបជាងផែនដីយើងនេះដែរឬ ?

វិ. ច្បាប់ព្រះពុទ្ធសាសនាពន្យល់ថា មានភពខ្ពស់ទាបល្អអាក្រក់ជាច្រើនបែប, ឯសេចក្តីចំរើនរបស់សត្វដែលស្ថិតនៅក្នុងភពនោះ ៗ ក៏

ប្រកបទៅតាមថ្នាក់តាមជាន់ខ្ពស់និងទាប តាមលំដាប់ សម្រាប់បុគ្គលទីមួយ ៗ

ប្រ. ព្រះពុទ្ធជាម្ចាស់ ទ្រង់មានបង្រួញសេចក្តីក្នុងផ្លូវនៃធម៌ និងវិន័យទាំងមូលមកជាគាថា ជាដូចម្តេចឬទេ ?

វិ. មាន ៗ

ប្រ. ចូរអ្នកពោលមកមើល ?

វិ. សព្វបាបស្ស អករណំ
កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ
ឯតំ ពុទ្ធានសាសនំ

(ប្រែជាសេចក្តីថា) កិរិយាមិនធ្វើអំពើបាប ការសន្សំបំពេញនូវកុសល និងការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះហើយជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ៗ

ប្រ. គាថា ៣ បាទខាងលើ មានអ្វីជាសេចក្តីប្លែកឬទេ ?

វិ. មាន, បាទទី១ រួមចូលក្នុងព្រះវិន័យបិដក, បាទទី២ រួមចូលក្នុងព្រះសូត្រ, បាទទី៣ រួមចូលក្នុងព្រះអភិធម្ម ៗ គាថានេះ មានពាក្យបាលីតែ៨ម៉ាត់ទេ តែហាក់ដូចជាដំណក់ទឹកសន្សើមដែលអាចឆ្លុះយកពន្លឺនៃពួកផ្កាយទាំងអស់បាន គឺអាចបញ្ចាំងរស្មីនៃព្រះពុទ្ធសាសនាទាំងមូល ៗ

ប្រ. សិក្ខាវិន័យទាំងនេះ បង្ហាញឲ្យដឹងថា ព្រះពុទ្ធសាសនា ជាពាក្យប្រដៅនាំឲ្យខ្ជិលច្រអូស ឬក៏ឲ្យខុសក្លាហាន?

ឆ្លើ. ត្រង់ " ហាមមិនឲ្យធ្វើបាប " ហាក់ដូចជានាំឲ្យខ្ជិល ក៏ប៉ុន្តែត្រង់ដែលថា ឲ្យសន្សំបំពេញកងការកុសល ហើយសំអាងចិត្តគំនិតឲ្យបរិសុទ្ធផូរផង់នេះ ត្រូវឲ្យមានកិរិយាប្រឹងប្រែងណាស់ ៗ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រដៅថា យើងមិនគប្បីពេញចិត្តនឹងភាវៈជាអ្នកគ្មានវត្ថុនោះទេ ក៏ប៉ុន្តែ ត្រូវកាន់កិរិយាល្អជាដរាប ៗ

ប្រ. ទីពឹងទីរឭកទាំង៣ប្រការ ដែលអ្នកកាន់ព្រះពុទ្ធសាសនាត្រូវប្រតិបត្តិនោះ គឺអ្វីខ្លះ?

ឆ្លើ. ទីពឹងទីរឭកទាំងនេះ ហៅថា " ត្រៃសរណៈ " គឺ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាម្ចាស់ ទុកដូចជាមគ្គនាយក, ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ បីដូចជាយាននាំផ្លូវ, ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃបីដូចមគ្គនាយក, រីហេតុទាំងបីប្រការនេះ ជាពុទ្ធធម៌ ៗ

ប្រ. បុគ្គល ដែលសូត្រស្វាធ្យាយពាក្យហេតុទាំងនេះ មានការសំគាល់ក្នុងចិត្តដូចម្តេច?

ឆ្លើ. គឺតាំងចិត្តថា យកព្រះពុទ្ធជាសាស្តាដ៏ត្រៃលែង ជាកល្យាណមិត្រ ជាគ្រូ ៗ យកព្រះធម៌ដូចជាក្រឹត្យដ៏ឧត្តមគ្មានវិបល្លាស, ជាផ្លូវនៃសុចរិតនិងយុត្តិធម៌ ជាផ្លូវដ៏វិសេស អាចនាំទៅកាន់សន្តិសុខដ៏ឧត្តម ក្នុ

សាកលលោកនេះ ៗ យកព្រះអរិយសង្ឃទាំងឡាយ ជាគ្រូអាចារ្យ ជាទិដ្ឋានុគតិ គួយ៉ាងដ៏ជាក់ស្តែង របស់ព្រះធម៌ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងទុកមក ។

បុ. ក្នុងពពួកព្រះភិក្ខុសង្ឃទាំងអម្បាលនេះ មានព្រះសង្ឃអង្គណាដែលទទ់តាបដោយបញ្ញានិងចិត្តឬទេ ?

វិ. មាន, តែព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា ដែលទឹងទុកជាសង្ឃសាវ័ករបស់ព្រះអង្គដូច្នេះ គឺភិក្ខុសង្ឃឯណាដែលបានព្យាយាម ប្រតិបត្តិនូវសីលសិក្ខា ធ្វើបញ្ញាឲ្យកើតឡើង ហើយបានសំរេច នូវអរិយមគ្គនិងអរិយផលទាំង៨ប្រការណាមួយ ។ ព្រះអង្គប្រកាសថា ព្រះសង្ឃដែលរាប់ចូលក្នុងត្រៃសរណៈនេះ គឺ "ព្រះអដ្ឋអរិយបុគ្គល" ក៏គឺសំដៅដល់បុគ្គលដែលបានដល់ហើយ នូវអរិយមគ្គអរិយផលទាំងប្រាំបីប្រការណាមួយ ៗ កិរិយាដែលគ្រាន់តែទ្រទ្រង់នូវត្រៃចីវរពណ៌ទឹកអម្ចត់ បានចូលបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនានេះ ពុំមែនជាការគួររៀនឲ្យស្គាល់បានថា ជាអ្នកអស់នូវកិលេសទាំងពួង ដល់នូវភាវៈជាអរហន្ត គួរជាទីគោរពឡើយ ។

បុ. បើដូច្នេះ ពុំមែនពួកភិក្ខុថោកទាបនោះទេឬ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនា ទទួលយកទៅជាទីពឹងជាមគ្គនាយកនោះ?

វិ. ពិតមែនណាស់ហើយ ។

ប្រ. សិក្ខាបទ៥យ៉ាង ហៅថា "បញ្ចសីល" ដែលគ្រហស្ថទាំងអស់គ្នាត្រូវសមាទាននោះ បានដល់អ្វីខ្លះ?

វិ. ត្រណម "សិក្ខាបទ" ទាំងនោះ មាននៅក្នុងពាក្យប្តេជ្ញាដែលពុទ្ធសាសនិកទាំងឡាយត្រូវសូត្រប្រកាសក្នុងព្រះវិហារ គឺ

១- ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺកិរិយាវៀរចាកការសម្លាប់សត្វមានជីវិត ។

២- ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺកិរិយាវៀរចាកការលួចយកទ្រព្យរបស់អ្នកដទៃ ។

៣- ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺកិរិយាវៀរចាកការខុសក្នុងកាមទាំងឡាយ គឺស្រីដែលគេហួងហែងរក្សា ។

៤- ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺកិរិយានិយាយពាក្យកុហក ។

៥- ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺកិរិយាមិនផឹកនូវទឹកស្រវឹង ( គឺសុរានិងមេរ័យ ) ។

ប្រ. មនុស្សប្រកបដោយបញ្ញា កាលមើលប្រទះសិក្ខាបទទាំងនេះហើយ តើទឹងកើតការឃើញដូចម្តេច?

វិ. ទឹងគិតឃើញថា បុគ្គលណាបានប្រព្រឹត្តកាន់តាមដោយហ្មត់ចត់ ទឹងអាចចៀសវាងទុក្ខទោសលំបាកក្នុងមនុស្សលោកនេះបាន ។

បើយើងពិចារណាតាមប្រវត្តិសាស្ត្រទៅ ក៏គង់ឃើញថា ទុក្ខលំបាកគ្រប់យ៉ាង កើតមកអំពីការប្រព្រឹត្តកន្លងនូវសិក្ខាបទខាងលើនេះ ណាមួយដោយពិត ។

ប្ញ. បណ្តាសិក្ខាបទទាំងនេះ តើសិក្ខាបទណាខ្លះដែលសឲ្យឃើញថាពុទ្ធបញ្ញត្តិ ជាត្រឹមត្រូវពិត?

វិ. គឺសិក្ខាបទទី១,ទី៣,ទី៥ ព្រោះកិរិយាធ្វើមនុស្សឃាតក្តី ការសេពកាមក្តី ទិញវត្ថុជាគ្រឿងស្រវឹងក្តី សឹងនាំមកនូវទុក្ខលំបាកដល់អ្នកប្រព្រឹត្តចំនួន ៩៥ ភាគរយនៃសេចក្តីទុក្ខរបស់មនុស្សលោក ។

ប្ញ. អ្នកដែលប្រព្រឹត្តកាន់ ធ្វើតាមសិក្ខាបទទាំងនេះ នឹងបានដល់ប្រយោជន៍អ្វីខ្លះ?

វិ. បានកុសលតិចច្រើនតាមកំឡាំង តាមលក្ខណៈនៃការប្រតិបត្តិតាមពេលវេលាដែលរក្សា និងតាមចំនួនសិក្ខាបទ គឺថាបើអ្នកណារក្សាតែសិក្ខាបទ ១ ហើយចោលសិក្ខាបទ ៤ ឯទៀតនោះ នឹងទទួលកុសលតែអំពីសិក្ខាបទដែលខ្លួនរក្សាប៉ុណ្ណោះ អ្នកដែលបានរក្សាខ្ជាប់ខ្ជួននូវសិក្ខាបទទាំង ៥ ។ ទៅអនាគតជាតិនឹងបានទៅកើតក្នុងកពន្លំខ្ពស់ត្រូវជាទីរកពយយ៉ាងក្រៃលែង ។

ប្ញ. សិក្ខាបទណាខ្លះទៀត ដែលគ្រហស្ថគួរគប្បីកាន់យកហើយប្រតិបត្តិតាមសេចក្តីស្ម័គ្រ?

វិ. គឺអដ្ឋសីលឬសីល ៨ ដែលមានសិក្ខាបទពាយដូចខាងលើ តែលុបពាក្យថា “ស្ត្រីដែលគេហួងហែងចេញ” គឺវៀរចាកការសេពមេថុនធម្មទៅ ហើយបន្ថែមសិក្ខាបទ ៣ ទៀត គឺ

- ខ្ញុំព្រះករុណា សូមសមាទានន្ទូវសិក្ខាបទ គឺវៀរចាកការមិនបរិភោគអាហារក្នុងពេលវិកាល ។

- ខ្ញុំព្រះករុណា សូមសមាទានន្ទូវសិក្ខាបទ គឺវៀរចាកការរាំច្រៀងដេញដំប្រគំតូរ្យតន្ត្រី ល្បែងរបាំនិងផ្កាកំរង គ្រឿងក្រអូបនិងគ្រឿងតាក់តែងកាយ ។

-ខ្ញុំព្រះករុណា សូមសមាទានន្ទូវសិក្ខាបទ គឺវៀរចាកការដេកអង្គុយលើទីសេនាសនៈខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។ បុគ្គលអ្នកវៀរចាកកាម ត្រូវចៀសកន្លែងដេកអង្គុយដែលនាំឲ្យសម្រេចក្នុងផ្លូវកាមគុណនេះ ។

ប្ញ. ពុទ្ធសាសនិកជនពន្យល់អំពីកុសលថាដូចម្តេច?

វិ. ថាគ្មានអំពើជាខាងក្រៅណាមួយ ដែលអាចនាំមកនូវកុសលបានទេ, កុសលទាំងអស់ សុទ្ធតែអាស្រ័យហេតុខាងក្នុងជីវិត ដែលនាំឲ្យធ្វើអំពើនោះឡើង ។

ប្ញ. ចូរអ្នកលើកឧទាហរណ៍មួយមកមើល?

វិ. អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ទុកជាបានចំណាយទ្រព្យអស់

ច្រើន សង់វិហារសាលា សាងព្រះពុទ្ធរូប ធ្វើពិធីបុណ្យ, ទំនុកបំរុងព្រះភិក្ខុសង្ឃ ឲ្យទានដល់ស្មូមយាចក, ដាំដើមឈើ ជីកស្រះ សង់សាលាសំណាក់តាមផ្លូវសម្រាប់អ្នកដំណើរក៏ដោយ បើអ្នកនោះធ្វើអំពើទាំងនេះដើម្បីយកមុខឲ្យគេអួតសរសើរ ឬ ដោយប្រការណាចំពោះតែរូបខ្លួនមួយ អ្នកនោះឈ្មោះថា បានផលតិចស្តួចស្តើងទេ ។ បើគ្រាន់តែធ្វើបន្តិចបន្តួចក៏ពិតមែន តែធ្វើដោយចិត្តសប្បុរស ដោយចិត្តសទ្ធា ធ្វើអំពើល្អដល់អ្នកដទៃ ទើបបានបុណ្យកុសលច្រើនជាងដោយពិត ។ អំពើល្អណាមួយដែលកើតដោយចិត្តទុច្ចរិត ដោយបំណងអាក្រក់ អាចនាំមកនូវប្រយោជន៍ដល់តែអ្នកដទៃប៉ុណ្ណោះ ពុំមែនជាប្រយោជន៍ដល់អ្នកដែលធ្វើនោះឡើយ ។

បុគ្គលដែលគ្រាន់តែទទួលអនុមោទនា ត្រេកអរចំពោះអំពើល្អរបស់អ្នកដទៃ គង់បានទទួលចំណែកកុសលដូចគ្នាដែរ ឲ្យតែមានសមានចិត្តពិតប្រាកដ ពុំមែនដោយធ្វើកលមាយាធ្វើអំពើលាមកវិញ ។

ប្ញ. អំពើកុសលណា ដែលលោកចាត់ថាមានផលច្រើនជាងអំពើកុសលទាំងពួង ?

វិ. ក្នុងគម្ពីរធម្មបទ លោកប្រាប់ថាការសំដែងធម៌ ប្រដៅចង្អុលបង្ហាញប្រាប់ច្បាស់ ប្រាប់ផ្លូវឲ្យអ្នកដទៃធ្វើល្អធ្វើត្រូវ មានផលច្រើនក្រៃលែងជាងការជាកុសលទាំងពួង ។

(នៅមានត)

# ព្រះពុទ្ធសាសនា និង ពិភពលោក

ព្រះមហា អេង.ខេមី

វត្តស្វាយពពៃ សង្កាត់លេខ ៦ ក្រុងភ្នំពេញ

រៀបរៀង

---

## សេចក្ដីផ្ដើម

កាលពីសម័យបុរាណជាយូរយារណាស់មកហើយ មានមនុស្សមួយពួកដែលចូលចិត្តប្រៀនប្រដៅគេឲ្យបដិបត្តិធម៌ ដោយយល់ថាជាការធ្វើខ្លួនឯងមិនឲ្យសូន្យតាកប្រយោជន៍ ក្នុងការដែលបានកើតមកជាមនុស្ស និងជាការជួយសង្គ្រោះមហាជនឲ្យបានសម្រេចប្រយោជន៍ដ៏ធំផង ៗ មនុស្សពួកនេះ យ៉ាងជាន់ខ្ពស់ស៊ូលះសេចក្ដីសុខផ្ទាល់ខ្លួន លះទ្រព្យសម្បត្តិសក្តិយសហើយចេញទៅទ្រទ្រង់ភេទជាអ្នកបួស ស្វែងរកផ្លូវបដិបត្តិដែលខ្លួនយល់ឃើញថា ត្រូវមានប្រយោជន៍ នាំយកមកទូន្មានដឹកនាំមហាជនឲ្យបដិបត្តិតាម ៗ

ក្នុងចំណោមមនុស្សពួកនេះ ព្រះបរមសាស្ដារបស់យើងក៏មួយព្រះអង្គនឹងគេដែរ ដែលពេញព្រះទ័យនឹងដឹកនាំគេឲ្យប្រព្រឹត្តធម៌ ដោយព្រះអង្គហ៊ានលះបង់គ្រប់បែបយ៉ាង ដើម្បីប្រយោជន៍ដល់មហាជន ៗ សេចក្ដីអស្ចារ្យរបស់ព្រះអង្គ ក្នុងការបំពេញប្រយោជន៍សាធារណៈ ដែលប្រជាពលលោកគួរកោតស្ញប់ស្ញែង និងគួរកត់សំគាល់នោះ មាន ៣ ប្រការគឺ

១- ការចេញទ្រង់ព្រះផ្នួស ព្រះអង្គជាមកុដរាជកុមារ ដែលត្រូវបានទទួលរាជសម្បត្តិតព្រះវង្សពីព្រះវររាជបិតា ហើយតាមទំនាយថ្វាយថា ត្រូវបានជាស្តេចចក្រពត្តិដ៏ធំសម្បើមថែមទៀតផង ។ តែព្រះអង្គបានទ្រង់លះបង់ចោលអស់ ហើយចេញទ្រង់ព្រះផ្នួស ដោយឥតមានព្រះទ័យនឹកអាល័យស្តាយក្រោយទាល់តែសោះ ។

២- ទុក្ករកិរិយា ក្នុងការស្វែងរកមោក្ខធម៌ ព្រះអង្គទ្រង់បានបដិបត្តិយ៉ាងតឹងរ៉ឹងបំផុត គឺទ្រង់អត់ព្រះក្រយាស្ងោយ រហូតដល់ព្រះកាយស្គាំងស្គមរៀបនឹងអស់ព្រះជន្ម តែព្រះអង្គមិនរលត់ទឹងព្រះជន្មដែរឡើយ ។

៣- ការប្រោសសត្វ ពេលដែលព្រះអង្គទ្រង់ត្រាស់ដឹងហើយ ព្រះអង្គមិនបានសម្ងំយកសុខតែមួយព្រះអង្គឯងប៉ុណ្ណោះ ទ្រង់ខំព្យាយាមសំដែងធម៌ទូន្មានប្រៀនប្រដៅសត្វ គ្មានសំរាកថ្ងៃណាមួយ រហូតទល់គ្នាទឹងថ្ងៃដែលទ្រង់បរិនិព្វាន ។

ក្នុងការប្រោសសត្វនេះសោត ព្រះអង្គបានទ្រង់សំដែងបញ្ជាក់ថា ជនណាបូជាតថាគតដោយអាមិសបូជា អ្នកនោះមិនឈ្មោះថាស្រឡាញ់តថាគតទេ ជនណាបូជាតថាគតដោយការបដិបត្តិតាមពាក្យប្រដៅរបស់តថាគត អ្នកនោះទើបឈ្មោះថាស្រឡាញ់តថាគត ។ ព្រះពុទ្ធដីកានេះ សឲ្យឃើញច្បាស់ថា ព្រះអង្គគ្មានប្រាថ្នាលាភសក្ការៈឬប្រយោជន៍ផ្ទាល់ព្រះអង្គទាល់តែសោះ ដែលប្លែកពីគណាចារ្យមេលទ្ធិដទៃ ៗ ក្នុងសម័យនោះ ។

ពាក្យប្រៀនប្រដៅដែលព្រះអង្គទ្រង់ខំសំដែងអស់រយៈពេល ៤៥ ឆ្នាំ គឺចាប់ពីពេលត្រាស់ដឹង រហូតដល់ពេលបរិនិព្វាននោះ ហៅថា ព្រះពុទ្ធសាសនា ។ ព្រះពុទ្ធសាសនាបានឋិតនៅក្នុងលោកនេះជាង ២៥០០ ឆ្នាំហើយ ។ មនុស្សជំនាន់ក្រោយខ្លះ ដែលបានសិក្សាវិជ្ជាការខាងផ្លូវលោកមកហើយ ច្រើនតែរិះគន់ថា ព្រះពុទ្ធសាសនា មានប្រយោជន៍សម្រាប់តែអ្នកបួស និងមនុស្សចាស់ ៗ ដែលកាន់ឈើច្រត់ហើយប៉ុណ្ណោះទេ គ្មានប្រយោជន៍អ្វីសម្រាប់ក្មេង ៗ និងមនុស្សអ្នកប្រកបការងារចិញ្ចឹមជីវិតទេ ។ តាមការពិត ព្រះពុទ្ធសាសនាមានប្រយោជន៍សម្រាប់មនុស្សគ្រប់ភេទគ្រប់វ័យ គ្រប់ជាន់ថ្នាក់ ។

គោលធម៌មួយខាងព្រះពុទ្ធសាសនា ដែលហៅថា ឥទ្ធិបាទធម៌ គឺជាវិធីការដែលមនុស្សប្រដិបត្តិតាមហើយ នឹងឲ្យសម្រេចប្រយោជន៍ដូចសេចក្តីប្រាថ្នា ហើយសម្រាប់មនុស្សគ្រប់គ្នា គ្មានរើសមុខឡើយ ។ ឥទ្ធិបាទធម៌នោះ មាន ៤ យ៉ាង គឺ

១– ឆន្ទៈ សេចក្តីពេញចិត្តក្នុងកិច្ចការដែលធ្វើ,

២- វីរិយៈ សេចក្តីប្រឹងប្រែងព្យាយាមធ្វើកិច្ចការនោះ,

៣– ចិត្តៈ ការយកចិត្តទុកដាក់ក្នុងកិច្ចការនោះ,

៤- វីមំសា ការពិនិត្យពិច័យកិច្ចការដែលធ្វើនោះ,

គប្បីសង្កេតមើលថា ក្មេង បើគ្មានឆន្ទៈ គឺសេចក្តីពេញចិត្តនឹងទៅ

រៀន តើក្មេងនោះទៅរៀនកើតឬទេ ? សូម្បីតែត្រូវមនុស្សចាស់បង្ខិតបង្ខំក៏ដោយចុះ បើក្មេងនោះមិនពេញចិត្តនឹងទៅទេ ក៏មិនអាចនឹងទៅបានឡើយ, យើងអាចឃើញបាន ដូចក្មេងដែលគេបរេះជាដើម ៗ អ្នកធ្វើការពេជការ អ្នកធ្វើស្រែចំការ បើគ្មានឆន្ទៈគឺសេចក្ដីពេញចិត្តក្នុងការងារនោះ តើនឹងទៅធ្វើកើតដែរឬទេ? ហើយបើមានតែឆន្ទៈពេញចិត្តនឹងធ្វើ តែខ្វះសេចក្ដីប្រឹងប្រែង, បើមានសេចក្ដីពេញចិត្តនិងការប្រឹងប្រែងហើយ តែខ្វះការយកចិត្តទុកដាក់ក្នុងកិច្ចការនោះ ឬបើមានគ្រប់ទាំង ៣ខាងដើមហើយ តែខ្វះខទី ៤ គឺពេញចិត្ត, ប្រឹងប្រែង និងយកចិត្តទុកដាក់ធ្វើហើយ តែមិនមានការត្រួតពិនិត្យមើល ធ្វើទៅដោយខ្ជីខ្ជា តើកិច្ចការនោះនឹងបានផលបរិបូណ៌ដែរឬទេ? តាមការពិត មិនបានផលឡើយ បើនឹងបានក៏បានបន្តិចបន្តួច មិនសមល្មមនឹងទំហំកិច្ចការ គឺសម្រេចផលតិចច្រើនទៅតាមលំដាប់អង្គនោះឯង បើខ្វះទាំង ៤ តែម្តងនោះ ក៏នឹងមិនបានសម្រេចផលអ្វីសោះតែម្ដង ៗ មនុស្សដែលធ្វើការអ្វីទៅហើយ មិនបានទទួលលទ្ធផលអ្វីសោះនោះ បើពិនិត្យស្រាវជ្រាវទៅហើយ នឹងឃើញបានថា ខ្វះគោលណាមួយ ក្នុងបណ្ដាគោលទាំង ៤ នោះ ឬក៏ខ្វះទាំងអស់តែម្ដង ៗ សេចក្ដីអធិប្បាយយ៉ាងខ្លីប៉ុណ្ណោះ បញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាមានប្រយោជន៍ដល់មនុស្សគ្រប់ភេទ វ័យ និងគ្រប់ជាន់ថ្នាក់ មិនមែនសម្រាប់តែមនុស្ស

ពួកណាគេទណាទេ ។ អ្នកខ្លះទៀតទិតៀនថា ព្រះពុទ្ធសាសនាធ្វើឲ្យមនុស្សខ្ជិល មិនទាន់សម័យ ចាញ់ផ្លូវលោកគេឆ្ងាយណាស់ អ្នកប្រាជ្ញខាងផ្លូវលោក គេបានរៀបចំឲ្យមានរបៀបបែបផែនក្បួនតម្រា ដែលមានផលប្រយោជន៍ដល់ជីវិតមនុស្ស តាមដែលមនុស្សត្រូវការ ជាចាំបាច់ ដូចរឿងសង្គមសាស្ត្រនិងសេដ្ឋកិច្ច ជាដើម ។ ឯព្រះពុទ្ធសាសនាគ្មានទូន្មានបង្ហាត់បង្រៀនអំពីវិជ្ជាទាំងនេះ ដែលជាប្រយោជន៍ដល់ជីវិតមនុស្ស ដូចគេសោះ ៗ អ្នកដែលទិតៀនបែបនេះ មិនមកពីអ្វីទេ គឺមកពីអ្នកនោះឯងសិក្សារឿងព្រះពុទ្ធសាសនាតិចពេក ។ តាមការពិត វិជ្ជាទាំងនោះ ខាងព្រះពុទ្ធសាសនាមានទាំងអស់ ហើយមានមុនផ្លូវលោកទៀតផង គឺព្រះពុទ្ធជាម្ចាស់ បានទ្រង់ត្រាស់សំដែងទុកមកជាង ២៥០០ ឆ្នាំហើយ ឯអ្នកប្រាជ្ញខាងផ្លូវលោក ទើបនឹងបង្កើតវិជ្ជាទាំងនោះឡើង នៅពេលក្រោយនេះទេ ។

ដើម្បីនឹងដោះស្រាយរឿងនេះ អ្នកសរសេរទើបនាំយកគោលធម៌ខាងព្រះពុទ្ធសាសនាខ្លះមកធ្វើអត្ថាធិប្បាយ ប្រៀបធៀបនឹងហេតុការណ៍ដែលកើតមានឡើងក្នុងលោក ដើម្បីឲ្យលោកអ្នកអានបានស្គាល់នូវតម្លៃនិងគុណប្រយោជន៍នៃព្រះពុទ្ធសាសនា ។ ហេតុនោះ ទើបឲ្យឈ្មោះរឿង ព្រះពុទ្ធសាសនា និង ផ្លូវលោក ៖ ដោយអធិប្បាយប្រៀបធៀបគ្នាជាលំដាប់ ៗ តទៅ ។

# អំពីសន្តិភាព

មនុស្សក្នុងលោកទាំងមូលនេះ មិនថាជាតិណា សាសន៍ណា ប្រុសឬស្រី ក្មេងចាស់ទេ សុទ្ធតែចង់បានសេចក្តីសុខ ស្អប់ខ្ពើមទុក្ខដូចគ្នាទាំងអស់ ។ តែតាំងពីបុរាណកាលមក ការស្វែងរកសេចក្តីសុខផ្លូវលោកច្រើនតែជាការបៀតបៀនគ្នា ដែលជាហេតុឲ្យកើតសេចក្តីទុក្ខក្តៅក្រហាយដល់គ្នានិងគ្នាទៅវិញ ។ ពលរដ្ឋនៃប្រទេសមួយលើកទ័ពទៅច្បាំងកាប់សម្លាប់ពលរដ្ឋក្នុងប្រទេសមួយទៀត ដោយសង្ឃឹមថា កាលបើបង្ក្រាបបានហើយ ខ្លួនក៏នឹងបានសេចក្តីសុខ ព្រោះនឹងមានអំណាចលើប្រទេសនោះគ្រប់បែបយ៉ាង ។ តែតាមការពិត ប្រទេសដែលចាញ់គេនោះ ខាងផ្លូវចិត្ត ឥតព្រមចុះចាញ់ទាល់តែសោះ តែដោយខ្លួនទន់ខ្សោយខាងផ្លូវកម្លាំង មិនអាចតស៊ូនឹងគេបាន ក៏ត្រូវតែអត់ទ្រាំទទួលបរាជ័យទៅសិន ដោយមានគំនិតគិតបង្កំនុំគុំគួនព្យាបាទ គិតរកឧបាយ ដើម្បីនឹងបំបាក់បំបបគូសត្រូវរបស់ខ្លួនយកជ័យជំនះមកវិញជានិច្ច ។ លុះពេលដែលមានកម្លាំងល្មមនឹងតស៊ូបាន អ្នកចាញ់នោះ ក៏លើកទ័ពទៅធ្វើសង្គ្រាមកាប់សម្លាប់យកជ័យជំនះពីអ្នកដែលបំបាក់បំបបខ្លួនពីកាលមុននោះ ជាហេតុឲ្យអ្នកដែលគិតថានឹងបានសុខស្រួលពីមុននោះ ត្រឡប់ទៅជាបានសេចក្តីទុក្ខក្តៅក្រហាយឡើងវិញ ។ ការស្វែងរកសេចក្តីសុខខាងផ្លូវលោកបែបនេះ មិនបានសេចក្តីសុខសមតាមប្រាថ្នាសោះ, ផ្ទុយទៅវិញ ត្រឡប់ជា

បានតែសេចក្តីទុក្ខក្តៅក្រហាយជានិច្ច ។ ទើបអ្នកដែលចង់ស្វែងរកសេចក្តីសុខសន្តិភាពខាងផ្លូវលោក ចេះតែខំព្យាយាមផ្លាស់ប្តូរមធ្យោបាយ ជាលំដាប់ ៗ មក ។ លុះមកដល់ពេលមុននឹងកើតសង្គ្រាមលោកលើកទី ១ ព្រះមហាក្សត្រនិកូឡាសទី ២ នៃប្រទេសរុស្ស៊ី ទ្រង់បានស្នើឲ្យមានការប្រជុំរវាងប្រជាជាតិនានាពិភាក្សាបញ្ហាបន្ថយសព្វាវុធ ដើម្បីចៀសវាងការធ្វើសង្គ្រាមកាប់សម្លាប់គ្នា ។ តែការស្នើរបស់ព្រះអង្គមិនបានសម្រេចផល ទើបនៅឆ្នាំ ១៩១៤ ក៏កើតសង្គ្រាមលោកលើកទី ១ ឡើង ។ លុះមកដល់ឆ្នាំ ១៩១៨ ពេលដែលសង្គ្រាមលោកលើកទី១ ស្ងប់ហើយ ប្រជាជាតិនានាបានរួបរួមគ្នាផ្តើមចាត់តាំងអង្គការមួយឡើង ហៅថា "សន្និបាតជាតិ" សម្រាប់ជាទីប្រជុំពិភាក្សាបញ្ហាផ្សេង ៗ រវាងប្រទេស ។ អង្គការនេះមានគោលបំណងធំបំផុត គឺដើម្បីរក្សាទុកនូវសុវត្ថិភាព និងសន្តិភាព នៃប្រជាពលរដ្ឋក្នុងប្រទេសនានា និងចូលដៃគ្នារវាងប្រទេស ដើម្បីជួយទំនុកបំរុងឲ្យសាកលលោកមានសេចក្តីចំរើនលូតលាស់ ដែលជាហេតុឲ្យកើតសេចក្តីសុខសន្តិភាព ។ តែអង្គការនេះសោត ក៏មិនអាចផ្តល់នូវសន្តិភាពដ៏បរិបូណ៌ដល់ប្រជាពលលោកបាន ទើបនៅឆ្នាំ ១៩៣៦ សង្គ្រាមលោកលើកទី ២ ក៏បានផ្ទុះឡើងទៀត ។ លុះសង្គ្រាមលោកលើកទី ២ នេះស្ងប់ចុះហើយ នៅឆ្នាំ ១៩៤៥ គឺ ចិន សហរដ្ឋអាមេរិក បារាំងសែស អង់គ្លេស និងរុស្ស៊ី ក៏បានប្រជុំព្រមព្រៀងគ្នាបង្កើតអង្គការមួយថ្មីទៀត

មានឈ្មោះថា អង្គការសហប្រជាជាតិ បានចាប់ផ្ដើមអនុវត្តកិច្ចការឡើងក្នុងឆ្នាំ ១៩៤៥ នោះឯង ។ គោលបំណងធំបំផុតនៃអង្គការនេះ គឺដើម្បីស្វែងរកសន្តិភាពឲ្យដល់សាកលលោក ដោយប្រើវិធីប្រជុំពិភាក្សាប្តូរយោបល់គ្នារវាងប្រជាជាតិទាំងអស់ក្នុងសាកលលោក សំដែងគោលបំណងរៀងៗខ្លួនចំពោះទីប្រជុំ និងជួយដោះស្រាយបញ្ហាផ្សេងៗដែលកើតទៅប្រទេសនោះៗ ដើម្បីការពារកុំឲ្យកើតសង្គ្រាមកាប់សម្លាប់គ្នាបាន ហើយនឹងបាត់ឲ្យមានផ្នែកសម្រាប់ជួយសង្គ្រោះប្រទេសនានា ដែលខ្វះខាតជាដើម ។ តាំងនេះ ដោយយល់ឃើញថា មនុស្សយើង តែងចង់បានសេចក្ដីសុខដូចៗគ្នាតាំងអស់ កាលបើចូលមករួមប្រជុំសំដែងយោបល់ ឲ្យមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក ហើយក៏មុខជានឹងមានសេចក្ដីមេត្តាករុណាអាណិតអាសូរគ្នានឹងគ្នា លែងបៀតបៀនគ្នា ដែលជាហេតុឲ្យកើតសេចក្ដីស្ងប់សុខឡើង ហេតុនោះ ទើបព្រមព្រៀងគ្នាបាត់តាំងអង្គការនេះឡើង ដោយមានទីស្នាក់ការធំនៅក្រុងញូវយ៉ក សហរដ្ឋអាមេរិក ហើយនឹងប្រទេសនានាក៏បានជួយឧបត្ថម្ភគាំទ្រ ជាហេតុឲ្យបានគង់វង់នៅរហូតមកដល់បច្ចុប្បន្នកាលនេះ ។ តែទុកជាយ៉ាងនេះ ក៏សាកលលោកនៅតែមិនបានសេចក្ដីស្ងប់សុខ សមតាមសេចក្ដីប្រាថ្នារបស់មនុស្សឡើយ, ការធ្វើសង្គ្រាមកាប់សម្លាប់គ្នា ការបៀតបៀនគ្នា ក៏នៅតែមាន មិនបានសាបសូន្យឡើយ ។ នេះឯងគឺជាវិធីស្វែងរកសេចក្ដីសុខសន្តិភាពខាងផ្លូវ

លោក ដែលមានដំណើរជាការចងពៀរ ទើបប្រជាពលលោកមិនបាន សេចក្ដីសុខសមតាមសេចក្ដីប្រាថ្នា ។

ខាងផ្លូវព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ប្រាប ច្បាស់ថា មនុស្សខ្លះទៅ ពេលដែលទឹងស្វែងរកសេចក្ដីសុខ ក៏គិតតែត្រឹម ខ្លួនឯងមួយប៉ុណ្ណោះ ត្រង់ការស្វែងរកសេចក្ដីសុខរបស់ខ្លួននោះប៉ះទង្គិច ទៅលើប្រយោជន៍អ្នកដទៃ ធ្វើឲ្យអ្នកដទៃកើតសេចក្ដីទុក្ខក្ដៅក្រហាយនោះ មិនបានគិតដល់សោះ ។ យើងអាចសង្កេតឃើញបានដូចអ្នកសម្លាប់សត្វ មានមាន់ទាជាដើម តែងតែគិតសប្បាយរីករាយក្នុងចិត្តថា នឹងបានឆ្ងាញ់ ពីសាដោយបានបរិភោគសាច់មាន់ទានោះ ត្រង់ដែលសត្វនោះបានទទួល សេចក្ដីទុក្ខភ័យស្ដាយជីវិតយ៉ាងណានោះ ខ្លួនគ្មានគិតពាល់តែសោះ ។ តែពេលដែលមានអ្នកណាមួយមានចិត្តក្លាហាន មិនចាំបាច់ដល់ទៅយក អាវុធមកកាប់សម្លាប់អ្នកដែលកាប់សម្លាប់សត្វ មានមាន់ជាដើមនោះឡើយ គ្រាន់តែយកដៃទៅទះតប់ ឬហៅអា-មឹងមួយម៉ាត់ប៉ុណ្ណោះ អ្នកនោះឯង រមែងប្រឡោតក្រោធខឹង កើតសេចក្ដីក្ដៅក្រហាយក្នុងចិត្ត ព្រោះប្រកាន់ ថាគេមើលងាយខ្លួន តែត្រង់ដែលខ្លួនយកសត្វមានជីវិត ស្រឡាញ់ជីវិត ទៅកាប់សម្លាប់ផ្ដាច់ជីវិតគេនោះ ខ្លួនគ្មានគិតដល់សេចក្ដីទុក្ខ របស់គេ សោះ ។ ម្យ៉ាងទៀត អ្នកដែលមានសេចក្ដីទុក្ខលំបាក ព្រោះការខ្វះអាហារ ទទួលទាន ខ្វះសំពត់ស្លៀកពាក់ ហើយមិនរិះស្វែងរកដោយផ្លូវសុចរិត បែរ

ជាទិលួចប្លន់ឆក់ដណ្ដើមទ្រព្យរបស់អ្នកដទៃ យកមកបំពេញសេចក្ដីខ្វះខាតរបស់ខ្លួន ឲ្យខ្លួនបានសុខ គ្រង់ដែលគេបានទុក្ខក្ដៅក្រហាយ ស្ដាយទ្រព្យសម្បត្តិព្រោះតែខ្លួនទៅលួចប្លន់នោះ ខ្លួនគ្មានគិតបន្តិចបន្តួចសោះ សំឡឹងយកសេចក្ដីសុខចំពោះតែខ្លួនឯងម្នាក់ប៉ុណ្ណោះ ។ ឯអ្នកម្ចាស់សោក ក៏មានការគុំគួន និងរកឱកាសព្យាបាទតបវិញដែរ ដែលជាហេតុនាំឲ្យមានការចងពៀរនឹងគ្នា បៀតបៀនគ្នាមិនចេះអស់មិនចេះហើយ ។ ព្រះពុទ្ធជាម្ចាស់ ទើបទ្រង់ត្រាស់សំដែងទុកថា " ពៀរមិនដែលស្ងប់ដោយការចងពៀរបានទេ " គឺថា បើនៅតែមានការចងចិត្តប្រទូសរ៉ាយគ្នាទៅវិញទៅមកនោះ មនុស្សមិនអាចនឹងស្រឡាញ់ សះស្រលគ្នាបានទេ, សត្វទាំងឡាយតែងតក់ស្លុតចំពោះអាជ្ញា គឺការបៀតបៀនពីអ្នកដទៃ, ជីវិត ជាទីស្រឡាញ់របស់សត្វទាំងពួង, មនុស្សត្រូវយកខ្លួនឯងជាគ្រឿងប្រៀបធៀបហើយកុំបៀតបៀន កុំសម្លាប់អ្នកដទៃ, " អ្នកណា ស្វែងរកសុខដល់ខ្លួនហើយបៀតបៀនសត្វដទៃ ដែលគេប្រាថ្នាសុខដែរនោះ អ្នកនោះ មិនបានជួបប្រទះនឹងសេចក្ដីសុខជាដាច់ខាត " ។ តាមន័យព្រះពុទ្ធភាសិតនេះឃើញថា មនុស្សយើងគ្រប់រូប ដែលស្រឡាញ់សុខ ត្រូវកុំបៀតបៀនគេព្រោះគេស្រឡាញ់សុខដូចយើងដែរ កាលបើយើងទៅបៀតបៀនគេ គេក៏ក្ដៅក្រហាយ ហើយនឹងបៀតបៀនយើងវិញ ជាហេតុឲ្យយើងមិនបានសុខដែរ ដែលជាការចងពៀររកទីបំផុតគ្មាន ។ កាលបើការចងពៀរ

ការបៀតបៀនគ្នា មានដំបន់ណា សេចក្ដីទុក្ខក្ដៅក្រហាយ ក៏មាននៅដំបន់នោះដែរ ទីងរកសេចក្ដីសុខស្ងប់ស្ងៀមមិនបានឡើយ លុះត្រាតែមនុស្សឈប់បៀតបៀនគ្នានោះ ទើបនឹងបានសេចក្ដីសុខសមតាមប្រាថ្នា សមនឹងព្រះពុទ្ធភាសិតមួយបទទៀតថា « ការមិនបៀតបៀនគ្នា ជាសុខក្នុងលោក » ។ ដោយអាស្រ័យហេតុនេះហើយ ទើបព្រះពុទ្ធជាម្ចាស់ដែលជាសាស្ដាឯកក្នុងលោក ព្រះអង្គទ្រង់ត្រាស់សំដែងនូវវិធីបំបាត់ការបង់ពៀរនឹងគ្នា ដើម្បីបំបាត់ការធ្វើសង្គ្រាម កាប់សម្លាប់គ្នានេះទុកមក ដោយទ្រង់សំដែងតាំងផ្លូវវិន័យ តាំងផ្លូវធម៌ ដែលហៅថា « សីលធម៌ » គឺសីល ៥ និងធម៌ ៥ ដូចតទៅនេះ :

## បញ្ចសីល

១ ទ្រង់ហាមមិនឲ្យសម្លាប់សត្វបំបាត់ជីវិតគេ តាំងអំពីសត្វជាន់ទាបរហូតដល់មនុស្ស ។

២– ទ្រង់ហាមមិនឲ្យលួចប្លន់ឆក់ដណ្ដើមទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ។

៣– ទ្រង់ហាមមិនឲ្យប្រព្រឹត្តខុសកាម គឺមិនឲ្យរំលោភលើប្រពៃណីគេ រំលោភលើបុត្រធីតាភរិយាគេ ។

៤– ទ្រង់ហាមមិនឲ្យនិយាយកុហកបញ្ឆោតអ្នកដទៃ ។

៥– ទ្រង់ហាមមិនឲ្យផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជា

ហេតុឲ្យកើតសេចក្ដីប្រមាទ ខូចសតិស្មារតី ហ៊ានធ្វើអំពើអាក្រក់ផ្សេងៗ ដោយឥតអៀនខ្មាស ។

## បញ្ចធម៌

១– ទ្រង់ប្រដៅឲ្យមានមេត្តា ករុណា អាណិតអាសូរដល់មនុស្សសត្វទូទៅ ។

២– ទ្រង់ប្រដៅឲ្យប្រកបការចិញ្ចឹមជីវិតតាមសម្មាជីវៈ គឺរកទទួលទានចិញ្ចឹមជីវិតដោយសុចរិតត្រឹមត្រូវ តាមគន្លងធម៌ ចៀសវាងការចិញ្ចឹមជីវិតដោយផ្លូវទុច្ចរិត ។

៣– ទ្រង់ប្រដៅឲ្យសង្រួមក្នុងកាម ឲ្យសន្ដោសត្រេកអរតែនឹងភរិយារបស់ខ្លួន ។

៤– ទ្រង់ទូន្មានឲ្យនិយាយតែសេចក្ដីពិត និយាយតែពាក្យផ្អែមល្ហែម មានផលមានប្រយោជន៍ ។

៥– ទ្រង់ប្រដៅឲ្យតាំងសតិសម្បជញ្ញៈ សង្រួមរាំងក្នុងអារម្មណ៍ផ្សេងៗ ជានិច្ច ។

សីល ៥ និង ធម៌ ៥ ដូចរៀបរាប់មកខាងលើនេះ គឺជាពុទ្ធវិធីវិសេសមួយសម្រាប់ឲ្យមនុស្សប្រតិបត្តិតាម ដើម្បីកុំឲ្យមានការចងពៀរនឹងគ្នា កុំឲ្យបៀតបៀនគ្នា ដោយឲ្យចេះគិតយកចិត្តអ្នកដទៃមកដាក់ក្នុងចិត្តខ្លួន គឺឲ្យចេះគិតពិចារណាប្រៀបធៀបថា ចិត្តរបស់យើងស្រឡាញ់សេចក្ដី

សុខ ស្រឡាញ់ជីវិត ស្អប់ខ្លាចទុក្ខលំបាកយ៉ាងនោះដែរ ។ គេបៀតបៀនយើងដោយកាយវាចា យើងបានសេចក្ដីទុក្ខក្ដៅក្រហាយយ៉ាងណា យើងបៀតបៀនគេវិញ គេក៏មានសេចក្ដីទុក្ខក្ដៅក្រហាយដូចយើងយ៉ាងនោះដែរ ។ កាលពិចារណាឃើញដូច្នោះហើយ ត្រូវបេះផ្សាយមេត្តាអាណិតអាសូរដល់គ្នានឹងគ្នា តាំងចិត្តចៀសវាង ការបៀតបៀនគ្នាប្រទូស-រ៉ាយគ្នាតរៀងទៅ ដែលជាហេតុឲ្យកើតសេចក្ដីសុខសន្តិភាពដល់មនុស្សគ្រប់ៗគ្នា ។ អាចនឹងមានសំនួរថា បើពិតដូច្នេះមែន ចុះហេតុអ្វីក៏ប្រទេសដែលកាន់ព្រះពុទ្ធសាសនាដូចគ្នានៅតែមានការទាស់ទែងខ្វែងគំនិតគ្នាមានការបៀតបៀនដែរ ? ឆ្លើយថា ព្រោះពលរដ្ឋនៃប្រទេសទាំងនោះល្មើសព្រះពុទ្ធដីកា គឺមិនបដិបត្តិតាមនូវពាក្យប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ។ ពាក្យថា ពុទ្ធសាសនិកជន គឺអ្នកកាន់ព្រះពុទ្ធសាសនានោះ មិនមែនមានន័យថា ពលរដ្ឋទាំងនោះសុទ្ធតែគោរពបដិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ទាំងអស់ទេ, ជនពួកខ្លះ គ្រាន់តែជាពុទ្ធសាសនិកដោយកំណើតប៉ុណ្ណោះក៏មាន គឺថាមាតាបិតាជាពុទ្ធសាសនិកផងដែរ តែគ្មានបានសិក្សាព្រះពុទ្ធសាសនាសោះក៏មាន ខ្លះក៏បានសិក្សាខ្លះដែរ តែមិនបដិបត្តិតាម ប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិរបស់ព្រះពុទ្ធជាម្ចាស់ក៏មាន ។ ប្រៀបដូចជា ច្បាប់សម្រាប់ប្រទេសនីមួយ ៗ កើតឡើងអំពីឆន្ទៈរបស់ប្រ-ជាពលរដ្ឋ ហើយត្រូវតាំងឡើងដើម្បីការពារកុំឲ្យពលរដ្ឋប្រព្រឹត្តអាក្រក់មាន

លួចប្លន់ជាដើម ចុះហេតុដូចម្ដេចបានជានៅតែមានមនុស្សលួចប្លន់មិនចេះអស់? ឆ្លើយថា ព្រោះពលរដ្ឋមិនគោរពច្បាប់, ច្បាប់មានគឺពិតមែន តែបើពលរដ្ឋល្មើស មិនព្រមប្រតិបត្តិតាម ការលួចប្លន់ជាដើមក៏មិនអាចនឹងអស់ទៅបាន, ហេតុនោះ ការដែលមានច្បាប់ហើយ នៅតែមានចោរលួចប្លន់នោះ មិនមែនមកអំពីច្បាប់ទេ គឺមកអំពីមនុស្សមិនព្រមគោរពច្បាប់នោះឯង សេចក្ដីនេះយ៉ាងណាមិញ ប្រទេសដែលកាន់ពុទ្ធសាសនានៅតែមានការឈ្លោះវិវាទគ្នានោះ ក៏មិនមែនមកអំពីព្រះពុទ្ធសាសនាទេ គឺមកអំពីពលរដ្ឋនៃប្រទេសនោះ ៗ មិនព្រមប្រតិបត្តិតាមព្រះពុទ្ធោវាទយ៉ាងនោះដែរ ។ សរុបសេចក្ដីថា ការដែលប្រទេសកាន់ព្រះពុទ្ធសាសនានៅតែមានការបៀតបៀនគ្នានោះ មិនមែនមកពីព្រះពុទ្ធសាសនាទេ ព្រះពុទ្ធសាសនា មានគោលការណ៍សុទ្ធតែនាំឲ្យកើតសេចក្ដីសុខ ឲ្យចៀសវាងការបៀតបៀនប្រទូសរ៉ាយគ្នាទាំងអស់ ។ តាមគោលការបញ្ចសីល បញ្ចធម៌ដូចពោលមកនេះ ប្រសិនបើមនុស្សប្រតិបត្តិតាមឲ្យដិតដល់ហើយ រមែងបានទទួលលទ្ធផលគឺ សេចក្ដីសុខសេចក្ដីចំរើនសមដូចសេចក្ដីប្រាថ្នាជាមិនខាន ។ ឧទាហរណ៍ដូច មនុស្ស ៣ នាក់នៅជាមួយគ្នា ហើយតាំងចិត្តរៀង ៗ ខ្លួន គឺថា អ្នកទី ១ តាំងចិត្តថា នឹងមិនបៀតបៀនអ្នកទី ២ និងអ្នកទី ៣ អ្នកទី ២ ក៏តាំងចិត្តថា នឹងមិនបៀតបៀនអ្នកទី ១ និងអ្នកទី ៣, ឯអ្នកទី ៣ ក៏តាំងចិត្តថា នឹងមិនប្រទូសរ៉ាយអ្នកទី ១ និង

អ្នកទី ២ ៗ កាលបើតាំងចិត្តនឹងបដិបត្តិយ៉ាងតឹងរ៉ឹងបានយ៉ាងនេះ អ្នកទាំង ៣ ក៏នឹងមិនមានការប៉ះទង្គិចគ្នា មិនមានការបៀតបៀនប្រទូសរ៉ាយគ្នានិងគ្នាឡើយ, បើគ្មានការបៀតបៀនគ្នាហើយ សេចក្តីទុក្ខសេចក្តីក្តៅក្រហាយក៏គ្មាន, អ្នកទាំង ៣ នឹងមានតែសេចក្តីសុខក្សេមក្សាន្តជាដរាប បើមនុស្ស ១០ នាក់ដែលនៅជាមួយគ្នា ធ្វើបានយ៉ាងនេះ មនុស្សទាំង ១០ នាក់នោះ ក៏នឹងមានសេចក្តីសុខស្ងប់ស្ងៀម គ្មានសេចក្តីទុក្ខឡើយ, បើពលរដ្ឋនៅក្នុងប្រទេសជាមួយគ្នា ធ្វើបានយ៉ាងនេះ ពលរដ្ឋទាំងនោះក៏នឹងបានសេចក្តីសុខសេចក្តីចំរើនគ្រប់ ៗ គ្នា, ហេតុនេះ ប្រសិនបើមនុស្សនៅក្នុងសាកលលោកទាំងមូលនេះ បដិបត្តិយ៉ាងនេះ សាកលលោកទាំងមូលក៏នឹងមានតែសេចក្តីស្ងប់រៀបរយ គ្មានការកាប់សម្លាប់គ្នា គ្មានការធ្វើសង្គ្រាមបង្ហូរឈាមឡើយ, មនុស្សក្នុងសាកលលោក ក៏នឹងមានតែសេចក្តីសុខក្សេមក្សាន្ត ប្រាសចាកសេចក្តីទុក្ខក្តៅក្រហាយជាពិតប្រាកដ ៗ

នេះឯង គឺជាវិធីស្វែងរកសេចក្តីសុខសន្តិភាព ខាងផ្លូវព្រះពុទ្ធសាសនា ដែលមនុស្សអនុវត្តតាមហើយ នឹងបានសម្រេចផលតាមសេចក្តីប្រាថ្នា គឺជាវិធីការដែលប្រសើរ មិនអន់ថយជាងវិជ្ជាឬវិធីការខាងផ្លូវលោក ឬក៏អន់ថយជាងគោលការនៃសាសនាដទៃនោះទេ ហើយមិនមែនគ្រាន់តែជាសាសនាដែលមានគោលការទាន់សម័យប៉ុណ្ណោះទេ តែជាសាសនា

ដែលមានគោលការនាំមុខវិធីការខាងផ្លូវលោកថែមទៀតផង ព្រោះព្រះពុទ្ធជាម្ចាស់បានទ្រង់សំដែងពុទ្ធវិធីនេះទុកមកជាង ២៥០០ ឆ្នាំហើយ, ឯវិធីការផ្សេង ៗ ខាងផ្លូវលោក ទើបនឹងកើតមានឡើងនៅពេលក្រោយនេះឯង ៗ ហេតុនោះ អស់លោកអ្នកអានទាំងឡាយដែលជាពុទ្ធសាសនិកជនកុំគប្បីទុកតូចចិត្តនឹងព្រះពុទ្ធសាសនារបស់យើងថាជាសាសនាអន់ថយជាងវិជ្ជាការខាងផ្លូវលោកឡើយ គួរត្រិះរិះពិចារណាសាជាថ្មី ហើយសេចក្តីរីករាយពេញចិត្តចំពោះព្រះពុទ្ធសាសនា ដែលជាសាសនារបស់ជាតិជាយើងឈ្មោះថាជាអ្នកមានភ័ព្វសនាធំណាស់ ដែលបានកើតមកទាន់ព្រះឱវាទពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលជាព្រះឱវាទដ៏មានតម្លៃទាន់សម័យ និងមានសភាពស័ក្តិសិទ្ធិអាចធ្វើឲ្យយើងជាពុទ្ធសា-សនិកអ្នកបដិបត្តិតាមយ៉ាងពិតដល់ បានសម្រេចប្រយោជន៍តាមសមគួរដល់ការបដិបត្តិរៀង ៗ ខ្លួន ពោលគឺ អាចជួយឲ្យមនុស្សអ្នកបដិបត្តិតាមបានផុតអំពីសេចក្តីទុក្ខភ័យ ហើយបានជួបប្រទះនឹងសេចក្តីសុខក្សេមក្សាន្តដូចសេចក្តីដែលបានធ្វើអត្ថាធិប្បាយមកដូច្នេះឯង ៗ

# ផ្នែកអក្សរសាស្ត្រ

| | |
|---|---|
| អក្សរសាស្ត្រខ្មែរ | ខ្មែរគួរថែថ្នម |
| ឲ្យបានខ្ជាប់ខ្ជួន | គង់វង្សគត់មត់ |
| ព្រោះអក្សរជាតិ | ពោលជាតិប្រាកដ |
| អក្សររលត់ | ជាតិក៏រលាយ |

ប.ព.

## ពិចារណាដើម្បីយល់តក្កវិជ្ជា

(គ)

លោក ហ៊ុន គិមសៀ រៀបរៀង

តក្កសាស្ត្របុរាណ ជាវិទ្យាសាស្ត្រមួយបែបគ្មានប្រកាន់វណ្ណៈ គឺជាឧបករណ៍មួយយ៉ាងសម្រាប់មនុស្សទូទៅ ប៉ុន្តែក្នុងការសិក្សាដែលអាចឲ្យឆាប់យល់ច្បាស់ហើយត្រឹមត្រូវផងនោះ គេត្រូវប្រកាន់យកគំនិតវិទ្យា-សាស្ត្រ ដែលជាគំនិតជាក់ស្តែង គំនិតរកហេតុផលគ្រប់គ្រាន់ និងមានកស្តុតាង ។

## ការយល់ក្នុងគ្រាដំបូង

មនុស្សមានគំនិតវិទ្យាសាស្ត្រគេយល់ថា : ការបេះដូងរបស់មនុស្សក៏ត្រូវឆ្លងកាត់រយៈពេលបីយ៉ាង ហើយរយៈពេលទាំង៣យ៉ាងនោះ ក៏ទាក់ទងគ្នាយ៉ាងជិតស្និទ្ធ មានវិធានរបស់វា ៗ ឥឡូវយើងយករយៈពេលនីមួយ ៗ មកពិចារណាសភាពការបេះដូងរបស់មនុស្សយើងល្បងមើល ៗ

មុនដំបូងយើងនិយាយ អំពីការយល់ក្នុងគ្រាដំបូង :

មនុស្សយើងមានបញ្ចេន្ទ្រិយ ( Cinq sens ) កាលណាសម្ភារៈ ឬ ធាតុក្លូតខាងក្រៅវាមកប៉ះទង្គិចនឹងបញ្ចេន្ទ្រិយ នាំឲ្យកើតមានជាវិញ្ញាណ ( Sensation ) ។ ភ្នែកមើលឃើញពន្លឺ, ឃើញពណ៌សម្បុរសខ្មៅ.. ត្រចៀកឮស្នូរសម្លេងពិរោះ ឬ សម្លេងស្អា . . . ដៃកាន់វត្ថុដឹងថារបស់ទន់ របស់រឹង . . . ។ល។ ហេតុដូច្នេះ ការចេះដឹងរបស់មនុស្ស ចាប់ផ្ដើមពីវិញ្ញាណ ពីព្រោះថា : វិញ្ញាណជាលទ្ធផលនៃការប៉ះទង្គិច រវាងបញ្ចេន្ទ្រិយ និងសម្ភារៈ ក្នុងសាកលលោកខាងក្រៅ ។

ឧទាហរណ៍ : វិញ្ញាណយើងដឹងថា ភ្លើងវាក្ដៅ ពីព្រោះយើងទៅជិតភ្លើង វាមានចំហាយក្ដៅមែន (មានយើង+ភ្លើង=ក្ដៅ) តើមានវិញ្ញាណអ្នកណាខ្លះដែលដឹងថា ផ្កាយវាក្ដៅ បើយើងមិនដែលរៀនចក្រវាឡសាស្ត្រ ម្ដងណាសោះ ? ។

សុំប្រាប់ថែមទៅទៀតថា : វិញ្ញាណអាចចុះបានតែលក្ខណៈឬភាពមួយ ១ នៃវត្ថុប៉ុណ្ណោះទេ ប៉ុន្តែផ្ទុយទៅវិញ វត្ថុនីមួយ ១ មានលក្ខណៈនិងភាពរបស់វាច្រើនបែបច្រើនយ៉ាង ។ ឧទាហរណ៍ : យើងមើលគោ យើងឃើញភាពនិងលក្ខណៈវាច្រើនដូចជា : ពណ៌សម្បុរ ទំហំ, ចាស់ក្មេង, ស្គមធាត់ . . . លក្ខណៈទាំងអស់នេះវាចូលមកក្នុងភ្នែកយើងទាំងអស់ ដូច្នេះ ក្នុងពេលដែលយើងមើលឃើញវត្ថុឬព្

សម្ពន្ធ័ រូបក៏ចូលមកក្នុងខួរក្បាលយើង ក៏មិនមែនចូលមកតែមួយ ឬពីរលក្ខណៈប៉ុណ្ណោះទេ គឺក៏ចូលមកព្រមគ្នាទាំងអស់ក្នុងមួយពេលតែម្តង នាំឲ្យយើងមានវិញ្ញាណយ៉ាងសព្វគ្រប់ (គឺដឹងថា គោបាស់, គោស្គម, គោក្រហម, គោខ្ចិចត្រូវលក់ឲ្យគេប្រញាប់) វិញ្ញាណទាំងនោះ ក៏ទាក់ទងគ្នាមានឯកភាពយ៉ាងស្រុះស្រួលគ្នា ដែលនាំឲ្យកើតទៅជាបញ្ញាញាណ ឬ ជាការដឹងច្បាស់ ។

ក្រៅអំពីវិញ្ញាណនិងបញ្ញាញាណ មនុស្សនៅមានទស្សនៈមួយទៀត (Concept) គឺថា : នៅចំពោះមុខយើងមានវត្ថុមួយ វត្ថុនោះនាំឲ្យយើងមានជាវិញ្ញាណនិងបញ្ញាញាណដោយផ្ទាល់ ។ ដល់យើងយកវត្ថុនោះទុកបាត់ទៅ ក៏នៅមានរូបកងទីងបែបផែននៅក្នុងខួរក្បាលយើងនៅឡើយ នេះហៅថា ទស្សនៈ ។

ឧទាហរណ៍ : បងឯងមើលឃើញខ្ញុំ ខ្ញុំឃើញបងឯង យើងមានវិញ្ញាណ និង បញ្ញាញាណចំពោះគ្នាទៅវិញទៅមក ។ បងឯងត្រូវទៅស្រុកឆ្ងាយ យើងទាំងពីរនាក់នឹករឭកគ្នា នៅចាំរូបរាងគ្នា ចាំសម្តីនិយាយគ្នា ចាំសំឡេងសើច របស់គ្នា នេះហើយហៅថាទស្សនៈ ។

កន្លងមកយើងទាំងអស់គ្នាបានយល់ហើយអំពីវិញ្ញាណ, បញ្ញាញាណ និង ទស្សនៈ ។ ប្រការទាំង ៣ នេះក៏ខុសគ្នា ប៉ុន្តែយើងត្រូវយល់អំពីលក្ខណៈដូចគ្នានៃប្រការទាំង ៣ ខាងលើនេះ ។ គឺកើតឡើងមកតែអំពីការប៉ះទង្គិចរវាងសម្ភារៈ និង បញ្ចេន្ទ្រីយទាំងអស់ ។

យើងទាំងអស់គ្នាបានយល់ថែមទៀតថា ការចេះដឹងរបស់មនុស្ស មិនមែននៅនឹងថ្កល់មួយកន្លែងទេ វាអាចឡើងពីទាបទៅខ្ពស់ ។ មុនដំបូង សម្ភារៈ វាមកប៉ះនឹងឥន្ទ្រិយ នាំចូលទៅក្នុងខួរក្បាល កើតបានជាវិញ្ញាណ កើតជាការដឹង ហើយបន្តទៅទៀត វានាំឲ្យមនុស្ស មានការពិចារណា; ការត្រិះរិះរកហេតុរកផល, ការពិនិត្យដើម្បីឲ្យយល់អស់នូវបាតុភូតនីមួយៗ ទៀត ។ល។

## ការយល់នៅលើកទី២ និង ទី៣

សម្ភារៈទាំងអស់នៅក្នុងលោក សុទ្ធតែមានចលនារបស់វា, ហើយ ខួរក្បាលរបស់មនុស្សយើង ក៏មានចលនារបស់វាដែរ ។ ចលនារបស់ខួរក្បាលយើង ហៅថា „ ការពិចារណា ” ឬ “ ការគិត ” ។

ឧទាហរណ៍: យើងនៅក្នុងផ្ទះ, ឮសូរឆ្កែព្រុស យើងគិតភ្លាមថា: នៅខាងក្រៅមានមនុស្សឬមានបាតុភូតអ្វីចំឡែក ។ ហេតុនេះចលនានៃខួរក្បាលវាចាប់ផ្ដើមពីវិញ្ញាណ, ចាប់ផ្ដើមពីសម្ភារៈប៉ះទង្គិចនឹងបញ្ចិន្ទ្រិយ, ចាប់ផ្ដើមពីទស្សនៈ ។

វិញ្ញាណ និង បញ្ញាញាណផ្ដល់ឲ្យខួរក្បាលនូវឧបករណ៍ ដើម្បីគិត ដែលបញ្ចិន្ទ្រិយ ទទួលបានមក ហើយទស្សនៈជាអ្នករក្សាទុកនូវឧបករណ៍ទាំងនោះក្នុងខួរក្បាល ។ បន្ទាប់មក ខួរក្បាលវាចាប់ផ្ដើមត្រិះរិះពិចារណា នូវឧបករណ៍ទាំងនោះ តាមរបៀបតក្កវិជ្ជា រួមមានរបៀប :

ពិចារណាប្រៀបធៀប

ពិចារណាវែកញែក និង ចងក្រង

ពិចារណាសន្និដ្ឋាន និង ការប្រមាណស្ទង់ហេតុ

បន្ទាប់ពីការពិចារណាបាតុភូត តាមរបៀបតក្កវិជ្ជាហើយ ទើបខួរក្បាលមនុស្សមានការចេះដឹង មានការយល់កាន់តែទូលាយឡើងថែមទៀត ។

ឧទាហរណ៍: មូសកើតពីទឹកស្អុយ ហើរមកខាំមនុស្ស, មនុស្សត្រាំមិនបានគិតរកមធ្យោបាយការពារ ។ មុនដំបូង មនុស្សដុតភ្លើងផ្សែងការពារ បន្ទាប់មកយកមុង ដល់យូរៗទៅ មនុស្សកាន់តែជឿនលឿន មនុស្សចេះប្រើថ្នាំការពារ ទៅអនាគតមនុស្សនឹងបំបាត់មូសឲ្យអស់ពីផែនដីតែម្តង កាលណាមនុស្សមានសមត្ថភាពវិទ្យាសាស្ត្រគ្រប់គ្រាន់ ។ នេះហើយហៅថាការយល់ឬការចេះរបស់មនុស្ស គឺវាមានការរីកកាន់តែយល់ឡើងបែបនេះឯង ។

យើងសុំបញ្ជាក់ឧទាហរណ៍មួយទៀត ដូចជាពេជ្រ :

មុនដំបូង មនុស្សដឹងថា ពេជ្រជារតនវត្ថុមួយភ្លឺថ្លាឆ្លាំងចែងចាំងស្រស់ល្អ, ហេតុនេះគេយកវាមកធ្វើជាគ្រឿងអលង្ការ, តមកទៀត គេដឹងថាវារឹងជាងលោហធាតុអ្វីទៀតទាំងអស់, ហេតុនេះ មនុស្សគេយកវាមកធ្វើជាមុល ឬ ធ្វើជាប្រដាប់សំរាប់កាត់កញ្ចក់ ។ល។

មិនមែនដូចអាជ័យ ម្ដាយប្រើឲ្យទៅរកឈើ "ដំពាម" ក្នុងព្រៃយកមកធ្វើជើងក្ដារនឿ ទៅរកមួយថ្ងៃទល់ល្ងាច ត្រឡប់មកផ្ទះវិញក៏ឆ្លើយប្រាប់ម្ដាយថា: គ្មានដំពាមក្បាលចុះក្រោមទេ មានតែ "ដំពាម" ក្បាលឡើងទៅលើ ។ នេះបានចំជាអាជ័យ ក្បាលទៅលើឬចុះក្រោមស្រេចតែគេបង្កិលទេតើ ! ។

ដើម្បីរើសអើងនិងវែកញែក រាល់ប្រការចាំបាច់និងមិនសូវចាំបាច់ ប្រការជាធម្មធាតុក្នុងសម្ភារៈ និងការដែលប្រែប្រួលនៅក្នុងធម្មជាតិ តក្កវិជ្ជា គេប្រើវិធី "ទូទៅ" និង វិធីពិចារណាខាងគំនិតនិយម ។

សមត្ថភាពខាងពិចារណា គឺជាសមត្ថភាពរបស់មនុស្ស ពីព្រោះមនុស្សមានការពិចារណាខាងខួរក្បាល (សត្វដទៃគ្មានការពិចារណាទេ)។

នៅក្នុងដំណើរជីវភាពរាល់ថ្ងៃ មនុស្សប្រើការពិចារណា ខាងគំនិត ឧទាហរណ៍ ដូចជា "នៅក្នុងផ្ទះនេះ មានមនុស្ស ១៥ នាក់" ។ ស្ដាប់តាមយើងអាចយល់ថា ឃ្លានេះជាក់លាក់ពេក ប៉ុន្តែផ្ទុយទៅវិញ ឃ្លានេះមិនទាន់ជាក់លាក់ប្រាកដប្រជានៅឡើយទេ ។ ពីព្រោះ ១៥ នាក់ ក៏នៅជាអរូប ។ មនុស្សគឺជា នាមនាមទូទៅ ។ ១៥ នាក់គឺជាបកតិសំខ្យាទូទៅ ។

យើងយកឧទាហរណ៍ ១៥ នាក់នេះ មកនិយាយចុះ ។ ម្នាក់ៗសុទ្ធតែមានអាយុខុសគ្នា, ពណ៌សម្បុរខុសគ្នា, រាងរៅសំដីសំដៅខុស

គ្នា ! . . . នេះយើងមិនទាន់និយាយអំពីចិត្តថ្លើម និងអធ្យាស្រ័យខុសគ្នាថែមទៀតផង ដែលជាគុណសព្ទរបស់លក្ខណៈមនុស្ស ៗ ដូច្នេះ ១៥ នាក់យើងនិយាយអំពីបញ្ហាដូចគ្នាគឺ "មនុស្ស" គឺចំនួនប៉ុណ្ណោះ ៗ

ហេតុនេះ "មនុស្ស" គឺជាសព្ទ នាមមិនជាក់លាក់ (និយាយរួម) មានតែមនុស្សទូទៅ ចំណែកមនុស្សជាក់លាក់ គឺមនុស្សណាធាត់ ឬ ស្គម ធំ ឬ តូច . . . ។ល។ ហេតុដូច្នេះហើយ បានជាយើងនិយាយថា ការយល់របស់មនុស្សក៏មានពីរ ការយល់ខាងគំនិត នៅការយល់ខាងសម្ភារៈ រួចពីការយល់ខាងសម្ភារៈ ត្រឡប់មកការយល់ខាងគំនិតវិញ គឺការពិចារណាខាងខួរក្បាល ដើម្បីយល់ធាតុកូតនៃសម្ភារៈ ៗ ពីព្រោះសម្ភារៈក៏មានគុណលក្ខណៈច្រើន ដូចជាមនុស្សម្នាក់ក៏មានគុណលក្ខណៈ ខ្មៅ, ស, ក្មេង, ចាស់, ធាត់, ស្គម, ស្លូត, កាច ។ល។

និយាយសង្ខេបមក ក្នុងបញ្ហានៃការពិចារណានេះ មនុស្សយើងក៏មានការចេះដឹង ឬថាការយល់ច្រើនលើកច្រើនគ្រា ៗ ការយល់លើកទី ១ ក៏ខុសនឹងការយល់លើកទី ២ ពីព្រោះការយល់លើកក្រោយ ក៏ច្បាស់លាស់ ហើយជ្រាលជ្រៅជាងលើកទី ១ ៗ

# ទស្សនិយម ( CONCEPT )

ក– ធម្មជាតិនៃទស្សនៈ

ខ– ទស្សនិយម និង ភាសា

គ– លក្ខណៈផ្ទាល់ និង លក្ខណៈទូទៅនៃទស្សនៈ

ឃ– ការទាក់ទងរវាងលក្ខណៈទូទៅ និង លក្ខណៈផ្ទាល់

ង– ទស្សនៈប្រភេទ និង ទស្សនៈតួដ (បំពូក)

ច– ការទាក់ទងរវាងទស្សនៈ

## ក_ ធម្មជាតិនៃទស្សនៈ

យើងទាំងអស់គ្នាបានតាមដានអំពីការពិចារណារួចហើយ ឥឡូវយើងមកដល់ ទស្សនិយមហើយ ( Concept ) ។ ទស្សនិយមគឺជាអត្ថសេសំខាន់នៅក្នុងតក្កវិជ្ជា ។

មុនដំបូងបង្អស់យើងត្រូវយល់ជាមុនសិន នូវពាក្យថា " ទស្សន-និយម" ។

វិញ្ញាណរបស់មនុស្ស ឬ ជាបញ្ចេន្ទ្រីយរបស់មនុស្ស រាប៉ះពាល់និងសម្ភារៈនិងបាតុភូត(Phénomène)ខាងក្រៅ នាំឲ្យមានការចាប់អារម្មណ៍នៅក្នុងវិញ្ញាណ ការចាប់អារម្មណ៍នៅក្នុងវិញ្ញាណនោះហើយ ដែលហៅថា: ទស្សនិយម ។

ឧទាហរណ៍ : យើងយកភ្លើងជាកម្មវត្ថុ ។ ភ្លើកមនុស្សប៉ះនឹងកម្មវត្ថុខាងក្រៅ គឺ (ភ្លើង) នាំឲ្យអារម្មណ៍របស់យើងមានទស្សនៈនិយមមួយ គឺសត្វក្ដៅ ។ និយាយមួយបែបទៀតថា ទស្សនៈនិយម គឺជាការចាប់អារម្មណ៍នៃខួរក្បាលដែលកើតឡើងមកអំពីវត្ថុជាសម្ភារៈខាងក្រៅ(កម្មវត្ថុ) មកប៉ះទង្គិចនឹងឥន្ទ្រិយរបស់មនុស្ស ។ ទស្សនៈគឺជាលទ្ធផលខ្ពស់បំផុតនៃខួរក្បាល ក៏មិនមែនគ្រាន់តែជាការយល់ធម្មតា ការឃើញធម្មតា ការដឹងធម្មតា គឺការរួមទាំងការ និងឃើញ-យល់ហើយមានការពិចារណាជ្រាលជ្រៅច្បាស់លាស់បូកថែមទៅទៀតផង គឺថា ទស្សនៈមិនមែនគ្រាន់តែជា ការយល់ឃើញសើ ៗ ខាងក្រៅនៃសម្ភារៈប៉ុណ្ណោះទេ ផ្ទុយទៅវិញ គឺក៏ជាការយល់យ៉ាងជ្រាលជ្រៅគ្រប់ហេតុ ផល បច្ច័យ ទាំងអស់នៃសម្ភារៈ ។

នៅក្នុងសង្គមមនុស្សទូទៅ ក៏មានទស្សនៈពីរផ្ទុយគ្នា គឺទស្សនៈមួយកកើតគំនិត ឬ អារម្មណ៍របស់មនុស្ស ដែលយើងហៅថា ទស្សនៈ (គំនិតនិយម) ឬ ទស្សនៈយល់សច្ចនិយម ទស្សនៈដែលមានតែនៅក្នុងគំនិត ទស្សនៈមិនពិត និងទស្សនៈមួយទៀត គឺពិតប្រាកដ មានការជាក់លាក់ ដែលយើងហៅថា ទស្សនៈសម្ភារនិយម ។

ឧទាហរណ៍ : ដូចជាអង្គុយសំកុកមើលមេឃ ហើយចង់ឡើង

ឋានសួគ៌ ។ នេះជាទស្សនៈគំនិតនិយម ។

ចង់បេះឲ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាឲ្យយកភ្លើងដុតគល់ ។ល។ នេះជាទស្សនៈសម្ភារៈនិយម ។

យើងនិយាយកាន់គ្នាទៅវិញទៅមករាល់ថ្ងៃ បានសេចក្ដីថា យើងប្រើទស្សនៈ ដើម្បីប្ដូរអារម្មណ៍របស់យើង ។ បណ្ដាទស្សនៈដែលយើងប្រើរាល់ថ្ងៃ គឺជាការចេះដឹងរបស់មនុស្ស ឆ្លងកាត់ច្រើនសតវត្សមកហើយ ដែលពពួកមនុស្សខំប្រឹងប្រមែប្រមូលបានមកគ្រប់វិស័យ ។

នៅក្នុងទំព័រប្រវត្តិសាស្ត្រនៃដំណើរលូតលាស់របស់ (ការគិត) វាមានពីរយ៉ាងគឺ ការគិតម្យ៉ាងវាពិត ជាប្រាកដនិយម ការគិតម្យ៉ាងទៀតវាមិនពិត ដូចជាការគិតអំពីខ្មោចព្រាយ ជឿអារក្សអ្នកតា ជាដើម ។ គំនិតមិនពិត គេមិនអាចបញ្ជាក់បានតាមរបៀបសម្ភារៈ ឬ តាមសង្គមមនុស្សជាក់ស្ដែងបានទេ ហើយសំដីនិយាយដែលគេចង់គ្រង់ទៅជាទ្រឹស្ដីក៏មិនរឹងប៉ឹងដែរ ពីព្រោះគ្មានមូលដ្ឋានជាកំណត់ ។

## ១_ ទស្សនិយម និង ភាសា

សតិអារម្មណ៍និងភាសា វាមានការទាក់ទងគ្នាជិតដិតណាស់ ។ ភាសា, ពាក្យ, សំដី, អក្សរ . . . គឺជាសញ្ញាដើម្បីសម្ភាររូបនីយកម្ម (Matérialiser) សតិអារម្មណ៍ ដើម្បីលាតត្រដាងគំនិតឲ្យចេញមកក្រៅ។

(នៅមានត)

–ជាតិតា ស្ត្រី. ភាវនៃអ្នកដែលកើតក្នុងវណ្ណៈចុងបំផុត ។ –អន្ត្យាធិ បុំ. ភាគខាងចុង ។

អន្ត្យាវសាយិន៑ បុំ. អ្នកនៅក្នុងវណ្ណៈចុងបំផុត ។

អន្ត្រ នបុំ. ពោះវៀន ។ –ឝិលា ស្ត្រី. តាមស្ទឹង ។

អន្ត្រាបីឌ ប្រការិន៑ គុ. ដែលប្រាប់ថាមានពោះឈឺខ្លាំង ។

អន្ទុ-ន្ទូ ស្ត្រី. ខ្សែប្រវក់តូច (សម្រាប់ស្ត្រីពាក់កជើង) ។

អន្ទោលន នបុំ. កិរិយាយោល (ទោង) ។

អន្ធ គុ ខ្វាក់, ងងឹត, ល្ងង់ខ្លៅ ។ –តា ស្ត្រី. អន្ធការភាព ភាពខ្វាក់ ។ –ការ បុំ. នបុំ. អន្ធការ ។ គុ. ដែលអន្ធការ, តា ស្ត្រី. អន្ធការភាព; អន្ធការិត គុ. ដែល

ធ្វើឲ្យខ្វាក់ ឬ ឲ្យងងឹត, អន្ធការិន គុ ដែលងងឹត,
ខ្មៅ ។ -មយ គុ ដែលងងឹត ។ -កូប បុំ.
អណ្ដូងងងឹត, ឋានរក ។ -តមស៍ ឬ -តមស
នបុំ. កិរិយាងងឹតក្រៃលែង ។ -តមិស្រ នបុំ. ភាព
ងងឹត, ឋានរក ។

អន្ធក គុ. ខ្វាក់, ល្ងង់, ខ្មៅ ។ បុំ. នាមអសុរ និងអ្នកដទៃទៀត ។
នាមប្រទេស ។ -ឃាតិន៍ ឬ -រិបុ បុំ. ឥសូរ ។
អន្ធកាន្តក បុំ. ឥសូរ ។

អន្ធសិ នបុំ. ចំណីអាហារ ។

អន្ធ្រ បុំ. ពហុ. នាមវណ្ណៈលោកទាប ។ នាមប្រជាជន នៅប្រទេសតេលុគុ ។

អន្ន នបុំ. ចំណី អាហារ បាយ ។ -វន្ត គុ ដែលមានអាហារ ។
ទ ឬ ទាត្ឫ គុ អ្នកឲ្យអាហារ ។ -ទោឞ បុំ.
អន្នទោស ។ -បក្តិ ស្ត្រី. កិរិយាចំអិនអាហារ ។
បតិ បុំ. សវិតរ ។ -ប្រាឝន នបុំ. អន្នប្រាសន៍

អាហារដែលឲ្យទារកមុនដំបូង, នាមរីតិ ។ –មល នបុំ.
អន្នមល, មេរ៍យ ។ –រស បុំ. អន្នរស, អន្ននិងបាន;
បុំ. រសនៃអាហារ ។ –វិការត្វ នបុំ. ការនៃកិរិយាធ្វើ
ឲ្យក្លាយជាអាហារ ។ –វិក្ឫតិ ស្ត្រី. –សំស្ការ បុំ.
កិរិយាចំអិនអាហារ ។ អន្នាទ គុ. ដែលស៊ីអាហារ;
បុំ បុត្រនៃក្ឫស្ណ ។ អន្នាទិន គុ អន្នាទិន ដែលស៊ី
អាហារ ។ អន្នាទ្យ នបុំ. ចំណីអាហារ, គ្រឿង
បរិភោគ ។ ភាពមាំមួន ។ អន្នាយុ គុ. អន្នាយុ,
ដែលចង់បរិភោគអាហារ ។

អន្នមយ គុ. ដែលជាវិការនៃអាហារ ។

អន្យ គុ. ដទៃ ផ្សេង មួយទៀត ដទៃទៀត ។ –ក្ឫត
គុ. ដែលមានអ្នកធ្វើការមួយទៀត ។ –កាម គុ. ដែល
ស្រឡាញ់អ្នកមួយទៀត ។ –គិ គុ. ដែលទៅកាន់
អ្នកមួយទៀត, ដែលមិនស្មោះត្រង់, –គាមិនិ ដូចគ្នា ។

_បិត្ត គុ. ដែលមានចិត្តបញ្ចូនទៅកាន់អារម្មណ៍ដទៃ ។

_បេតស៍ គុ ដែលមានចិត្តបែកចេញ, ភយមាយ ។

_ជិ គុ ដែលកើតអំពីអ្នកដទៃ ។ _ជន្មន នបុំ អន្យជន្មន, កំណើតក្នុងអនាគត ។ _ជាត បុំ. អន្យ-ជាត, អ្នកកើតអំពីមាតាបិតាឥតខាន់ស្លា ។ _បរ គុ. ដែលទាក់ទងដោយអ្នកដទៃ ។ _បុព្វ៍ ឬ _ភូតា ស្ត្រី. នាមលលកញី ។ _បូវ៌ា ស្ត្រី. អន្យបូវ៌ា ស្ត្រីជាដែលគេដណ្តឹង ឬ ការហើយដោយប្រុសដទៃមុនរៀបការទៀត ។ _មនស៍ គុ. ដែលមានចិត្តទៅកាន់អារម្មណ៍ដទៃ, សាភ ។ មាតុក៏ គុ ដែលមានមាតាមួយទៀត ។ _យុក្ត គុ ដែលជាប់ដោយអ្នកដទៃ ។ _រាជិក គុ ដែលមានព្រះរាជាមួយទៀត, ដែលជារាស្ត្រនៃព្រះរាជាមួយទៀត ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ១២

(ក)

លោក ឌឹក-គាម

ស្រាវជ្រាវ និង រៀបរៀង

កាលនោះ ព្រះភិរុទព្រះសុត្រុតទាំងពីរព្រះអង្គ ទ្រង់បានស្តាប់ព្រះបិតុរេសធិបតី ក៏លើកដៃអញ្ជលីទទួលព្រះបញ្ជា ទើបថ្វាយបង្គំលាព្រះជនកព្រះជននី លាទាំងព្រះលក្សណ៍ និងអង្គសម្តេចព្រះរាមាធិបតី និងព្រះអគ្គកជសីតាស្រេចហើយ ព្រះអង្គក៏យាងមកឡើងគង់លើរាជរថ ឲ្យលើកកងទ័ពយោធាពលករ ចេញមកនគរអយុធ្យាធានី ក៏ស្រូតរូតទៅតាមផ្លូវពនាលីហោង ៗ ស្តេចលើកនិករយោធាឈប់សម្រាកក្នុងអារញ្ញវេស មករៀង ៗ ក៏បានដល់ក្រុងកៃកេសបុរី ព្រះចក្រីក៏យាងឡើងទៅកាន់ប្រាសាទកែវរតនា ជាសុខក្សេមក្សាន្តហោង ៗ

យើងបញ្ឈប់ទុកស្រេះ ឥឡូវនេះនឹងនិយាយពីទូតតិទ្ធិកាហាន មានទេវឫក្ខទៅថែរក្សាមកជាយូរអង្វែង គុហាកែវសូរ្យកាន្តដូចបានថៅដោះមាតាតែសព្វថ្ងៃ ក៏មានកម្លាំងពលំបូទ្ធាកាហាននោះ ដោយសារបានទេវ-ឫក្ខជួយទំនុកបំរុងរក្សា លុះចម្រើនវ័យ្បនាការធំឡើងគ្រប់ថ្ងៃខែ ពូកែមានឫទ្ធិ ក៏ត្រេចចរយាត្រាចេញមកល្បងដើររត់លេងស្រែកកងរំពងព្រៃ រៃស្ទុះវ័ធបូជាសិលាធំ ៗ ហើយដំដើរតាមគន្លងដានខ្ទូតា ហើយមហាផ្សា

ក៏តាំងត្រាវស្វែងរករបែបប្របដិតតាមគន្ធស្នាមជើងបិតា ល្បងលងមើលទៅ ឃើញគន្ធស្នាមស្វែងរកនោះ ក៏របើកបានធំ ៗ ប៉ុនគន្ធជាងបិតាដែរ ផ្ទេះហើយក៏គិតថា អញនេះល្មមនឹងដល់តស៊ូបាន ទូរគីគិតហើយ បំង កុងចិត្តថា សត្រូវនឹងបិតាមិនភ្លេចឡើយ ហើយថា ថ្ងៃហ្នឹងខ្លួនអញនឹង បិតា ទឹងបានល្បងប្ញទ្ធិគ្នា ដល់មើលឲ្យបានដឹងកម្លាំងប្ញទ្ធិ គិតហើយ ទូរគីក៏អែបខ្លួនពួនកាយា ក្រោមម្លប់មែកឈើធំចាំហិតក្លិន ស៊ីស្មៅនៅរម ទាំងព្រោះ ។

គ្រានោះ ទូរគាប្ញទ្ធាក្លាហាន ដេកនៅនឹងហ្វូងបរិវារទាំងពួង ហើយ ក៏ក្រោកឡើងនាំអស់ហ្វូងបរិវារ ត្រាច់ដើរដោយព្រៃពនាវែន ទៅតាមមគ្គមាគ៌ា សប្បាយតាមចំនេះនឹងចិត្តឥតទើសទាល់ ។ គ្រានោះទូរគីប្ញទ្ធិក្លានោះ លុះឃើញទូរគាបិតាដើរមកហើយ ក៏មានចិត្តនោះត្រេកអរសាទរណាស់ ចង់ដល់ឈ្នះចាញ់ហើយ ក៏ស្ទុះលោតទៅដោយកម្លាំងកំពុងពេញពល ចូលទៅជិតបើកកន្ទុយកង់លើកឡើងលើហើយ ក៏ស្កាត់ផ្លូវនៅចំមុខ ស្រែកទៅថា ស្គាល់អញឬទេទូរគា ខ្លួនអ្នកនេះចិត្តអាក្រក់ឫស្យា មិច្ឆាធម្មា ព្យាបាទ សម្លាប់តែកូនឯងស្លាប់ច្រើនមកណាស់ហើយ យើងនេះ ក៏ជាកូនបង្កើតរបស់អ្នកដែរ តែកុំវេលានេះ យើងប៉ងបំណងមកបំផ្លាញ ជីវិតអ្នកហោង ។

កាលនោះ ទូរគាបានស្តាប់ហើយ ក៏ក្រេវក្រោធប្រឡោតនេះដូច

ភ្លើងប្រល័យកល្ប ហើយក៏រលាស់ស្នែងលើកកន្ទុយកងឡើងលើ ហើយស្រែកទៅថា ខ្លួនឯងនេះ ជាកូនអញ គួរឬមកមាក់ងាយ និយាយមិនគប្បី ព្រោះហើន បានប្រមាថអញជាបិតា ដ៏មានបុណ្យក្រៃ ឮល្បីខ្ចរខ្ចាយសាយសព្វគ្រប់ទីអរញ្ញក ទោះតាំងស្តេចគជសារចុះប្រេង ក៏មិនបានទទឹងរឹងនៅពីមុខអញ ឯងចង់តស៊ូរឹទ្ធិនឹងអញជាបិតា អញនឹងជល់សម្លាប់អាឯងឲ្យស្លាប់ក្នុងគ្រានេះហោង ។

គ្រានោះ កំហែងទូរគីបានស្តាប់ទូរគាពោលពាក្យអហង្ការហើយ ក៏លោតចូលទៅ បំអកឡូកឡូយ ហើយឆ្លើយតបទៅវិញថា ខ្លួនអ្នកធ្ងាទុច្ចរិត ហើយមកអាងអួតរឹទ្ធិនឹងអញដូចម្តេចបាន ទេក៏លោកមិនជួយឲ្យពរជ័យអ្នកទេ ធ្វើម្តេចនឹងបានរួចជីពមរណាក្ស័យនឹងអញពុំខាន ។

គ្រានោះ ទូរគានោះ បានស្តាប់ហើយ ក៏ក្រេវក្រោធពិរោធក្រៃពេក ភ្នែកទាំងពីរនោះ ក្រហមច្រាលដូចភ្លើង ក៏កងកន្ទុយគ្រវីស្នែងគ្រញែងខ្លួន ស្ទុះបោលចូលទៅវាធវៃជល់ដីរបើកលើកឡើង រលាស់រហ័សលោតហក់ ហើយបំណងប៉ងក្នុងចិត្តនោះ នឹងផ្តាច់ជីវិតជីវីហោង ។

គ្រានោះ ទូរគីក៏បែងហៅហានមហិមា ខនក ប្រឹងកាយឈរចាំបម្រុងនឹងជល់ ហើយក៏បែរប្រមុខមក គ្រវីស្នែង គ្រលែងដាក់ ប៉ះស្នែងនឹងស្នែងគ្នា ពថយរៀងខ្លួន រួចក៏ស្ទុះបោលចូលជិត ជល់គ្នាទៀតទៅស្នែងនិងស្នែងគ្រលែងរលាស់ប៉ះគ្នា ឮស័ព្ទសន្ធឹកដូចរន្ទះទាំង ៧ យូរបន្តិច

ទៅ ទូរគោក្អាត់ថយក ទូរគ៏ក៏រុញដល់ជិតគិតកៀករំលៀករំធៅត្រូវត្រង់
កទូរគោ មរណាស្លាប់ទៅហោង ៗ រីទូរគ៏នោះ លុះបានឈ្នះមានជ័យ
ជំនះលើបិតាហើយ មហិន្ទ្រាក៏ត្រេកអរក្រៃ ត្រអាលអួតអរងើយង រត់
ល្បងលងដើង តាមទំនើងដោយចិត្តស្រើបស្រាល លោភលលក្នុងចិន្តា
ទឹកដល់ហ្វូងពួកបរិវារមហិន្ទ្រាញីនោះ ហើយក៏ស្ទុះបោលបោះផ្លោះតម្រង់
មករកក្របីញី ៗ លុះបានមកដល់ហើយ ក៏តាំងស្រូបស្រង់ក្លិនហិតហា
មាត់លិទ្ធមុខលេងដោយស្នេហា ហើយក៏រួមរសតណ្ហាមេត្រីនឹងហ្វូងក្របី
ញីរួចស្រេចកាលណា មហិន្ទ្រាទូរគ៏ សែនសប្បាយកាយសប្បាយចិត្ត
រីតរីងតែរួមរក្សស្នេហា តាមដោយកាសាសត្វ សែនត្រេកាលត្រអាលអង្គ
ក្នុងហិមវន្ត ប្រឡែងលេងនឹងហ្វូងបរិវារមហិន្ទ្រាញី ជាទីសម្រាន្តកាយ
សប្បាយចិត្តហោង ៗ លុះយូរបន្តិចទៅ ក៏ត្រេចយាត្រាត្រង់ ចង់ល្បង
ដើងរត់ចាកពោលពីហ្វូងបរិវារធំហើយ ក៏ត្រេចដើរដោយដងមាគ៌ាស្ពាន
មានចិត្តនោះអហង្ការក្អៀវក្លាហាន លុះបានដើរមកដល់ពនាលីហិមវន្ត ក៏
តាំងដល់ក្នុសិលា ហើយក៏ស្រែកថា រុយពួកទេពទេវៈណា មានសក្តា
អានុភាពក្រៃ ចូលមកជាញជ័យតវិទ្ធគ្នាឲ្យបានដឹងឈ្នះចាញ់ ៗ

កាលនោះ រីអស់ហ្វូងទេវរុក្ខជាធំនៅក្នុងហិមវន្តនាលី បានស្តាប់
ពាក្យមហិន្ទ្រាទូរគ៏ទុច្ចរិតចិត្តបាប ហើយទេវតាក៏ដញ្ជឹងរំពឹងគិតទៅថាខ្លួន
វាជាសត្វតិរច្ឆាន សន្តានពាល ជាចិត្តវាក៏ទុច្ចរិតឫស្យា ថាបើអញនឹង

ចេញទៅជាញជ័យល្បែង ប្រឡងឫទ្ធា សម្លាប់ជីវិតបាន ក៏គិតមើលទៅដូចហាក់មិនល្អ ជាបើអញនេះទៅតឫទ្ធិនឹងវា ចាញ់ឫទ្ធិ ក៏នឹងអាប់អស់កេរ្តិ៍ឈ្មោះទេវគ្រប់កសីហោង ៗ គិតហើយទើបតបវាទៅថា អញនេះ មិនមានឫទ្ធានុភាពនឹងជាញជ័យ នោះយើងមិនហ៊ានទីនឹងអ្នកទេ បើអ្នកចង់តាំងច្បាំងដូច្នេះ ចូរអ្នកទៅញុំាងការឧបញ្ចពិត ៗ

គ្រានោះ ទូរគីទុច្ចរិតឫស្យាឃើញពួកទេវត្តា ក៏ខ្លាចក្រែងស្ញែងឫទ្ធិ មិនហ៊ានដូច្នោះហើយ ក៏រីករឹងទ្រើសទ្រនង់ក្នុងចិត្ត មិនគិតខ្លាចអំណាចអ្នកណាឡើយ ទើបមហិទ្រាក្រាប់ក្រង់តម្រង់ដើរទៅទៀតហោង ៗ លុះក្រាប់មកដល់បញ្ចគិរីបពិត ក៏ចូលទៅវែកក្នុងថ្មធំ ៗ ក៏បើកបែកខ្ចាយព្រាយក្លីព្រោងដូចផ្កាភ្លើង ហើយក៏ស្រែកទៅថាដោយពាក្យអហង្ការ ពុំមានកោតញញើតឡើយ រុំយនៃ ពួកទេវតាទាំងពួងអើយ ទេវៈណាដែលមានឫទ្ធិបារមីខ្លាំងក្លាហាន ជាងអស់ទេពទេវត្តា ដែលបិតនៅក្នុងព្រៃហិមវា ចូរអ្នកមកតឫទ្ធិនឹងអញដ៏មានឫទ្ធិក្លាហាន ៗ កាលណោះទេវត្តាដែលនៅនឹងគិរី ៥ អង្គនោះ ស្តាប់ពាក្យទូរគីពោលហើយ ក៏ឆ្លើយតបទៅវិញថា វីអាត្មាខ្ញុំនអញទាំងឡាយនេះ ទឹងតាំងច្បាំងនឹងអ្នកពុំបានទេ ឃើញទេវតាដែលនៅក្បែរសមុទ្រនោះ គេមានកម្លាំងឫទ្ធានុភាពក្រៃលើសលុបលោកា អញ្ជើញអ្នកចូលទៅជាញជ័យនឹងគេឯង ឯណោះចុះ យើងចាញ់អ្នកហើយ ៗ នឹងអង្គព្រះសមុទ្រទៅ ទើបនឹងមានឫទ្ធាតទល់

ទឹងអ្នកបាន ។ ថាហើយទេវបុត្រក៏លើកដៃចង្អុលបង្ហាញមាគ៌ា ។ គ្រា
នោះ ទូរគីកំហែងក្លាហានបានស្តាប់វាចាទេវបុត្រតីរប្រាប់ដូច្នោះហើយ ក៏
ហោះទៅដោយកម្លាំងឫទ្ធិហោង ។ លុះដល់ហើយ ក៏ចុះហែលក្នុងមហា
សាគរ មហារលកក៏តាំងរំជួលកវិកវិលបែកពពុះសំពោងក្នុងជលសា ហើយ
ស្រែកប្រកាសទៅថា រុំយ ៗ ពួកទេពទេវ ដែលនៅក្រោមមហាសមុទ្រ
ធំ ល្បីព្រឺទ្ធិមានឫទ្ធិតបះពូកែខ្លាំង ចូលមកច្បាំងនឹងអញឲ្យដឹងគេជាដៃ
ហោង ។ កាលណោះ ព្រះសមុទ្រទេវាធិបតី បានស្តាប់សំដីកំហែង
ទូរគី មានវាចីអួតអាងអំណាចអហង្ការដូច្នោះហើយ ទើបឆ្លើយទៅវិញថា
រីខ្លួនយើងនេះគ្មានឫទ្ធានុភាពទេ យើងនេះសព្វថ្ងៃតាំងចិត្តកាន់ឧបេក្ខា-
ញាណ អ្នកណាហើយនឹងចង់ច្បាំងនឹងអ្នកឲ្យសប្បាយកាយាហឫទ័យ ។
រីខ្លួនអញឯនេះ ចំជាទុច្ចរិតចិត្តឈ្លានពាន មិនដឹងគុណអញសោះឡើយ
ហើយបើអ្នកចង់ជាញជ័យ ចូរអ្នកអញ្ជើញទៅកៃលាសគិរី ៗ កាល
ណោះ កំហែងទូរគី បានស្តាប់ទេវបុត្រសមុទ្ទទេវាថាដូច្នោះហើយ ក៏
ត្រេកអរសោទរក្រៃ មិនគិតខ្លាចអំណាចព្រះបរមលោកា មហាផ្សាក៏ស្ទុះ
ឡើងចាកសមុទ្រគម្ភីរ ដោយកម្លាំងឫទ្ធាពលាកាយរំសាយកន្ទុយ បើក
ត្រចៀក ដើរមកតាមដោយមគ្គមាគ៌ាពនាលីហោង ៗ លុះមកដល់
អរញ្ញបពិតកៃលាស ហើយក៏ឃើញព្រះត្រៃត្រកូវនាថបរមលោកា ក៏ឈប់ឈរ
ហើយពោលវាចាថា ម្នាលព្រះឥសូរជ៏មានឫទ្ធា ខ្ញុំអ្នកជាអគ្គទេវនអ្នក

បង្ក្រាបកបបានដល់ឋានតុសិត ជាធំនៅក្នុងកំឡុងទិសទាំង ១០ ចូរអ្នកមកល្បងរិទ្ធិទឹងអញ ជាអ្នកមានរិទ្ធិសិទ្ធិសក្តា ៗ កាលណោះ ព្រះឥសូរលោកា ព្រះអង្គបានស្តាប់ពាក្យមហាព្រហ្មអហង្ការដូច្នេះហើយ ព្រះបរមលោកា ក៏មានទេវឱង្ការថា យើ ! មើលមើល៍ អាទូរគីកហ៊ានមកអួតអាងកាងក្រពាថាកនេះមានរិទ្ធិក្លាហាន រីព្រោណអាឯងនេះថាមានរិទ្ធិក្លាហានណាស់, នៃអាឯងនេះ ពេញហៅទុច្ចរិតគាក្រក់ក្រៃ ចង្រៃពាលពាលា ហើយអាហ៊ានយកកមកលទឹងចក្រពេជ្រ អាឯងជាកំជាសត្វតិរច្ឆានអប្រិយ សម្លាប់បិតាហើយចង់មកតរិទ្ធិទឹងអញទៀត អាឯងនេះមិនមែន . . . . ហើយមិនសមជាគូដៃទឹងអញទេ, អើ បើអាឯងចង់ច្បាំងណាស់ អាឯងចូរទៅច្បាំងនឹងពាលីជាបុត្រទេវឥន្ទ្រា ឲ្យអាឯងអស់ជីវិតដោយរិទ្ធិញាណពានរ នៅនគរខិតខិនបុរីឯណោះ បើអាឯងស្លាប់ទៅហើយ ចូរអាឯងទៅកើតជាកូនពញាខរ ឈ្មោះមុន្ទកេណ្ឌ ដ៏មានរិទ្ធិពូកែ តែឯងនេះមុខជាស្លាប់នឹងសរជ័យនឹងដៃនារាយណ៍បែងភាគ ចុះទៅនោះហោង ៗ គ្រានោះទូរគីរិទ្ធិក្លាហាននោះ លុះត្រូវពាក្យបណ្តាសាព្រះឥសូរធិបតីយុខគ្រប់ តិបណ្តាលចិត្តនោះមោហាទោសោ ឆ្អេវឆ្អើងក៏យកស្នែងវែងដល់គិរីកៃលាសបន្តិចហើយ ក៏សម្តែងរិទ្ធិញាប់ញ័រកក្រើកដី ស្រេចហើយយុខគ្រប់ ក៏ត្រឡប់វិលមកក្នុងព្រៃពពនាលី តម្រង់ទៅគាទីបុរីខិតខិននគរ ៗ លុះដល់ហើយ ទូរគីនោះ ក៏ចូលទៅវែងស្នួន

ទព្វានរបស់ក្រុងពាលី រលំរលើងបាក់បែកដើមវិនាស មិនតែប៉ុណ្ណោះ
ក៏ដេញដល់ពួកពានរវេវរ៉ក ។

គ្រានោះ វេបណ្ដាពួកពលពានរតូចធំនោះ ឃើញមហិង្សាដេញផល់
វឹកវរ ក៏ភ័យភិតតក់ស្លុតរន្ធត់កល់គ្នា មិនមានពលណាហ៊ានតដៃ ក៏ភ័យ
នាំគ្នាខ្លាចខ្ចួនញ័រជើងដៃ ហើយក៏ស្រែកហៅគ្នីគ្នាជាកោលាហល ខ្លះក៏
រត់ជួលស្រងល់ទល់ប្អូកនៅប្អះ ។ ខ្លះក៏ចំរត់គេចវេះទៅ គ្រឡប់គ្រឡិន
កិងប៉ះគ្នាទៅវិញទៅមក ៗ

កាលណោះ កំហែងទូរគីនោះ លុះឃើញពួកពលស្វាមិនហ៊ានតដៃ
ឡើយ ហើយក៏ស្ទុះដើរមកដល់មុខព្រះលានជ័យហោង ៗ ហើយក៏
ស្រែកហៅថា រ៉ឺយ! ពានរខ្ទួជាចៅមឿងខិតខិនបុរី ល្បីព្ទថាមានឫទ្ធិពូកែ
វិសេស ដ្បិតអង្គអញគ្មានមុខអ្នកណាហើយអាចក្លាហានហ៊ានចូលជាញ
ជ័យតដៃនឹងអញ ។ រីអង្គអញនេះ ទីលំនៅអញសំណាក់ ក្នុងទីពនាលី
ហិមពាន្តមានប្ញគ្គាក្លាហានណាស់ អស់ពួកទេវរុក្ខទេព្រ័ក្ស ព្រមទាំងចក្រ-
ពត្យមិនហ៊ានតបេស្តាអានុភាពនឹងអញបានឡើយ ហើយបើឯងពូកែមាន
ឫទ្ធិវិសេសជាចំបង ចូលមកប្រឡងល្បងឫទ្ធានឹងគ្នា ឲ្យឃើញគេជដៃក្នុង
គ្រានេះ, អម្បាលតែព្រះឥស្សរេមតីរ៍ ក៏មិនហ៊ានតឫទ្ធិបេស្តានឹង
អញឡើយ ៗ

(នៅមានត)

# ឯកសារ សាស្ត្រាស្លឹករឹត និង ក្រាំង

*ដែលមាននៅវិជ្ជាឋាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( ក )

បំណងជើង " សាស្ត្រា សុភទ្ទជាដ "

អ្នកនិពន្ធ ព្រហ្មបរិកត្តិ ឬ បរិកត្តិ "ព្រហ្ម" ។

កាលបរិច្ឆេទ ថ្ងៃអាទិត្យ ៨ រោច ខែស្រាពណ៍ ឆ្នាំចអដ្ឋស័ក
ព.ស. ២៤២៩ ច.ស. ១២៤៨ ( គ.ស.
១៨៨៦ ) ។

របៀបនិពន្ធ ពាក្យកាព្យ ( បទកាកគតិ – ពំនោល – ព្រហ្មគីតិ
– កុជន្តលីលា ) ។

ប្រភេទរឿង ហាសិបជាតក៍ ឬ បញ្ញាសជាតក ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ៨ ខ្សែចប់ ជុំជាតក៍ ។
ខ្សែទី ១ មានសន្លឹក ៣៣, ទី ២ មានសន្លឹក ៣៤,
ទី ៣ មានសន្លឹក ៣៤, ទី ៤ មានសន្លឹក ៣៦,
ទី ៥ មានសន្លឹក ៣៤, ទី ៦ មានសន្លឹក ៣៦,

ទី ៧ មានសន្លឹក ៣៦ ទី ៨ មានសន្លឹក ៣៨ ។

បូករួម ២៨១ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានច្បាប់ដើមអំពី វត្តហារ ខេត្តកណ្តាល យកមកចារ ចម្លងកាលពី ព.ស. ២៤៨៦ ចុះលេខសាស្ត្រា ១៣៦៩ ។

អត្ថបទផ្តើម : កាព្យនៃខ្ញុំ នេះនាមឈ្មោះព្រហ្ម បវរគត្ត គិតកាព្យ និពន្ធ ផ្សិតមានសេចក្តី និពន្ធរឿងនៃ សុគន្ធមេថាងណា ។ មានគុណនិបាត ហៅហាសិបជាតក អតិក្កន្តា កន្ទង់ឆ្ងាយហើយ កាលណោះព្រះមហា ពោធិសត្វ សាងព្រះបារមី ។...

ពុទ្ធសាសនំ អតិក្កន្តំ កន្ទង់ហើយណា ពីរពាន់បួនរយ ម្ភៃប្រាំបួនវស្សា ចុល្លសករាជត្រូវជា មួយពាន់ពីររយ សែសិប ប្រាំបី កាលខ្ញុំគិតនៃ ចងជាកាព្យដោយ អតីតនិពន្ធ មាន មកមិនឲ្យ លើសលស់តាមដោយ សេចក្តីពាក្យកាព្យ ។ រវៃរ ប្រាំបីកេចខែ ស្រាពណ៍នៃឆ្នាំ នក្សត្រអដ្ឋស័ក ដៀងជាក់កាលក កាព្យគិតតាំងត ទុកក្នុងសាសនា...។ល។

អត្ថបទបញ្ចប់ : រីឯព្រះឥន្ទ្រ ហោមហៅទេវិន្ទ្រ នោះឯងតែងមាន គុណ និងពោធិ នោះជាប្រធាន ជាសាវកញាណ អនុរុទ្ធាចារ្យ ។

ឯការជានេយ្យ បេរិលវៃនៃ ជួបជុំជាគា ជាអង្គព្រះធម្មទេសក សាវកសាស្តា សារពេជ្ញញាណញេយ្យ ។ ព្រះជ័យសុរវង្ស អន្ទោលជាតិទ្រង់ សន្សំបារមី ដល់ជុំជាតក៍ខ្ញី ត្រាស់ធម៌ ប្រាំបី ហ្មឺនបួនពាន់ហោង ។ គឺអង្គព្រះពុទ្ធ ប្រសើរវិសុទ្ធ វិសេសគន្ធ ទេសនាទូន្មាន មនុស្សសត្វនោះផង គិតដឹបម្ដង ផាក់ដល់និព្វាន ។ និព្វាននេះស្រេច គិតកាព្យកែគេប លើកខុសក្រែងមាន លោកណាចាំផាក់ សេចក្ដីនិព្វាន ខ្វះខាតក្រែងមាន ជួយតម្រង់ផង ។

+

បំណងជើង " សាស្ត្រា អាចុះអាសាញ់ "

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាយ (បទកាកគតិ - មេណ្ឌាគាគ - ពំនោល - ព្រហ្មគីតិ - កុជង្គលីលា ) ។

ប្រភេទរឿង រឿងព្រេងខ្មែរ

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែចប់ ចំនួនសន្លឹក ២១ ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តស្តៅ
ខេត្តកំពង់ចាម ចុះលេខសាស្ត្រា ៦៨៣ ។

អត្ថបទផ្ដើម : បទកាកគតិ ។ បពិត្រអញខ្ញុំ ហត្ថាបង្គំ ប្រណម្យ សូមពរ សូមមានតេជះ ដូចព្រះរាមា សូមមានប្រាជ្ញា ដូចព្រះមហោសថ ។ ខ្ញុំថ្វាយបង្គំ ព្រះពុទ្ធឧត្តម ប្រាជ្ញមុះមុត កែងនាំសត្វផង ឆ្លងឆ្លងសមុទ្រ សង្សារចំហុត ដាក់ដល់សួគ៌ា . . . ។ល។

អត្ថបទបញ្ចប់ : ទៅសាញ់សោយរាជ្យ មែនមានអំណាច លើព្រះបិតា សឹងតែបានសុខ ឥតទុក្ខភយា ទោះរាស្ត្រប្រជា ឥតមានទុក្ខសោះ ។ ខ្ញុំលក់ទំនិញ ដូចពីមុនមិញ ទិញគ្នាទៅមក អ៊ឹកធឹកក្រៃក្រ រអែករអាក ទិញគ្នាទៅមក រកធីទៅហោង ។ ឥតទុក្ខឥតភ័យ រកចីសព្វថ្ងៃ សប្បាយឥតហ្មង ទៅសាញ់សោយរាជ្យ យូរក្រៃកន្លង តាំងផ្ដើលដល់មួង សឹងសុខឥតក្រែង ។

រីឯពាក្យខ្ញុំ សេចក្ដីសុខុម ផុតប៉ុណ្ណោះឯង នេះតាមទំនង រឿងគេថ្លាថ្លែង តែប៉ុណ្ណោះឯង សូមរួចហើយហោង ។

ចំណងជើង "សាស្ត្រា ទេវន្ត(១)"

អ្នកនិពន្ធ លោក អម្ពុតក្សត្រី "ម៉ុក" (២) ។

កាលបរិច្ឆេទ ថ្ងៃព្រហស្បតិ ៣ កើត ខែអស្សុជ ឆ្នាំមមែ ព.ស. ២៤០២ (គ.ស ១៨៥៩) ។

របៀបនិពន្ធ ពាក្យកាយ (មានតែបទកាកគតិ តែមួយបទ ហូតដល់ចប់) ។

ប្រភពរឿង ហាសិបជាតក៍ ឬ បញ្ញាសជាតក ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ៦ ខ្សែ ចប់ជាតក៍ ។ ខ្សែទី១ មាន ២៩ សន្លឹក ខ្សែទី ២ មាន ៣៦ សន្លឹក ខ្សែទី ៣ មាន ៣៣ សន្លឹក ខ្សែទី៤ មាន២៧ សន្លឹក ខ្សែទី ៥ មាន ៣៤ សន្លឹក ខ្សែទី ៦ មាន ៣២ សន្លឹក ។

---

១– រឿងទេវន្តពាក្យកាព្យនេះ និពន្ធដោយលោក អម្ពុតក្សត្រី "ម៉ុក" ខ្ញុំស្រង់ចម្លងអំពីច្បាប់សាស្ត្រាស្លឹករឹតជាដំបូង កាលពីឆ្នាំ ១៩៤៤ ។ តមកក្នុងឆ្នាំ ១៩៤៧–៤៨ ទើបឃើញមានចុះផ្សាយអត្ថបទនេះ ក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ។

២– កវីនេះ មានគោរម្យងារជា អម្ពុតក្សត្រី នាមដើម "ម៉ុក" បាននិពន្ធរឿងនេះកាលពី ព.ស ២៤០២ ចុងសម័យឧដុង្គ ។ ប្រហែលជាកវីនេះទេដឹង? នៅខាងដើមសម័យដើមក្រុងភ្នំពេញ លោកមានគោរម្យងារជា ឧកញ៉ាសុន្ទរវោហារ "ម៉ុក" ជាកវីមានកិត្តិនាមល្បីល្បាញក្នុងរជ្ជកាលព្រះករុណា ព្រះសុវណ្ណកោដ្ឋ មានមុខងារជា ចាងហ្វាងកឹង ព្រះអាលក្ខណ៍ ដូចខ្ញុំបានសរសេរជីវប្រវត្តិយ៉ាងខ្លី នៅខាងដើមរឿងទេវន្ត ក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ ១៩៤៧ ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពី
វត្តសត្បូរ ខេត្តកណ្តាល យកមកចារចម្លងចុះ
លេខសាស្ត្រា ១៣៨៣ ។

អត្ថបទដើម: បរកាកគតិ ។ អហំវន្ទា អញ្ជលិយា បគ្គយ្ហ សីសបណោ
ពុទ្ធេវិក វិញ្ញាណា ញាណសេដ្ឋា ។ អហំនមោ នមស្សត្ថា
ធម្មគុណោ សង្ឃគុណំ អហំនមោ នមស្សមានោ វត្តខ្វាំ ។ ...
សកពជគ្រប់គ្រាន់ បួនរយពីរពាន់ ទិងពីរវស្សា គន់គិត
គ្រគាន់ បច្ចុប្បន្នសាសនា មមែងឡា អស្សជមាស ។
សុក្កប្បក្ខ តេរសិ គរុវារ បីកើតគត់ច្បាស់ ព្រហស្បតិ៍
កិរកាលអដ្ឋ-សូរសមសត្ថា ។ល។ . . .

អត្ថបទបញ្ចប់: ទៅនូវនិព្វាន នរុត្តមោ វិសេសក្រៃក្រាន ក្រៃក្រុល
ប្រាជ្ញប្រុះ វិញ្ញាញយ្យញាណ ពុំគិតក្រក្សាន្ត ព្រះថេរជាឲ ។
គឺអដ្ឋព្រះពុទ្ធ ប្រពៃបរិសុទ្ធ ខ្ញុំតាំងកពោត្រៃ ស្មោះស្មើរនេស
វិសេសថ្លាថ្លៃ គ្រូគ្រប់សុបណ្ណៃ សុបណ្ណនាគារ ។ តាំង
កុម្ភណ្ឌយក្ខ មនុស្សទេពសិងពាក់ សឹងពីងបេក្ខា បញ្ចូង
ប្រតិស្ឋ នមស្សការ លុះត្រៃសរណា សរណគមគាប់ ។
វរទេវឥន្ទ្រា គឺជាជាតកោ ទិដ្ឋិតំថែងចប់ ដោយគាព្យកបកិច្ច
សេចក្រៃលុះសព្វ បរិបូណ៌គ្រាន់គ្រប់ ប្រការម្ល៉េះហោង ។

( នៅមានត )

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង្វ · គាន ជ

ប្រែ · រៀបរៀង

( ៩ )

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ   អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលចំណាន   ទាំងមានសន្តានស្នេហាជាតិ
>
> — យូរ—អ៊ុន —

លុះនាយទាហានជាបំរើ កាន់តម្រាស់ចូលទៅហើយ ក៏អង្គុយព្រងើយធ្វើបែបមិនដឹងខ្លួន គ្មានគំនាប់តាមគួរសមសោះ, តេងអ៊ីក៏និយាយនឹងអ្នកកាន់សំបុត្រតម្រាស់នោះថា កាលគ្រាព្រះចៅវុយអង់គង់ព្រះជន្មនៅ បានតាំងចៅហ្វាយយើងឲ្យធ្វើធំហើយ តែព្រោះមានមនុស្សញុះញង់ ទើបកើតជារឿងហេតុមកដល់សព្វថ្ងៃនេះ, ឥឡូវព្រះចៅវុយអង់ ទើបតែនឹងសុគតមិនទាន់បានប៉ុន្មានថ្ងៃ ស្រាប់តែមានតម្រាស់មកកាត់ទោសបងប្អូនឯង ៗ តេងអ៊ីថា ចៅហ្វាយស្រុកយើងនេះ មានសតិបញ្ញាឆ្លៀវឆ្លាត ឥតរកនរណាស្មើគ្មាន គួរតែបានធ្វើធំជំនួសបិតា តែមានមនុស្សញុះញង់បានជាមិនបានវិញ ។ •

ឯចូស៊ុត ក៏បង្គាប់ទាហាន ឲ្យទាក់កបំរើកាន់គ្រាបង្គាប់នោះឲ្យជាប់ ហើយឲ្យយកដំបងដេញវាយបំរើនោះឲ្យចេញទៅ, បំរើនោះ ក៏វិលទៅ

ទូលចៅភីតាមដំណើរ ៗ ចៅភីខឹងណាស់ ទើបប្រើចៅធូឲ្យនាំទាហាន ៣.០០០ លើកប្រញាប់ទៅដល់ស្រុកលិមឈី ៗ ឯពួកទាហានដែលយាមទ្វារស្រុកលិមឈី មិនព្រមបើកទ្វារឲ្យចៅធូចូលទៅ, ចៅធូក៏សម្លាប់ទាហានយាមទ្វារនោះស្លាប់ លើកកងទ័ពចូលទៅដល់លំនៅចៅស៊ុត ឃើញចៅស៊ុតនឹងកេងជី កេងអ៊ុ កំពុងផឹកស្រាស្រវឹងដេកទាំងអស់គ្នា ចៅធូក៏ឲ្យទាហានចាប់ចងទាំងខ្លួនដាក់លើរទេះទាំង ៣ នាក់ ហើយបង្គាប់ទាហានឲ្យចាប់យកភរិយាបុត្របាវព្រាវក្នុងផ្ទះចៅស៊ុត, លុះទៅដល់ស្រុកផៀបកុនហើយ ក៏នាំខ្លួនចៅស៊ុតនឹងកេងជី កេងអ៊ុ ចូលទៅថ្វាយចៅភី ៗ ក៏បង្គាប់ឲ្យយកខ្លួនកេងជី កេងអ៊ុ ទៅប្រហារជីវិតបង់ ហើយឲ្យយកចៅស៊ុតទៅដាក់គុកទុក ៗ មាតាចៅភីដឹងដំណឹងថា ចៅហ៊ុមចង់ស្លាប់ទៅហើយ ឥឡូវចៅភីចាប់ចងខ្លួនចៅស៊ុតមកសម្លាប់ទាំងសគ្រប់ក្ខពួកពេញទៀត, ឯខ្លួនចៅស៊ុតឲ្យដាក់គុកទុកដូច្នោះ, មាតាក៏សោកាពិលាបអាណិតកូនណាស់ ហើយឲ្យហៅចៅភីចូលទៅ, ចៅភីក៏ក្រាបសំពះមាតា ៗ ទួញយំអង្វរកូនសុំទោសថា ប្អូនប្រុសរបស់ចៅម្នាក់នេះ វែងចូលចិត្តផឹកស្រា រាអួតថាខ្លួនវាល្អត្រឹមត្រូវ វេលានេះជីវិតម្តាយនៅរស់ នៅឲ្យកូនយល់មុខម្តាយម្តងចុះ ព្រោះវាជាប្អូនប្រុសរួមឧទរជាមួយគ្នានឹងកូន ៗ កុំសម្លាប់វាឡើយ បើចៅទុកជីវិតវាហើយ ទោះបីម៉ែស្លាប់ក៏ធ្មេចភ្នែកជិតទៅបាន ៗ

ចៅភីជំរាបមាតាថា ប្អូនខ្ញុំបាទនេះ វាជាអ្នកខ្ជៀវខ្ជាតណាស់ ខ្ញុំបាទ

គឺមានចិត្តស្រឡាញ់វាប្រាកដ ដែលខ្ញុំបាទធ្វើទោសវាយ៉ាងនេះ ប្រយោជន៍ពង់តាល កុំឲ្យវាធ្វើអាក្រក់តទៅមុខទៀត ខ្ញុំបាទមិនមែនចង់សម្លាប់វាទេ អ្នកម្ដាយកុំព្រួយបារម្ភឡើយ ។ មាតាពុកខូចជាដូច្នោះហើយ ក៏មានអំណរណាស់ ត្រឡប់ចូលទៅក្នុងវិញ, ចូកីក៏ត្រឡប់ទៅកាន់ទីនិយាយការ ហើយឲ្យយកខ្លួនចូស៊ុតចេញទៅសួរ, ហ៊ូហ៊ុមក៏ចូលសួរចូកីថា មាតាទ្រង់បានសុំទោសចូស៊ុតថា ចូកីប្រាប់ថាមាតាខ្ញុំសុំទោសចូស៊ុត ខ្ញុំលើកជូនទៅហើយ, ហ៊ូហ៊ុមថា ចូស៊ុតនោះ ជាមនុស្សប៉ុនប្រសប់ណាស់ បើទុកជីវិតទៅមិនបានទេ ក្រែងយូរទៅនឹងកើតអន្តរាយ ។ ចូកីថា ទឹងទទឹងប្រសាសន៍មាតាម្ដេចបាន ។ ហ៊ូហ៊ុមថា ទូលបង្គំបានឮគេនិយាយល្បីថា, ចូស៊ុតនោះចេះតែងឃ្លោងបំណាច់ណាស់ សូមទ្រង់ឲ្យហៅខ្លួនមកតែងឃ្លោងល្បងមើល បើចេះល្អមែន ក៏មិនគួរនឹងសម្លាប់ទេ ។ ចូកីក៏ឲ្យហៅខ្លួនចូស៊ុតចូលមក, ចូស៊ុតភ័យណាស់ ចូលទៅដល់ហើយ ក៏ក្រាបសំពះបងអង្វរសុំទោស ។

ចូកីថា បងនឹងចៅឯងជាបងប្អូននឹងគ្នាពោះមួយ ឥឡូវបងបានជាម្ចាស់ផែនដីហើយ គឺជំនួសបិតាយើង, បណ្ដានាម៉ឺនមុខមន្ត្រីធំ - តូចក៏គោរពខ្លាចបងទាំងអស់, ហេតុអ្វីចៅឯងមិនក្រែងខ្លាចយើងបន្តិចសោះ, កាលបិតានៅរស់ តែងប្រើចៅឲ្យតែងឃ្លោងស្ដាប់, បងនៅសង្ស័យថាក្រែងអ្នកដទៃធ្វើឲ្យចៅទេដឹង ? បើធ្វើបានមែនពិត ត្រូវដើរចេញទៅ

៧ ដំហាន ហើយថាពាក្យឃ្លោងឲ្យបានសេចក្តី ឲ្យបងស្តាប់ល្បងមើល ត្រូវពណ៌នាពីយើងបងប្អូន តែត្រូវឲ្យយកសេចក្តីដទៃមកប្រៀបក្នុងបងប្អូនយើង កុំឲ្យចេញឈ្មោះបងប្អូន, បើធ្វើបាន បងនិងលើកទោសហោល បើធ្វើមិនបាន បងនិងចុះទោសប្រហារជីវិត ។ ចូស៊ុតថា សូមទ្រង់ឲ្យហាមកុំឲ្យឮមាត់មនុស្សទាំងពួងនិយាយគ្នារំខានស្តាប់ចុះ ហើយដើរគិតថាពាក្យឃ្លោងនោះថាឲ្យល្មមតែ ៧ ដំហានឲ្យចប់សេចក្តី ។

ក្នុងសេចក្តីនោះថា :

"ទឹកលីងសណ្តែកនៅក្នុងឆ្នាំង ត្រូវដុតភ្លើងខ្លាំងតាំងឲ្យស៊ុស
យកទងសណ្តែកដុតធ្វើអុស គ្រាប់លីងឆ្អិនស្រុសព្រោះទងវា ។
ដើម ទង និង ឫសដុះជាគ្រាប់ កើតជាប់ជាមួយដោយពូជជា
ភ្លើងឆេះព្រោះទងឆាងផុតគ្នា ធ្វើឲ្យគ្រាប់វាឆ្អិនខ្លោចទៅ" ។

ចូគីបានស្តាប់ឃ្លោងដូច្នេះ ក៏នឹករឭកដល់សេចក្តីស្រឡាញ់បងប្អូនដែលជាប់ជាតិលោហិតជាមួយគ្នា ឲ្យបង្កើតសេចក្តីខ្សឹកខ្សួល អាណិតមេត្តា ក៏សោកាពិលាប មាតាក៏ទូលដើរមកឮ ទើបមកនិយាយថា ចៅជាបងគេ ហេតុម្តេចមកធ្វើញាំញី ឲ្យប្អូនបានសេចក្តីទុក្ខលំបាកក្តៅក្រហាយដូច្នេះ ? ចូគីបានឮមាតាថាដូច្នេះ ក៏ក្រោកឡើងគំនាប់ហើយជំពបថា នេះឯងជាទំនៀមផែនដីនៃអ្នកធំ បើឃើញថា អ្នកឯណាធ្វើខុសហើយ ក៏ត្រូវតែធ្វើទោសតាមទោសានុទោស បើមានសេចក្តីយោក

យល់ត្រាប្រណី ច្បាប់ផែនដីក៏ទីងសាបរលាបខុសអំពីបុរាណកាលប្រវេណី ទៅ ហើយចូក៏ចាត់ឲ្យចូស៊ិតទៅឈររក្សាស្រុកអានហៀង ជាចុងស្រុក ឆ្ងាយពីទីក្រុងចេញទៅ, ចូស៊ិតក៏ព្រមទទួលបង្គាប់ គំនាប់លាចេញទៅ នៅអានហៀង, ឯចូក៏កំកើងយសខ្ពស់លើសជានបិតា ប្រើអាការសង្កត់ សង្កិនព្រះចៅហៀនគេ លើសជាងអំណាចចូចូ មួយសារទៅទៀត ។ សម័យនោះ មានមនុស្សដែលស៊ើបការណ៍ នាំយកអាថ៌ពត៌មានទៅទូល ព្រះចៅឡេវតី ឯស្រុកសែឈួន ។

ព្រះចៅឡេវតី លុះទ្រង់ជ្រាបនូវព្រឹត្តិការណ៍សព្វប្រការដូច្នោះ ក៏ព្រួយព្រះទ័យណាស់ ត្រាស់ឲ្យប្រជុំអស់នាម៉ឺនមុខមន្ត្រី ដែលជាទីប្រឹក្សាទាំងពួងមកព្រមហើយថា ចូចូស្លាប់ទៅ ឥឡូវបានចូក៏ជាកូនឈរនិយាយការជំនួស ហើយចេះតែសង្កត់សង្កិនព្រះចៅហៀនគេ លើសជាងចូចូទៅទៀត ឯចំណែកខាងស៊ុនគួន ក៏បន្ទាបខ្លួនទៅចំណុះចុះចូលធ្វើជាខ្ញុំចូក៏ហើយ, វេលានេះ យើងគិតទីងចង់លើកទ័ពទៅច្បាំងយកស្រុកកាំងតាំង សង់សឹកគួនអ៊ួឲ្យបានរួចសឹមទន្ទ្រានលើកទៅវាយកំចាត់អាសត្រូវពជសម្បត្តិកុងផែនដីទាំងអម្បាលនេះ ឲ្យរាបទាបឲ្យបានទៀត លៀវហ៊្វ បានឮដូច្នោះក៏យំ ហើយទូលថា គួនអ៊ូ, គួនប៉េង ស្លាប់បង់ត្រានេះ ក៏ព្រោះតែឡេវហាង និង ប៉េងតាត់ មិនលើកទ័ពទៅជួយ ឯ២នាក់នេះ មានទោសដល់ស្លាប់ គួរតែទ្រង់ទីងសម្លាប់ចេញទើបត្រូវ

ព្រះចៅឡៅតីយល់ឃើញត្រូវ ក៏ឲ្យទៅយកខ្លួនឡៅហាង និង បេងគាត់ មកដើម្បីសម្លាប់ចេញ ។

ខុងបេង ឮដូច្នោះ ក៏ទូលតវ៉ាឃាត់ថា សូមឲ្យទ្រង់បង្អង់ឈប់សិនបុះ។ ព្រោះយើងគិតធ្វើការសង្គ្រាមជាធំណាស់ និងស្រួតរូតធ្វើការប៉ុណ្ណោះ ក្រែងឡៅហាង, បេងគាត់ និង ទៅផាសត្រូវឡើង, សូមទ្រង់តាំងឲ្យអ្នកទាំង ២ នេះញែកគ្នាចេញទៅឈររក្សាស្រុកម្នាក់ស្រុក១ របស់ម៉េយើងធ្វើការជាក្រោយឲ្យបានស្រួល ។ ព្រះចៅឡៅតីយល់ឃើញត្រូវ ទើបបាត់ឲ្យនាំត្រាតាំង ទៅតាំងឡៅហាងជាចៅហ្វាយស្រុកចិតុក តាំងបេងគាត់ជាចៅហ្វាយស្រុកយុង ។

ឯផែអៀវ ជាពួកប័ក្ខ ត្រូវអធ្យាស្រ័យគ្នា និងបេងគាត់ កំពុងគាល់ព្រះចៅឡៅតីនៅទីនោះ លុះឮព្រះរាជតម្រាស់ ដូច្នោះ ក៏លបធ្វើសំបុត្របាត់បម្រើជាសម្ងាត់ទៅប្រាប់បេងគាត់ឲ្យដឹងខ្លួន, បម្រើក៏កាន់សំបុត្រចេញទៅតាមផ្លូវទក្សិណស្រុកសៃឈួន ។

ម៉ាឈៀវ ទៅគយល្បាតចាប់បានបម្រើរបស់ផែអៀវ បានឃើញមានសំបុត្រ ក៏ស្រាយយកទៅមើល ដឹងសេចក្ដីនោះហើយ ម៉ាឈៀវក៏ទៅជួបនឹងផែអៀវក្នុងផ្ទះ, ផែអៀវក៏ឲ្យរៀបតុលៀងអាហារ ផឹកស្រាជាកកាលណា ម៉ាឈៀវក៏ល្បងសួរយកការណ៍ថា អ្នកជាមនុស្សមានសតិបញ្ញា ពីដើមមកព្រះចៅឡៅតីបានជប់លៀងអ្នកច្រើនណាស់ មក

ដល់សម័យនេះ ខ្ញុំឃើញមិនដូចពីដើម ដូចជាគ្មានសេចក្ដីប្រោសប្រាណអ្វីសោះ ។

ផៃអៀវ ស្រងឹងស្រងោខ្លាំងណាស់ឆ្លើយថា ការឡៅពីកញ្ញាស់នេះ ពីជាមនុស្សត្រឡប់ត្រឡិន មិនដឹងខ្លួនត្រង់ណាសោះ បើកាលណាមានឱកាស ខ្ញុំនឹងសងសឹកពុំបាន ។ ម៉ាឈៀវក៏ឆ្លងថា ខ្លួនខ្ញុំក៏មានសេចក្ដីគាន់គ្នាញ់ក្នុងចិត្តមកជាយូរណាស់ហើយដែរ ។ ផៃអៀវបានឮដូច្នោះ ក៏ឆ្លើយថា បើដូច្នោះ ចូរអ្នកលើកទាហានរបស់អ្នកទៅតិតគ្នានឹងបេងគាត់ឲ្យរាយចូលមកចុះ ខ្លួនខ្ញុំនឹងទាហានរបស់ខ្ញុំ នឹងចាំរះតិតធ្វើកលខាងក្នុង មុខជានឹងកើតការដោយស្រួលមិនខាន ។ ម៉ាឈៀវថា អ្នកគិតការយ៉ាងនេះស្រួលណាស់ ចាំថ្ងៃក្រោយយើងនឹងប្រឹក្សាគ្នាទៀត នឹងបានសងសឹកតាមគំនិតយើងគិត និយាយគ្នាហើយ ម៉ាឈៀវក៏លាចេញទៅ ហើយយកមនុស្សបំរើផៃអៀវ និងសំបុត្រគាងនោះ ចូលទៅថ្វាយព្រះចៅឡៅពី ហើយចូលទៅខ្សឹបទូលសេចក្ដីតាមសំដីដែលផៃអៀវនិយាយនឹងខ្លួននោះ ថ្វាយព្រះចៅឡៅពីទ្រង់ព្រះសណ្ដាប់, ព្រះចៅឡៅពីទ្រង់ខ្ញាល់ខ្លាំងណាស់ ត្រាស់បង្គាប់ឲ្យទៅចាប់ខ្លួនផៃអៀវ មកពាយពីតារណាសួរយកចម្លើយ, នោះផៃអៀវក៏ឆ្លើយទទួលតាមសត្យ ហើយក៏ត្រាស់បង្គាប់ឲ្យយកខ្លួនផៃអៀវទៅដាក់គុក ។ ព្រះចៅឡៅពី ក៏ទ្រង់ប្រឹក្សានឹងខុងបេងថា ផៃអៀវពាក់តក្យត់នឹង

យើងដូច្នេះហើយ បើយើងនឹងចិញ្ចឹមរក្សាទុកក៏ពុំបាន ប្អូននឹងគិតប្រការម្តេច ?

ខ្ញុំបងទូលថា: អាផែអៀវនេះ វាជាមនុស្សព្រាលចំកួតសោះ បើនឹងចិញ្ចឹមរក្សាទុកក៏ពុំបាន គង់មានពេលទៅថ្ងៃមុខ ៗ ជានឹងប្រទុស-កាយយើងវិញពុំខាន ។ ព្រះចៅឡៅតីក៏ត្រាស់ឲ្យដាក់គុកផែអៀវទុកឲ្យស្លាប់ក្នុងគុកនោះ, ឯការនោះមិនស្ងាត់ មានមនុស្សនាំដំណឹងទៅប្រាប់បងគាត់ ៗ ដឹងដូច្នោះក៏ភ័យខ្លាំងណាស់ ព្រោះដឹងថាខ្លួនមានទោសខុសមកស្រាប់ផង ថែមទាំងឃើញត្រាតាំងបំបែកឡៅហាំងទៅឈរស្រុកប៉ីតុក ឯខ្លួនឯងក៏ពាល់គំនិត ព្រោះឥតមានទីប្រឹក្សាការសោះ ទើបឲ្យអញ្ជើញ សិន-គាំ ជានាយទាហាយធំក្នុងស្រុកស៊ុងយ៉ុង ហើយនឹងស៊ុន-ងី ជានាយទាហានទៅស្រុកហង់ឡុង, ទាំង ២ នាក់នេះ បងប្អូននឹងគ្នា ត្រូវអធ្យាស្រ័យគ្នានឹងបងគាត់ លុះនាយទាហានទាំង ២ មកដល់ហើយ បងគាត់និយាយថា ហ្លួងបងនឹងខ្ញុំ បានធ្វើសេចក្តីគាប់ប្រសើរទុកដល់ព្រះចៅឡៅតីមកពីថ្ងៃមុនច្រើនណាស់; វេលានេះ ហ្លួងបងក៏ស្លាប់ទៅហើយ ឡៅតីភ្លេចអស់សេចក្តីគាប់ប្រសើរនោះ ត្រឡប់គិតប្រទូសកាយខ្ញុំវិញ ខ្ញុំមិនដឹងនឹងគិតគំនិតយ៉ាងណា ទើបនឹងបានឲ្យរួចពីសេចក្តីស្លាប់នោះបាន ។

(នៅមានត)

# ឯកសារ កម្ពុជសុរិយា

(គ)

លោក ឌឹក-គាម ប្រមូលរៀបរៀង

សាស្ត្រាចចក : ទ.ក. ១១, ទំព័រ ១០៦៩, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

សិប្បកថា : ព្រះឧបាលិវង្ស មីង-សែស ទ.ក. ៩, ទំព័រ ៨៧៤, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។ ទ ក ៨, ទំព័រ ៥៦៣, ឆ្នាំ ១៩៥៥, (ម.៥២/១៧) ។

សិពជាតក : លោកមហា ប៉ុណ្ណ-សម្កាជ ទ.ក. ១១, ទំព័រ ៥៩៩, ឆ្នាំ ១៩៤៦, (ម ៥២/១៨) ។

សិរីវិបុលកិត្តិជាតក : ព្រះឧត្តមមុនី អ៊ុំ ស៊ូ ទ.ក. ១-៦, ទំព័រ ៩៤, ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

សិល្បៈនៃអតីតព្រះរាជអាណាចក្រខ្មែរ : លោក ក៉យ-ប៊ុក ទ.ក. ៧, ទំព័រ ៦៥៤ ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សិល្បៈពុទ្ធសាសនា : ព្រះឧបាលិវង្ស សូ-ហាយ ទ.ក. ៥, ទំព័រ ៤១១, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

សិល្បរបាំ : ឆេង-ជ្រើ ទ.ក. ៨, ទំព័រ ៨៤៧, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

សិលាចារឹកជ័យ-ធន្នូ : លោក ឌឹក-គាម ទ.ក. ៥, ទំព័រ ៥១៥ ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

សិលាចារឹកត្រពាំងរុង : លោក ឌឹក-គាម ទ.ក. ៨, ទំព័រ ៨៣២, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

សិលាចារឹកនគរវត្ត : ព្រះមហាពិទូរក្រសេម ទ.ក. ៤-៥-៦, ទំព័រ ៣, ឆ្នាំ ១៩៣៨, (ម.៥២/១០) ។

សិលាចារឹកប្រាសាទវិមានអាកាស : ព្រះភិក្ខុ ប៉ាង-ខាត់ ទ.ក. ៨, ទំព័រ ៨១៥, ឆ្នាំ ១៩៦២, (ម.៥២/៣៤) ។

សិលាចារឹកភ្នំជីសូរ : លោក ឌឹក-គាម ទ.ក. ១១, ទំព័រ ១១៩៤ (ម.៥២/៣៦) ។

សិលាចារឹកស៊ីម៉ង់រឿងព្រះពុទ្ធសាសនា : ទ.ក. ១-២-៣ ទំព័រ ១៣, ឆ្នាំ ១៩៣៧, (ម.៥២/៣២) ។

សីលធម៌ : ឃុនបណ្ណាទុរក្ស ប៊ូ-ប៊ូ ទ.ក. ១, ទំព័រ ២២, ឆ្នាំ ១៩៥៥ (ម.៥២/២៧) ។

សីលធម៌ និង សិល្បសាស្ត្រ : ឃុនបណ្ណាទុរក្ស ប៊ូ ប៉ូ ទ.ក. ៧ ទំព័រ ៦៣៦, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

សុខកថា : ព្រះមហា ផៃ-មុល ទ.ក. ១១, ទំព័រ ៨១០, ឆ្នាំ ១៩៥២ (ម.៥២/២៤) ។ ព្រះមហា សុខ-ទេ ទ.ក. ៣,

ទំព័រ ១៦៣, ឆ្នាំ ១៩៥៤ (ម.៥២/២៦) ។ ព្រះបាឡាត់ បទុមវ័ន្ត ហ៊ុង-កេង ទ.ក. ៤, ទំព័រ ៣៥៩, ឆ្នាំ ១៩៥៩ (ម៥២/៣១) ។

សុខមូលតាងមិ : ភិក្ខុឧបសេនោ ញ៉ែម-នី ទ.ក. ២, ទំព័រ ១៥៤, ឆ្នាំ ១៩៣៦, (ម.៥២/៣៧) ។

សុខុប្បត្តិមូលគាថា : ព្រះមហា ទៅ-ជា ទ.ក. ៦, ទំព័រ ៥៨៣, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

សុទោទាយគាថា : ព្រះអាចារ្យ ទូច-ឡេង ទ.ក. ២, ទំព័រ ៨៣, ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

សុចរិត និង ទុច្ចរិត (រឿងព្រេងរុស្ស៊ី) : អ្នកស្រី ស-សក ទ.ក. ៨, ទំព័រ ៩០៧, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

សុជាតាជាតក : លោកអាចារ្យ មុញ ណាគ្រី ទ.ក ១១, ទំព័រ ៦៥៧, ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

សុទ្ធិគាថា : ព្រះមហា មូល-អ៊ូ ទ.ក. ៦, ទំព័រ ៥៤៥, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សុខទុក្ខត្តលិង្គមុត្ត : យុទ្ធបណ្ណាធិរក្ស ប៊ូ.ប៉ូ ទ.ក. ១១, ទំព័រ ៨១១, ឆ្នាំ ១៩៤៥ (ម.៥២/២៥) ។

ស៊ុនយ៉ាតសេន អ្នកនយោបាយឯកជាតិចិន : លោក ប៉ាយ ប៊ុក ទ.ក. ១, ទំព័រ ៣៨, ឆ្នាំ ១៩៤៨, (ម.៥២/២០) ។

សុន្ទរកថា : រដ្ឋលេខាធិការក្រសួងធម្មការ ទ.ក. ៩, ទំព័រ ១០៦១ ឆ្នាំ ១៩៦២, (ម.៥២/៣៤) ។

សុន្ទរកថា និង សារលិខិត : លោក ប៉ាយ-ប៊ុក ទ.ក. ៧, ទំព័រ ៦៦៣, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សុន្ទរកថាអំពីដង្ហែព្រះសារីរិកធាតុនៅខេត្តសៀមរាប : លោក សុខ-សាវឿន ទ.ក. ៥, ទំព័រ ៤៦៧, ឆ្នាំ ១៩៤៦ (ម.៥២/៣៦) ។

សុភានឈ្លាយ : ទ.ក. ៤ ៥ ៦, ទំព័រ ២៥៩, ឆ្នាំ ១៩៣៨, (ម.៥២/១០) ។

សុភាសិត : លោកប៉ាយ ប៊ុក ស៊ុរី និង លីបង់ ទ.ក. ១, ទំព័រ ៦៦, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។ យួន-ចិន ទ.ក. ៤, ទំព័រ ៤៤៧, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

សុភាសិត (កាព្យ) : ព្រះគ្រូសុន្ទរវិទូ ពាង-សុខ ទ.ក. ៧, ទំព័រ ៣៣៩, ឆ្នាំ ១៩៤៥ (ម.៥២/១៧) ។

សុភាសិតច្បាប់ស្រី : ឧកញ៉ាសុត្តន្តប្រីជាឥន្ទ ទ.ក. ៤-៥-៦, ទំព័រ ៤៦, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

សុភាសិត ជាតិប៉ុល និង ទូត្យលៀរ : លោក ក៉យ-ប៊ុក ទ.ក. ១, ទំព័រ ៦៥, ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

សុភាសិតចាកំងែស : ទ.ក.៤, ទំព័រ ២៤៣, ឆ្នាំ ១៩៤៨ (ម.៥២/២០) ។

សុភាសិតបាលី (ប្រែកាព្យ) : ព្រះគ្រូសុខុវិទូ ពាង-សុខ ទ.ក. ៤, ទំព័រ ១៨២, ឆ្នាំ ១៩៤៥ (ម.៥២/១៧) ។

សុភាសិតប្រកាបនិធាន : ទ.ក. ១-២-៣, ទំព័រ ១៥៣, ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

សុភាសិតប្រដៅជនប្រុសស្រី : ព្រះឃោសធម្ម ម៉ឹង-សែស ទ.ក.១, ទំព័រ ៥០, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សុភាសិតប្រឌិតរឿង : ព្រះមហា អ៊ឹម-សុខ ទ.ក. ១,២ ទំព័រ ៩១១; ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

សុភាសិតភាគទី ១ : លោក ក៉យ-ប៊ុក ទ.ក. ៣, ទំព័រ ១៨១, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។ ភាគទី ២ ទ.ក. ៧, ទំព័រ ៤៩៧, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។

សុភាសិតនិង ធារកោភន : មហា សៅ-លីវ ទ.ក. ៨, ទំព័រ ៤៣០, ឆ្នាំ ១៩៤៧ (ម.៥២/១៩) ។

សុភាសិតកាដជ័ត (កាព្យ) : អ្នកទុកញាំទៅ ទ.ក. ២, ទំព័រ ១៤៧, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

សុភាសិតណារ : លោក ក៏យ-ប៊ុក ទ.ក. ១១, ទំព័រ ៩៨៣, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សុភាសិតភាជាកាជា : ព្រះគ្រូញាណសំវរ ញាណ-ឈឹម ទ.ក. ១-២-៣, ទំព័រ ៨៣, ឆ្នាំ ១៩៣៨ (ម.៥២/១០) ។

ទ.ក. ១-២-៣, ទំព័រ ១៣១, ឆ្នាំ ១៩៣៨ (ម.៥២/១១) ។

សុភាសិតសាររ៉ែប្បែរ : លោក ក៏យ-ប៊ុក ទ.ក. ៦, ទំព័រ ៥៦០, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

សុភាសិតបាណ្ឌ : លោក ក៏យ.ប៊ុក ទ.ក. ១២, ទំព័រ ១១១៨, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

សុភាសិតអង់គ្លេស : លោក ក៏យ-ប៊ុក ទ.ក. ២, ទំព័រ ៨១, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

សុភាសិតអាពប់ : លោក ក៏យ-ប៊ុក ទ.ក. ៩, ទំព័រ ៨២៣, ឆ្នាំ ១៩៥៧ (ម.៥២/៣០) ។

(នៅមានត)

# ចិត្តមិនព្រមចាស់

និយាយពីចិត្តមិនព្រមចាស់ ចិត្តនេះខូចណាស់ក្រាស់ផុតវេង
សម្ប្រុកក្បួនកុងខ្លួនឯង យកជាទីពឹងអាស្រ័យនៅ ។
ខ្លួនធ្លាក់ក្នុងភ័យវ័យជក ច្រុះក្រោមគ្រាំគ្រាយ៉ាប់យ៉ឺនទៅ
សាច់ស្បែកជ្រួញជ្រីអុរជាតិជៅ ក្អែករូងខ្លួនជ្រៅដូចរន្ធឡូ ។
ធ្មេញបាក់សក់ស្កូវផ្លូវអើទៀត តែចិត្តមានស្នៀតឆ្មៀតកក្បូរ
នៅឆ្មៀតកកាយស្តាយបាយថ្លូ ចង់ណាស់ប្រោះឡួដួចក្មេងក្មាង ។
ខ្ញុំមិននិយាយតាមចិត្តស្រី មិនកើតទៀតអស់ទីអាង
តែស្រីៗ ទឹងប៉ុនគឹងគាង អ៊ីក៉ាទ់ទេងខាងចាក់សោក្រប ។
និយាយតែចិត្តប្រុសគ្នាយើង មិនសូវនាំក្តើងដើងដើរឡើប
កិច្ចការជ្រៅពក់ណាក់លបឡើប ឡុកលេងកេងគឹបគ្នាយើងស្រាប់ ។
ធម្មតាចិត្តប្រុសមានខុសគ្នា មានខូចមានជាក្រៅក្នុងច្បាប់
ប៉ុន្តែរឿង "ចាស់" ចិត្តមិនស្តាប់ លុះតែរូបស្លាប់ទើបអស់ផ្លូវ ។
សមស្រុកសព្វថ្ងៃនេះយ៉ាងណា ផុនតាមប្រាថ្នារឿងសក់ស្កូវ
មានថ្នាំក្រមៅកែតម្រូវ លាបលនលុបផ្លូវខ្មៅរលោង ។
ឡើងទៅរលង់គង់គាពដើម ប្រេងផ្សើមក្រោះផ្សាំយឹតយោង
គោះធ្មេញបាក់ទៀតឆ្មៀតលៃឈោង មានគ្រឿងថែជ្រងជ្រោងគ្រប់សណ្ឋាន ។
ឧបករណ៍ជំនួយជួយវ័យចាស់ មានច្រើនមាកណាស់ផ្លាស់ប្តូរបាន

សម្រាប់គុបតែងលំអប្រាណ ឲ្យតែល្អយមានគ្មានក្រអឺ ៗ
តែទុកជាចិត្តឥតគ្រឿងអាង តាំងប៉ុន្មានយ៉ាងដូចពោលស្តី
ក៏ចិត្តប្រុសយើងក្នុងលោកិយ ឥតបំព្រមបាស់ក្រឡាស់ប្រែ ៗ
មានតាខ្ញុំម្នាក់ជ្រាក់វ័យចាស់ ចិតសិបប្លាយច្បាស់ក៏ប៉ុន្តែ
ក្មេង ៗ ហៅតាជេរជល់ម៉ែ ចួនពិតហួរហែតាមតែថា ៗ
អាចោរខ្មោចក្មេងលេងមើលងាយ តើអញយកយាយឯងកាលណា
ក៏មកហៅអញថា តា-តា អាចោរមោហាប្រយ័ត្នគ្មាន ៗ
ពាក្យសល់ឯទៀតមិនផ្ទៀតហៅ ម៉េចនាំកំដៅអាតែហាង
អាចោរតែហឹតក្រអឹតគាង ក្រោយ ៗ ឯងគាំងជីងឲ្យច្បាស់ ៗ
តាខ្ញុំគាត់វិលវៀងមួយទៀត គាត់ខំប្រឹងផ្ទៀតតែងខ្លួនណាស់
ចូលចិត្តតែលេងល្បែងផ្កាំចាស់ ប្ដូរផ្លាស់គិតតែលៃរៀងហ៊ុង ៗ
មានស្រីខូចវិលគិលគ្រងណា ពោះនៅទីផ្សារប្ដូរក្រៅក្រុង
គាត់ញៀនញឹកញាប់ជាប់ចិត្តស្លុង វិលក្បួងផុងខ្លួនពួនគ្រង់នោះ ៗ
ស្រីវិលឃើញតាពីចម្ងាយ ស្រស់ស្រាយពក់ពាក់ហាក់ចិត្តស្មោះ
ហ៊ៈនុះមកហើយបងកំឡោះ ខ្ញុំអរដូចហោះបានជួបបង ៗ
នាំគ្នាស្ទុះចុះទៅទទួល បបួលគឺគ្នាគ្រាហ៍អែបអង
អួសដាក់លើតូកល្អកកេះខ្នង ផ្សៀងផ្អងផ្ដេកផ្ដិតកិតកៀកកាយ ៗ
ខ្ទះគក់ប្រហាច់កាច់ជើងដៃ ខ្ទះពាប់សរសៃស្ពាបនាយអាយ

បញ្ញោរបញ្ចើចសើចក្អាកក្អាយ តាខ្ញុំសប្បាយត្រើបេះដូង ៗ
យកអីយកទៅពៅបងអើយ ដល់ថ្នាក់ហ្នឹងហើយតាយល់សូង
យល់សប្តិឃើញគាត់ធ្លាក់អណ្ដូង ជ្រោះជ្រៅស្រឡូនខ្ទីក្អែកស៊ីង ៗ
មិនមែនតែតាខ្ញុំមួយទេ ទោះទាំងតាគេរឿងត្រង់ហ្នឹង
យាយដេរម្ដេចក៏មិនខ្ជីទឹង តាប្រឹងលែងព្រួយព្ទួយអស់ដៃ ៗ
គាត់ថាដូចជារបស់ទ្រព្យ កាលណាគាត់ង៉ាប់ជីវិតក្ស័យ
កូនចៅផ្ដុងឲ្យដោយច្រើនក្រៃ ចង្រៃរឿងហ្នឹងផ្ដុងមិនបាន ៗ
ដូច្នេះទើបតាគាត់ខំប្រឹង បំពេញកិច្ចហ្នឹងកុំឲ្យខាន
ទោះអស់សោហ៊ុយលុយប៉ុន្មាន ប្រចុយប្រចានប្រាណផ្ដាំចាស់ ៗ
ចួនកាលតាខ្ញុំជួបមិត្តភក្តិ បើគេភក់ទាក់គាត់ជោរណាស់
ឮពាក្យថា «ឃើ! ម្ដេចក្រចាស់? ដូចជាអត់ផ្លាស់នៅដដែល ៗ
ខានបានជួបគ្នាប៉ុន្មានឆ្នាំ សាច់នេះហៅចាំអាយុក្រែល
តែដូចកំឡោះស្មោះដដែល រកមនុស្សប្រហែលធីនេះក្រ» ៗ
ពាក្យគេបញ្ញោរលើកបញ្ចើច តាខ្ញុំគាត់សើចមាត់ប្រហ
ញញឹមបីថ្ងៃជាប់បន្ត អរអើយសែនអរនេះតាខ្ញុំ ៗ
ឲ្យតែអ្នកណាចេះបញ្ញោរ គុយទាវពោះគោចាយលុយជុំ
បើទៅទីណាមានក្រមុំ ញ៉េះញ៉ោះចេះសុំតាឲ្យម៉ត់ ៗ
ការីមីធាស្រោបផ្អែម ចៅពីតតែក្លែមតាស៊ូអត់

យាយនៅឯផ្ទះធ្វើការហត់ តាខ្ញុំគាត់ក្បត់អត់បានឆ្ងាញ់ ។
កាលយាយខ្ញុំដឹងខឹងប្រឡោក "កញ្ចាស់នៅនោតឯងក្បត់អញ
ឃើញមុខកាលណាផ្សាក្ដៅក្លាញ់ ឲ្យគេបំពញ់ចាញ់បោកគេ ។
ចាស់ឡើងព្រើលឡើងដូចឆៃយ៉ុ ក្មេងនេះបានផ្ដាំចាំប្ដូរទេ ?
មរណៈចូលជិតតែខូចទេ ចាស់ចេកខុសគេចាស់បំភ្លត" ។
តាខ្ញុំខំអត់អំណត់ដែរ ប៉ុន្តែយាយខ្ញុំផ្ដុំរឿងគ្រួត
តាទឹកខឹងខ្លាំងតាំងប្រកួត "មេពោរក្ដិតក្ដួតអួតពូកែ ។
ឃើញអញស្ងៀមឈឺងរឹងរិតណាស់ ខ្មោចមេកញ្ចាស់មិនមែនម៉ែ
គិតអត់មិនបានចាននៅក្បែរ បោកក្បាលបែកបែរចេញឈាមភ័រ" ។
យាយខឹងធ្លូលចេរស្ទើរប្រញាប់ ស្ទុះក្ដិតលេងផ្ទាប់ចាប់កអាវ
កញ្ចាក់បោកក្ដោបធុបក្រសារ តារើចំប្រាវលោតឡើងឆាក់ ។
យាយគេចវេចខ្លួនធួនក្បែរពាង តាដួលចង្ក្រានរាងដូចយក្ស
ស្មារតីយាយរឹងប្រឹងឥតរក់ យាយស្ទុះក្ដិតពាក់ជះលើតា ។
តារើខ្វៃ-ខ្វៃដៃប្រឡេះ យាយប្រឹងកកេះខ្ទេះក្ដិចខ្វារ
តាដួលក្រឡាប់វិលផ្កាប់ផ្ងារ យាយសាក្រឡប់គប់តាម៉ាំង ។
តារើខ្លួនរួចក្ដួចប្ដួងដៃ "ខ្មោចមេចង្រៃចៃបោរខ្លាំង"
តាក្ដិតទៅទៀតធ្ងៀតតតាំង យាយយឹតប្រឆាំងរាំងទទួល ។
តាចាប់យាយបានប្រានគ្រវាត់ ហើយស្ទុះទៅទាត់ក្ដាត់ជើងដួល

យាយមានទំនងវង់យ៉ាងស្រួល ដែលអៀវចាប់មួលពងតាដាប់ ។
តាខ្ញុំខំស្រែកក្អកស្ទោស្ទឹង កុំលេងធមិតឹងមេត្រៅគ្រាប់
ញយ៉ះប៉ះបំកន្ទេងឆាប់ ហាងធ្លាប់ដឹងទេមេចង្រៃ ។
លែងអញឲ្យចាប់ប្រញាប់ក្ទាម តិចអញព្ទួយផ្គាមហាងមួយដៃ
យាយថាកុំបាច់គិតសង្ស័យ បានដៃប៉ុណ្ណោះកេះមិនបាន ។
អញមួលប្រចាប់ផ្ដាច់អាយ៉ូស ឲ្យផុតខ្យល់ស្រូសប្រូសបែកហាន
ឲ្យអស់ពុតខូចដូចតិរច្ឆាន ម៉េចនៅភ្លាហានយ៉ាងណាទៀត ?
តាវ៉ៃយាយតែមឹតមួលខ្ទាំង តាឈប់តតាំងច្បាំងអស់ស្មៀត
វិះ ៗ ដាច់ខ្យល់ខ្វល់ចង្អៀត បែរបៀតសុំចុះចំណុះយាយ ។
រឿងយើងប្រុស ៗ ឈ្មោះទិនស្រី មិនស្រួលទេវ៉ីកុំមើលងាយ
ប្រយ័ត្នប្រយែងស្នែងមួយផ្លាយ កុំទុកពត់កាយយាយលេងម៉ត់ ។
ដំណាលពីចិត្តមិនព្រមចាស់ ពារ៉ែងឆ្ងាយណាស់សរសេរហត់
បែកដល់រឿងតាសង្ហាក្បត់ យាយអៀវសង្កត់តាវិះឆាប់ ។
ខ្ញុំសូមសន្មតកំណត់ស្ទេះ បញ្ចប់ត្រឹមណេះឈប់រៀបពប់
ចាំមានដំណើរប្រសើរគាប់ ទិនវៃលតក្លាប់រឿងទៅទៀត! ។

ញ៉ូច-សឿន

# ជីវប្រវត្តិរបស់ខ្ញុំ

ឈ្មោះ អៀង-សាយ

( ក )

ដោយឃើញសេចក្ដីក្នុងសំបុត្រដូចនេះ ទើបចៅហ្វាយនាយខ្ញុំញញឹម ខ្ញុំក៏ខានញញឹមមិនបាន ដោយលោកដឹងថាខ្ញុំមិនសូវចេះបារាំង ដោយនិយាយបារាំងជាមួយលោកមិនច្បាស់ ម្ដេចក៏គេថា ខ្ញុំចេះអាចកែចាប់ខុសត្រូវបាន ។

ខ្ញុំក៏នឹកហួសចិត្ត ដោយយល់ថា លោកអ្នកដែលបកប្រែសៀវភៅនោះ យ៉ាងអន់ណាស់ក៏ថ្នាក់ឌីប្លូម៉ដែរ ឯខ្លួនខ្ញុំមិនដែលមានឈ្មោះនៅក្នុងថ្នាក់កុមារដ្ឋាននៅសាលាណាសោះ មិនគួរមានកិត្តិយសដល់ទៅជាអ្នកចាប់ខុសគេបានទេ តែដោយចង់បន្ទាក់ ចៅហ្វាយនាយខ្ញុំក៏ឲ្យលោកញញឹមទៀត ខ្ញុំទទួលយកសៀវភៅទាំងពីរទៅ និងជំរាបលោកថា ចាំខ្ញុំយកទៅមើល ក្រែងមានខុសត្រង់ណា ។

ក្រោយពីនោះ ៤ ថ្ងៃមក ខ្ញុំយកសៀវភៅបារាំងនិងសៀវភៅខ្មែរមានក្រដាសគៀតភ្ជាប់គ្នាបួនដប់សន្លឹករបស់ខ្ញុំយកមកជាមួយផង ខ្ញុំបង្ហាញចៅហ្វាយនាយខ្ញុំបានចាំងអានអក្សរខ្មែរ ប្រែជាបារាំង ឲ្យលោកស្ដាប់ផងថា : អៀង-សាយ ខ្ញុំបានមើលពិនិត្យសៀវភៅដែលប្រែពីភាសាបារាំងមកជាខ្មែរនោះ ឃើញល្អមយកជាការបានហើយ តែ

មនុស្សពីរនាក់មិនដែលយល់ស្របគ្នាទាំងអស់ទេ បើគេឲ្យខ្ញុំបកប្រែមានយល់ផ្សេងពីគ្នាដោយអន្លើខ្លះ ដូចខ្ញុំបានសរសេរនៅលើក្រដាស បួនដប់ សន្លឹកនេះ ខ្ញុំកត់លេខទំព័រនិងចំនួនបន្ទាត់ពីលើទៅដល់ត្រង់សេចក្ដីនោះ ហើយខ្ញុំចម្លងសេចក្ដីអក្សរបារាំងដាក់ម្ខាង ខ្ញុំសរសេរបកប្រែជាខ្មែរម្ខាង តាមខ្ញុំយល់ផ្សេងពីលោកអ្នកបកមុន មានតែប៉ុន្មានអន្លើនេះ ។

ទៅហ្វាយនាយខ្ញុំបើកមើលក្រដាសដែលខ្ញុំសរសេរបួនដប់សន្លឹក រួចហៅស្មៀនមកប្រើឲ្យចាត់ការបញ្ជូនត្រឡប់ទៅវិញ ។

ខ្ញុំមិនមែនបង្រៀនតែសិស្សនៅសាលាទេសព្វាហកម្ម, វិទ្យាល័យ-ស៊ីសុវត្ថិ, សាលាគរុវិជ្ជា ប៉ុណ្ណោះទេ ខ្ញុំមានទៅបង្រៀនសិស្សនៅអនុ-វិទ្យាល័យនារី ដែលជាអនុវិទ្យាល័យនរោត្តមសព្វថ្ងៃនេះផងទៀត ដោយគេគិតលៃពេលម៉ោងខាងណេះខាងណោះ ឲ្យល្មមខ្ញុំទៅមកបង្រៀន ១ ម៉ោងក្នុង ១ ថ្នាក់គ្រប់ថ្នាក់ទាំងអស់ ។

បានជាខ្ញុំរត់ទៅណេះទៅណោះខ្វែងជើងយ៉ាងនេះ មកពីគ្មានគ្រូឯទៀតក្រៅពីខ្ញុំ សូមជ្រាបថា តាមកម្មវិធីដែលគេតម្រូវ ឲ្យបង្រៀនសិស្សនៅមធ្យមសិក្សា មានគំនូរទស្សនាការ (ដេស្សាំង អាវ៉ុយ) គំនូរវេចនា (ដេស្សាំងឌឺដេគ័រកាស៊ីយ៉ុង ) គំនូរធរណីមាណសាស្ត្រ (ដេស្សាំងសេអូមេទ្រិក ) និងគំនូរសិប្បយការ (ដេស្សាំងអាំងឌុស-ទ្រីយ៉ែល ) ទាំង ៤ មុខនេះ ។

ពួកសិស្សដែលមានឌីប្លូមចេញពីសាលារចនាមក ចេះតែគំនូរពីរមុខខាងដើម មិនចេះគំនូរពីរមុខទៀត ទៅធ្វើជាគ្រូបង្រៀនមិនបាន ។

បើឲ្យសិស្សដែលមានសញ្ញាបត្រចេញពីសាលាបច្ចេកទេសមកធ្វើគ្រូ ចេះតែពីគំនូរពីរមុខខាងចុង គំនូរពីរមុខខាងដើមមិនចេះបង្រៀនវាមិនកើតទៀត ទើបបានជាខ្ញុំធ្វើការដល់កំណត់ឆ្នាំ ដល់អាយុគេមិនទាន់ឲ្យនិវត្ត ទៅធ្វើការហួសកំណត់ឆ្នាំនោះមក ៧ ឆ្នាំទៀត ទើបបានឈប់ ឈប់ហើយ ទៅសាលារចនាដែលឡើងជាមហាវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ខ្វះគ្រូដែលចេះគំនូរធរណីមាណសាស្ត្រ គេដឹងថាខ្ញុំចេះ គេហៅឲ្យទៅបង្រៀន ឲ្យឈ្នួលគិតតាមម៉ោងទៅទៀត ។

ខ្ញុំសរសេរភ្លេចមុខភ្លេចក្រោយ ដោយមិនបានព្រាង នឹកឃើញត្រង់ណាសរសេរត្រង់ហ្នឹង ខ្ញុំត្រូវសរសេររឿង ១ ថែមឲ្យស៊ីសេចក្តីខាងដើម តែមិនមែនចង់ធ្វើឲ្យដូចពាក្យហោរឬពាក្យគ្រូទាយនោះទេ គឺខ្ញុំជ្រុលខ្លួនហួសទៅហើយ ទើបនឹកឃើញពាក្យហោរដែលទាយថា ខ្ញុំត្រូវមានប្រពន្ធដល់ទៅបីនោះជាក្រោយ គឺជាព្រហ្មលិខិតរបស់ខ្ញុំយ៉ាងនេះ ។

ខ្ញុំចាស់អាយុ ៥៨ ឆ្នាំទៅហើយ មានកូន ៤ ចៅ ១៧ នាក់ ខ្ញុំឃើញស្រីម្នាក់អាយុ ១៤ ឬ ១៥ ឆ្នាំ នៅស៊ីឈ្នួលបំរើគេ ដោយខ្ញុំធ្លាប់ខិលខូចនឹងស្រី តាំងពីក្មេងរៀងរាបមក លះបង់ចោលល្បែងនេះមិនបាន តាំងល្បែងបរបាញ់សត្វក៏ខ្ញុំធ្លាប់លេង ដោយមានកាំភ្លើងបាញ់សត្វ

ដល់ទៅពីរដើម មានច្បាប់អនុញ្ញាតឲ្យគាន់ ខ្ញុំចៀសវាងបានតែល្បែងស៊ីសង និងល្បែងស្រា អាភៀន កញ្ឆា ខ្ញុំមិនជាប់ចិត្តសោះ តែត្រង់ល្បែងស្រី ជាប់ចិត្តលង់លួចលាក់ជានិច្ច ដោយខ្ញុំសប្បាយណាស់ទៅជាមានជម្ងឺ គិតកុំឲ្យឈឺ លុះតែរកស្រីស្អាតស្អំ ដល់មកឃើញក្មេងដែលនៅស៊ីឈ្នួលគេនេះមានភាពជាក្មេងល្អត្រឹមត្រូវហើយ នៅតូចផងទើបនិយាយនឹងឪពុក ម្តាយឲ្យយកប្រាក់ខ្ញុំពាំពាន់រៀលទៅសងគេហើយយកនាងនោះ ដែលជាកូនមកនៅជាមួយគាត់ឲ្យឈប់លែងទៅបម្រើគេ ៗ ដោយគាត់ជាអ្នកទីទាល់ហើយមានកូន ៤ នាក់នៅក្នុងបន្ទុក ខ្វះស្លៀកពាក់ស៊ីចាយ ខ្ញុំជួយឲ្យប្រាក់ចាយ ជួយប្អូននាងនោះពីរនាក់ឲ្យមានសំ.បុត្រកំណើត បានចូលរៀនជាសិស្សសាលា ឪពុកម្តាយនាងនោះ.ឃើញខ្ញុំមានគុណលើកូនគាត់ នឹងលើខ្លួនគាត់ផង ក៏រៀបសែនមេបាឲ្យនាងនោះមកខ្ញុំ ៗ ទៅដេកនៅ ១ ដង ១ កាល មិនបានទៅជាប់ជានិច្ចទេ ដោយខ្លាចអ្នកមេផ្ទះខ្ញុំនិងកូនខ្ញុំគេដឹង តែដល់នាងនោះមានផ្ទៃពោះ ខ្ញុំទៅជាទន់ទោរទៅមកញឹក លុះបានកូនស្រីមួយនឹងនាងនោះខ្ញុំប្រាប់ប្រពន្ធតាមត្រង់ ដោយមិនចង់មានរឿងទាស់ទែងគ្នា រវាងកូនដើមនឹងកូនចុង ពីរឿងកេរ្តិ៍មរតក ខ្ញុំធ្វើសំបុត្រប្រគល់ផ្ទះចែកដីកាត់ឈ្មោះខ្ញុំ ឲ្យទៅឈ្មោះកូនស្រីម្នាក់ជាកូនដើម ៗ ដល់មកពេលនេះ ខ្ញុំមានកូននឹងនាងក្រោយនេះដល់ទៅពីរបី ខ្ញុំរកដីសង់ផ្ទះបានមួយឲ្យនៅ

ខាងត្បូងផ្សារទួលទំពូង ដោយក្រែងអត់អំពីខ្ញុំទៅពិបាកវេទនា ទឹងគ្នាច្រើនហើយ គ្មានរបររកទទួលទាន ខ្ញុំបង្រៀននាងនោះឲ្យចេះអក្សរ ឲ្យចេះធ្វើការជាងវេចនា ឥឡូវចេះធ្វើការលក់ដូរបានប្រាក់ចាយខ្លះហើយ ។

ខ្ញុំមិនមែនបានថ្មីចោលចាស់ទេ ខ្ញុំនៅជានិច្ចជាមួយអ្នកមេផ្ទះរបស់ខ្ញុំ ៗ គ្រាន់តែទៅមកផ្ទះក្រោយនេះ ១ ថ្ងៃ ២ ថ្ងៃម្ដង របស់ទ្រព្យ ប្រាក់ខែ ខ្ញុំមិនយកទៅទេខ្ញុំប្រគល់ឲ្យអ្នកមេផ្ទះខ្ញុំទាំងអស់ ខ្ញុំសុំយកទៅចាយខ្លះ ដែលគេព្រមល្មមឲ្យខ្ញុំ ៗ ធ្វើការរកប្រាក់ក្រៅបាន ខ្ញុំយកទៅឯណោះ ដូចជាបានមកអំពីលក់គំនូរ ឬលក់សិទ្ធិ ដែលបាននិពន្ធរឿងផ្សេង ៗ ។

ដល់មកនិយាយអំពីរឿងលក់សិទ្ធិ ខ្ញុំនឹកឃើញរឿងផ្ការីកផ្ការោយ ដែលជាប់លេខ ក្នុងការប្រឡងបានរង្វាន់ ឃើញគេចុះផ្សាយក្នុងកាសែតកម្ពុជាបន្តិចម្ដង ៗ រហូតដល់ចប់ ហើយបណ្ណាគារគីម-សេង ទិញយកទៅបោះពុម្ពជាសៀវភៅលក់ ។

មានទស្សនាវដ្ដីបារាំងឈ្មោះ ហ្វ្រង់ អាស៊ី ក៏បានយករឿងនេះទៅចុះផ្សាយជាអក្សរបារាំងដែរ ។

ដល់មកពេលខាងក្រោយនេះ ក្រុមហ៊ុនភាពយន្តមានជ័យ បានទិញសិទ្ធិយករឿងផ្ការីកផ្ការោយរបស់ខ្ញុំនេះថតជាខ្សែភាពយន្ត ។

ដល់និយាយពីរឿងភាពយន្ត ខ្ញុំបានចូលជាសមាជិកក្រុមហ៊ុនភាព-

យន្តនាពយន៍ ជាមួយលោក រឹម គិន, លោក ម៉ាំង-ម៉ូរ៉ា, លោក ហុក-ក៉ែត ។ល។ ខ្ញុំបានទិញសៀវភៅច្បាប់ក្បួនថតភាពយន្ត ថតសម្ដែងនិងផ្ទះបញ្ចាំង យកមករៀន ។ ខ្ញុំជាអ្នកផ្ញើទៅមកសួរគេទិញប្រដាប់ថតភាពយន្ត ថតសម្ដែង និងប្រដាប់ផ្ទះបញ្ចាំង ។

ពេលដែលបានប្រដាប់ថតភាពយន្តមក លោក ហុក-ក៉ែត គិតរកឲ្យគេមកបង្រៀនពន្យល់អំពីការប្រើប្រដាប់ទាំងអស់នោះ តែខ្ញុំមិនព្រម ដោយអួតអាងថាខ្ញុំចេះ ខ្ញុំទៅរកខ្សែហ្វីលដែលគេថតខូចគេចោលបាន ១ ដុំមក រកមើលរបៀបបើកប្រដាប់ថត ដាក់ខ្សែហ្វីលបានហើយ ខ្ញុំពួនទៅកន្លងបន្ទប់បិទទ្វារឲ្យស្ងាត់ ខ្ញុំរកបើកបិទគិតធ្វើជាថត ត្រូវមួលមើលតាមណា បើចង់បានរូបតូចរូបធំ ឆ្ងាយជិតឲ្យច្បាស់ គេធ្វើយ៉ាងម៉េច ឃើញថាត្រូវផ្លាស់ប្តូរកែវយឺតគិតតាមលេខតូច-ធំ រួចរកពីបើកបិទឲ្យល្មិត-ក្តី ។ ខ្ញុំពួនមើលពិនិត្យគិតដល់យល់ការទាំងអស់ បើបានហ្វីលថ្មី ១ ដុំមក ខ្ញុំថតបានភ្លាម ទើបខ្ញុំទៅជួបនឹងលោក ហុក-ក៉ែត ពន្យល់អំពីរបៀបប្រើប្រាស់ថតនោះទៅ លោកជឿទុកចិត្តតាមខ្ញុំអាចថតបាន ទើបបណ្តោយឲ្យខ្ញុំចាត់ការថតខ្សែកុន ១ ខ្សែ ។ ខ្ញុំយក រឿងការសង់សឹក ពីលោក រឹម-គិន មកគិតបែងចែងរឿងនោះជាភាគ ១ សង្កាត់ ១ ដែលគេហៅថា ដេគុបប៉ាស ។

រៀបរឿងរួចហើយ ខ្ញុំហៅគេបងប្អូនក្មួយ និងញាតិមិត្តជិតខាងខ្ញុំ

មក នាំគ្នាហាត់លេងតាមរឿង ៗ បានធ្វើប្រដាប់ដាវ-ខែល-ធ្នូ-ស្នា-លំពែង និងសំលៀកបំពាក់ មិនចង់ឲ្យបង់ខាតអស់ប្រាក់ច្រើនទៅលើសំលៀកបំពាក់តាមរឿងដាច់ដើម ខ្ញុំយកសំលៀកបំពាក់ធម្មតាមក រកក្រដាសពណ៌ក្រដាសមាស កាត់បិទបាយម៉ាន ធ្វើឲ្យបានល្អសមរម្យ រួចខ្ញុំចាត់ការថតផ្ទាល់ខ្លួនខ្ញុំ ពីដើមរហូតដល់ចប់ ៗ ថតបណ្តើរផ្ញើទៅឲ្យគេលាងឯស្រុកបារាំងបណ្តើរ ដោយខ្សែកុនពណ៌លាងនៅស្រុកយើងមិនទាន់បាន ដល់បានមកខ្ញុំសរសេរអក្សរចំណងជើងថតកាត់បិទតភ្ជាប់គ្នាកើតបានជាខ្សែកុន ១ យ៉ាងវែង ល្មមដុះបញ្ចាំងឲ្យគេមើលយកប្រាក់បាន ៗ

ដោយចង់បង្អួតគេឲ្យឃើញថា ខ្ញុំចេះល្បិចថតភាពយន្ត ខ្ញុំថតខ្សែកុនមុតប្រាយ ១ ខ្សែខ្លី នាំឲ្យគេឆ្ងល់ទីងពពុះទឹកអណ្តែតចេញពីកែវដែលមានទឹកពណ៌ស, ខៀវ, ក្រហម ទៅតម្រៀបជាអក្សរហើយក្លាយទៅជាទង់ជាតិ ៗ គេឆ្ងល់ទីងផ្កាយរេដំរៀបគ្នាជាអក្សរហើយឃើញព្រះចន្ទពេញវង់ ថែមទាំងឃើញព្រះភក្ត្រព្រះករុណា នៅក្នុងព្រះចន្ទនោះ ៗ មានមេអំបៅហើរដំរៀបគ្នាជាអក្សរ និងមានរូបគំនូរចេះដើរ គឺរូបរឿងអាចាក់ស្លុក ១ ចប់ ៗ

ខ្សែភាពយន្តវែង ១ ខ្សែខ្លី ១ ខ្សែនេះបានដុះបញ្ចាំងឲ្យគេមើលរោងកុនជិតកលមេរុ មានសម្លេងដែលខ្ញុំថតបញ្ចូលក្នុងពេលដុះបញ្ចាំងនោះផង ៗ

ក្នុងវេន ១ អាទិត្យ បានប្រាក់ចំណូល ៩០ ពាន់ ។

ដោយជិតអស់ក្រដាសនៅសៀវភៅនេះ ខ្ញុំមិនអាចសរសេរឲ្យពិស្តារបាន សូមសរសេរខ្លី ៗ ត្រង់នេះបន្តិច ត្រង់នោះបន្តិច តាមដែលនឹកឃើញ ។

ខ្ញុំមានបានរួមគំនិតជាមួយឈ្មោះ អៀង សៀង ប្អូនខ្ញុំ ចេញទស្សនាវដ្តីមួយឲ្យឈ្មោះថា ទស្សនាវដ្តីកំសាន្តចិត្ត ។ ប្អូនខ្ញុំនិពន្ធរឿងព្រេងជារឿងកំប្លែងខ្លី ៗ ចំណែកខ្ញុំ ៗ និពន្ធរឿងកំប្លែងសម័យថ្មីខ្លី ៗ ជាង ៣០ រឿង និងរឿងបញ្ហាព្រមទាំងរូបចំណាកឯទៀត ។ ចេញក្នុង ១ ខែ ១ លេខ ចេញបាន ១៦ លេខឈប់ ។

ដល់មកសម្តេចព្រះបិតាអក្សរសាស្ត្រខ្មែរបានបង្កើតសារពត៌មានអ្នកជាតិនិយម ក្រុមជំនុំបានពប់ឈ្មោះខ្ញុំចូលជាអ្នកនិពន្ធអ្នកជាតិនិយម ដោយឃើញមានបញ្ចូលយនាមខ្ញុំ និងនាមអស់លោកធំ ៗ ផ្ញើមកខ្ញុំហើយ យករូបថតខ្ញុំទៅធ្វើពុម្ព ១ និងយក ១ ទៀតទៅបិទធ្វើជាកាត ឲ្យខ្ញុំកាន់ចេញចូលទៅក្នុងព្រះរាជដំណាក់សម្តេចព្រះប្រមុខរដ្ឋនៅចំការមន ខ្ញុំបានជួយគូររូបអប់រំដាក់ចំណងជើងជាពាក្យកាព្យចុះក្នុងសារពត៌មាន អ្នកជាតិនិយមហូរហែមក ។ បានទទួលប្រោសព្រះរាជទានការជប់លៀងនៅក្នុងព្រះបរមរាជវាំង និងបានទទួលព្រះរាជទានគ្រឿងឥស្សរិយយសមេដាយអស្សរិទ្ធិសុវត្ថារ ដោយការនិពន្ធនេះ ។

អំពីការដែលមានឈ្មោះជួយមើលការប្រឡង រៀងរាល់ឆ្នាំដែលប្រឡងចេញ ប្រឡងចូល មានឈ្មោះត្រូវជួយមើល ។ ឯវិញ្ញាសាការប្រឡងគំនូរ ខ្ញុំជាអ្នកជ្រើសរើសគេជូនទៅលោកប្រធាននៃការប្រឡងដល់ចេញជូនគ្រូហើយ ត្រូវខ្ញុំជាអ្នកមើលឲ្យពិន្ទុ ។

ឯកម្មវិធីដែលបង្រៀនគំនូរនៅមធ្យមសិក្សា គឺខ្ញុំជាអ្នករៀបចំ តាំងពីថ្នាក់ទី ៦ ដល់ថ្នាក់ទី ៣ ។ ឯថ្នាក់ទី ២ និងទី ១ រៀបចំដោយគណៈកម្មការសាស្ត្រាចារ្យខាងគំនូរ ដែលមានឈ្មោះខ្ញុំជាប្រធាន ប្រជុំគ្នារៀបចំនៅមន្ទីររដ្ឋមន្ត្រីក្រសួងអប់រំជាតិ ។

តាំងពីមានថ្នាក់បង្រៀនខាងវិជ្ជាជីវៈគ្រូបង្រៀនប្រុសស្រី នៅវិទ្យាស្ថានជាតិគរុកោសល្យមក ខ្ញុំជាអ្នកបង្ហាត់បង្រៀនខាងមុខគំនូរ ខ្ញុំយកកម្មវិធីបង្រៀនគំនូរ នៅសាលាបឋមសិក្សាមកបង្ហាញឲ្យសិស្សទាំងអស់មើល ដោយកម្មវិធីនោះជាអក្សរបារាំង ខ្ញុំក្រែងពួកអស់នោះមិនយល់សេចក្តីមកជាភាសាខ្មែរ សូម្បីខ្ញុំដឹងថាពួកសិស្សដែលប្រឡងជាប់បានចូលទៅរៀនហាត់ធ្វើគ្រូនោះខ្លះមានឌីប្លូម ខ្លះមានបាស្រ្តី កំខ្ញុំនៅតែមិនទាន់ជឿថា អាចយកកម្មវិធីអក្សរបារាំងនោះទៅមើលហើយយល់អាចបង្រៀនទៅតាមកម្មវិធីនោះបាន ទើបខ្ញុំហៅគេអ្នកនាំណាដែលថាខ្ទង់ចេះអក្សរបារាំង អាចគានបានដឹងសេចក្តីឲ្យមកមើលកម្មវិធី ១ ឃ្លា ឬ

១ ភាគ រួចខ្ញុំសួរថាអ្នកនានាយល់សេចក្ដីនេះថា គេឲ្យយើងទៅបង្រៀន យ៉ាងម៉េចខ្លះ? តាមគោលការគេ ។ ឲ្យយើងធ្វើម្ដេចខ្លះ ឲ្យត្រូវតាមវិធី នោះ ។ មានខ្លះថាគ្រាន់តែយល់មិនចេះនិយាយ មានខ្លះចេះនិយាយ ដែរ តែនិយាយមិនត្រូវតាមគោលការ ដោយមានច្រឡំខ្លះ ។ មិនចេះ ពាក្យបច្ចេកទេស ម្ល៉ោះហើយខ្ញុំមិនព្រមឲ្យត្រូវ ខ្ញុំដណ្ដើមមើល ១ ឃ្លា ឬ ១ ភាគ ខ្ញុំនិយាយបកប្រែតាមសេចក្ដី តាមគោលការហើយថែម តាំងគូរពន្យល់នៅក្ដារខៀនទៀត ។

ដោយខ្ញុំបង្ហាញឲ្យពួកសិស្សឃើញអំពីការចេះដឹងយល់ការរបស់ខ្ញុំ ជាងខ្លួនគេ ។ ក៏នាំគ្នាចង់ដឹងថាខ្ញុំ រៀនបារាំងដល់ទៅថ្នាក់ណាទៅ បានជាចេះដឹងបកប្រែ "វែមតិចនិក" ពាក្យបច្ចេកទេសជ្រៅជ្រះ ម្ល៉េះ ។ ខ្ញុំថា ខ្ញុំមិនដែលមានឈ្មោះជាសិស្សរៀនអក្សរបារាំងនៅគ្រូអង់ហ្វង់តាំងសាលាណាសោះផង ។ និយាយតាមត្រង់ដូច្នេះ គ្មានអ្នកណាជឿសោះ ។

ខ្ញុំសរសេររឿងត្រង់នេះមិនមែនខ្ញុំអួតទេ គឺខ្ញុំចង់បំភ្លឺគេឲ្យយល់ថា ចំណេះរបស់ខ្ញុំមិនមែនកើតឡើងដោយបានរៀននៅថ្នាក់នេះថ្នាក់នោះ ឬ ដោយមានសញ្ញាប័ត្រនេះ សញ្ញាបត្រនោះទេ គឺសំខាន់ត្រង់ការព្យាយាម ដូចមានខ្លួនខ្ញុំជាតួយ៉ាង ។

(នៅមានត)

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

## ពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ

ឆ្នាំនេះ ក៏ដូចឆ្នាំមុន ៗ ដែរ រាជរដ្ឋាភិបាល បានរៀបចំ ធ្វើពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ យ៉ាងឱឡារិក នៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។

ពិធីនេះ បានចាត់ចែងឡើងជាពីរលើក គឺពេលល្ងាចថ្ងៃ ១៥ កើត ខែពិសាខ គឺថ្ងៃទី ២៣ មេសា ១៩៦៧ ប្រារព្ធធ្វើពិធីនមស្ការព្រះចេតិយដែលមានតម្កល់ព្រះបរមសារីរិកធាតុនៃព្រះសម្ពុទ្ធបរមគ្រូ ដែលតាំងនៅមុខស្ថានីយរាជអយស្ម័យយាន នាក្រុងភ្នំពេញ ។ សម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ក្រោយដែលបានទទួលការគោរពអំពីសំណាក់ឥស្សរជនគ្រប់ដំណែងនៃព្រះរាជាណាចក្រ ដែលមកជួបជុំក្នុងព្រះពន្លាហើយ ព្រះអង្គទ្រង់គោរពព្រះសង្ឃ ៨០ អង្គ ដែលមាន សម្តេចព្រះសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះពោធិវង្ស ជាអាទិ៍ ។ បន្ទាប់មកក៏មានប្រារព្ធពិធីគោរពទង់ជាតិ ទង់សាសនា ដោយមានចម្រៀងបទនគររាជ និងបទសរភេញ្ញ អង់ផង ។ សហជីវិន គុយ-ពៅ អនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថា ក្នុងនាមរាជរដ្ឋា-

កិចាល សំដែងសេចក្ដីគោរពចំពោះព្រះសក្យមុនីចេតិយ ដែលបន្ត មកសម្ដេចព្រះប្រមុខរដ្ឋ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ថ្លែងតបវិញនូវព្រះសង្ឃថា យ៉ាងក្បោះក្បាយ មានន័យទូលំទូលាយក្រៃលែង ដែលពុទ្ធបរិស័ទ និងបណ្ដាជនទាំងអស់បានស្ដាប់តាមវិទ្យុជាតិ ដែលបានផ្សាយជាច្រើនលើកមកហើយ គួរឲ្យជាប់ចិត្តពន់ពេកណាស់ ។

ចប់ព្រះសង្ឃថាហើយ សម្ដេចព្រះបិតាជាតិ ទ្រង់បានយាងមួយអន្ទើទឹងនាម៉ឺនសព្វមុខមន្ត្រី តាមដង្ហែព្រះអង្គផង យាងប្រទក្សិណ និងធ្វើសក្ការបូជាចំពោះព្រះសក្យមុនីចេតិយ ។ តមកព្រះសង្ឃ ៨០ អង្គ ក៏ចំរើនពុទ្ធជយមង្គលគាថា លាន់ឮគឹកកងផង ។

លុះព្រឹកឡើងថ្ងៃ ១ រោច ត្រូវនឹងថ្ងៃទី ២៤ មេសា ១៩៦៧ មានរៀបពិធីដាក់បាត្រព្រះសង្ឃ ៨០ អង្គ ជាផ្លូវការ នៅក្រោមព្រះរាជាធិបតីភាពនៃសម្ដេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៏ ដែលតមកមានពិធីទំលាក់ទង់ជាតិ ទង់សាសនា និងមានពិធីដាក់បាត្រព្រះសង្ឃ ១.៥០០ អង្គ ដោយឡែកទៀត ដែលពុទ្ធិកសមាគមបានរៀបចំឡើង ព្រមទាំងមានពុទ្ធបរិស័ទច្រើនកុះករមកចូលរួមផង ។

# សុន្ទរកថា

សហជីវិន **គុយ-ពៅ** អនុរដ្ឋលេខាធិការ

ក្រសួងធម្មការ និង សាសនសិក្សាធិការ

ថ្លែងក្នុងឱកាសបុណ្យនមស្ការព្រះសក្យមុនីចេតិយ

សូមព្រះតេជៈតំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទ

នៃសម្តេច សហជីវិន ព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

ថ្ងៃនេះ ជានក្ខត្តឫក្ស ពេញបូណ៌មី ខែពិសាខ គឺជាឱកាសប្រសើរបំផុតរបស់ពុទ្ធសាសនិកជនទាំងឡាយ សម្រាប់រំលឹកដល់មហាទិវាត្រី ដែលព្រះសមណគោតម ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រសូតជាបច្ឆិមជាតិផង ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណទាំងបី គឺ បុព្វេនិវាសានុស្សតិញាណ ទ្រង់រំលឹកឃើញជាតិកំណើតព្រះអង្គ ក្នុងអតីតជាតិ ដែលធ្លាប់អន្ទោលទៅមកក្នុងវដ្តសង្សារ, ចុតូបបាតញាណ ទ្រង់ជ្រាបដល់សត្វដែលច្យុត និងបដិសន្ធិ, អាសវក្ខយញ្ញាណ ទ្រង់ជ្រាបនូវផ្លូវសម្រាប់ទៅកាន់ទីរលត់ទុក្ខ និង ថ្ងៃបរិនិព្វានផង ។

ពុទ្ធសាសនិកជនទូទាំងប្រទេស ជាពិសេស អ្នកនៅក្នុងព្រះរាជធានីភ្នំពេញ តែងត្រេកអរឥតឧបមា និងបានហែតាមពីក្រោយព្រះប្រិស្ដាន្គនៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ជាទីស្នេហានិងគោរពស្មើជីវិតរបស់ខ្ញុំ ក្នុងការបូជាគ្រឿងទិព្វទេសពិសេសគន្ធរស ប្រទក្សិណព្រះសក្យ-មុនីចេតិយ ដែលតម្កល់ព្រះបរមសារីរិកធាតុ ។

ទូលព្រះបង្គំជាខ្ញុំ ក្នុងនាមនៃព្រះរាជរដ្ឋាភិបាល ក្នុងនាមនៃពុទ្ធបរិស័ទទាំងអស់ ក្នុងប្រទេសកម្ពុជាទាំងមូល និងក្នុងនាមនៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំពិធីបុណ្យ, សូមព្រះបរមរាជានុញ្ញាតសំដែងនូវអំណរព្រះគុណ និង កតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះវត្តមាននៃសម្តេចព្រះប្រមុខរដ្ឋ ជាទីគោរព·សក្ការៈ ស្មើដោយជីវិត នៃបណ្តាជនខ្មែរ ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ ដើម្បីញ៉ាំងពិធីនេះ ឲ្យបានរុងរឿងជាកិត្យានុភាព ហើយជាសក្ខីភាព បញ្ជាក់នូវព្រះរាជូបត្ថម្ភដ៏ខ្លាំងក្លា ចំពោះព្រះពុទ្ធសា-សនា ដែលជាសាសនារបស់ព្រះអង្គ ។

សូមព្រះតេជៈតំកល់លើត្បូង

ព្រះសក្យមុនីចេតិយនេះ ជាអនុស្សរណដ្ឋានដ៏ធំក្រៃលែង របស់ពុទ្ធសាសនិកជនខ្មែរទូទៅ ដែលតែងតែនាំគ្នាធ្វើសក្ការៈបូជាដោយទឹក

ចិត្តជ្រះថ្លាជាបំផុត ៗ រីឯព្រះបរមសារីរិកធាតុ ដែលដំកល់នៅទីនេះ គឺដោយសារសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ដែលព្រះអង្គទ្រង់គង់នៅលើរាជបល្ល័ង្កនៅឡើយ ព្រះអង្គទ្រង់បានទទួលផ្ទាល់ពីលោកអ្នកដែលថែរក្សាព្រះធាតុ នៅក្រុងកេណ្ឌី នៅឱកាសដែលទ្រង់យាងទៅបំពេញបេសកកម្ម ឯប្រទេសសេរីលង្កា ៗ នៅពេលដែលប្រទេសយើងរៀបធ្វើពិធីបុណ្យពាក់កណ្តាលសាសនា ពី គ.ស ១៩៥៧ នោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានប្រោសព្រះរាជទានឲ្យដង្ហែព្រះបរមសារីរិកធាតុ មកប្រតិស្ឋាននៅក្នុងអង្គព្រះចេតិយនេះ ទុកជាទីគោរពសក្ការៈតរៀងមក ៗ បន្ទាប់ពីបុណ្យដ៏ធំនេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ កំណត់យកថ្ងៃ ១៥ កើត និង ១ រោច ខែពិសាខ ទុកជាថ្ងៃបុណ្យសម្រាប់ធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយជាផ្លូវការ ហើយទ្រង់ចាត់ឲ្យក្រសួងធម្មការរៀបចំធ្វើពិធីនេះ ដោយរួមជាមួយក្រសួងនានា ប្រារព្ធធ្វើមកជារៀងរាល់ឆ្នាំ ជាគំរប់ឆ្នាំទី ១០ ហើយ ៗ

ព្រះសកម្មភាព ដ៏ធំៗ ក្នុងការឧបត្ថម្ភព្រះពុទ្ធសាសនា ដូចបានរៀបរាប់មកនេះ បន្ថែមទៅលើព្រះមហាករុណាធិគុណជាច្រើនអនេកផ្សេង ៗ ទៀត ដែលព្រះមហាក្សត្រគ្រប់ព្រះអង្គ ទ្រង់តែងតាក់ព្រះទ័យក្នុងការកសាងឲ្យមានអគារវិទ្យាការ ខាងពុទ្ធចក្រ ក៏ដូចជាខាងអាណា-

ចក្រដែរ ជាឧទាហរណ៍ ឲ្យយល់ប្រត្យក្សថា ព្រះរាជបល្ល័ង្កខ្មែរ តែងតែសន្តោសឧបត្ថម្ភព្រះពុទ្ធសាសនាគ្រប់ពេលវេលា ពុំមានខ្ចោះ ។

សូមទ្រង់ព្រះមេត្តាប្រោស

លំដាប់តពីនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជវរោកាស ថ្លែងអភិវន្ទនកិច្ច ចំពោះព្រះបរមសារីរិកធាតុដូចតទៅ ៖

បពិត្រព្រះបរមសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធ បរមគ្រូជាអម្ចាស់

ពិតមែនតែព្រះអង្គទ្រង់ចូលព្រះបរិនិព្វានផុតទៅហើយ ប៉ុន្តែព្រះបរមធាតុ និង សាសនាគឺពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ដែលទ្រង់ប្រតិស្ឋានទុកឲ្យគ្រប់ ៥.០០០ ព្រះវស្សានោះ បានឋិតនៅសេរីរីកដូចទិដ្ឋភាព កាលព្រះអង្គ គង់ព្រះជន្មនៅ ដូច្នោះដែរ ។ ព្រះសូត្រ ព្រះវិន័យ ព្រះអភិធម្ម ដែលជាមូលដ្ឋាននៃព្រះពុទ្ធដីកា ក៏ត្រូវពួកពុទ្ធ-សាសនិកជនគ្រង់គ្រាប់ គោរពប្រតិបត្តិ មកទល់សព្វថ្ងៃនេះបាន ២៥១០ វស្សាហើយ រហូតទៅដល់អង្គព្រះសិអារ្យមេត្រី ដែលនឹងត្រាស់ដឹងនៅចុងកប្បនេះ មានព្រះជន្មវស្សាដល់ទៅប្រាំបីម៉ឺនព្រះវស្សា ។ កម្ពុជរដ្ឋ ដែលក្នុងបច្ចុប្បន្ននេះ បានសន្តិភាពជាជាងប្រទេសនានា ដោយអាស្រ័យសម្តេចព្រះមហាក្សត្រិយានី និង សម្តេចព្រះអគ្គប្រមុខរដ្ឋ ព្រះអង្គទ្រង់ឧបត្ថម្ភពេញព្រះសមត្ថភាព លើកសាសនាព្រះអង្គឲ្យរុងរឿងជាអតិបរមា ព្រមជាមួយអង្គការចលនាសង្គមរាស្ត្រនិយម ដែល

មានមនោគមន៍វិជ្ជាដូចនេះមិន នឹងសង្គមនិយមព្រះពុទ្ធសាសនាដែរ ។ ខ្ញុំព្រះអង្គទាំងឡាយ មានសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្តេចព្រះប្រមុខរដ្ឋ ជាប្រធាន, ព្រះសង្ឃទាំងឡាយ មានសម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក, សម្តេចព្រះពោធិវង្ស, រដ្ឋសភា, ក្រុមប្រឹក្សាព្រះរាជាណាចក្រ, ព្រះរាជរដ្ឋាភិបាល, នាម៉ឺនសព្វមុខមន្ត្រី គ្រប់ក្រសួង ទាំងទាហាន, ទាំងស៊ីវិល, យុវជន - យុវតី, ឧបាសក - ឧបាសិកា ព្រមទាំងប្រជាពលរដ្ឋ បានស្តេចយាង និង អញ្ជើញមកជួបជុំក្នុងបរិវេណនេះ ដើម្បីគោរពនមស្ការចំពោះព្រះសារីរិកធាតុនៃព្រះអង្គ ដែលប្រតិស្ឋាននៅទីនេះ និងសូមរំលឹកព្រះមហាករុណាធិគុណនៃព្រះអង្គផង ព្រមទាំងបានបូជាដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន - ធូប - ផ្កាភ្ញីប្រទីបផ្កាលា ជាដើមផង ។ សូមព្រះអង្គ ទ្រង់ព្រះមេត្តាប្រោសទទួលនូវអភិវន្ទនកិច្ច និង គ្រឿងសក្ការៈទាំងឡាយ ដែលខ្ញុំព្រះអង្គទាំងអស់បាននាំមកថ្វាយនៅវេលានេះ ។

សូមទ្រង់ព្រះមេត្តាប្រោស

ដោយអានុភាពនៃកិច្ចនមស្ការនេះ ខ្ញុំព្រះអង្គទាំងឡាយ សូមគោរពបួងសួងចំពោះគុណព្រះបរមសារីរិកធាតុ គុណព្រះរតនត្រ័យ និងទេវតាទូទាំងសកលចក្រវាឡ សូមជួយបីបាច់ថែរក្សាអង្គសម្តេចព្រះមហា

ក្សត្រិយានី ព្រះមាតាជាតិ, សម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិ ជាទីគោរព និង ស្នេហា ស្មើជីវិតនៃប្រជាពលរដ្ឋទាំងឡាយ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ សូមព្រះអង្គប្រកបដោយព្រះបរមសុខ មានព្រះជន្មាទីឃាយឺនយូររាប់រយព្រះវស្សា ឈ្នះអស់មារសត្រូវគ្រប់ទិសទី ដែលកំពុងយាយីសព្វថ្ងៃ ឲ្យវិនាសខ្ចាត់ខ្ចាយអន្តរាយបាត់បង់យ៉ាងផុតនាប់ និងទ្រង់គង់ជាម្លប់ដ៏ត្រជាក់សុខសាន្តនៃកូនចៅរបស់ព្រះអង្គ នៅក្នុងកម្ពុជរដ្ឋទាំងមូល ជាអង្វែងតរៀងទៅ ។

មួយចំណែកទៀត សូមបុញ្ញកុសលនេះ ជួយទ្រទ្រង់សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ, សម្តេចព្រះសុធម្មាធិបតី ព្រះសង្ឃនាយក, សម្តេចព្រះពោធិវង្ស និង សម្តេចគ្រប់ព្រះអង្គ សូមទ្រង់បានប្រកបជួបប្រទះតែនឹងបរមសុខ ផុតចាករោគាពាធទាំងឡាយ ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនា បានថ្កុំថ្កើងរុងរឿងឋិតថេរចេរកាលតរៀងទៅ ។

ទីបំផុត សូមគុណានុភាព ជួយអភិបាលពុទ្ធបរិស័ទ ទាំងគ្រហស្ថប្រជាពលរដ្ឋរួមជាតិគ្រប់ឋានៈ ទាំងទាហាន - ទាំងស៊ីវិល - កងរាជតម្រួត - យុវជនរាជសង្គមនិយមខ្មែរ និង ប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រទាំងមូល ឲ្យបានជួបតែនឹងសេចក្តីសុខចំរើនគ្រប់ប្រការ ព្រមទាំងមានការព្រមព្រៀងគ្នាជាឯកភាព ក្នុងការកសាងប្រទេសជាតិ និង

ព្រះពុទ្ធសាសនា ក្រោមព្រះរាជូបត្ថម្ភនៃព្រះរាជបល្ល័ង្ក ឲ្យរឹងរឹតតែមាន សាមគ្គីរឹងប៉ឹងឡើងទៀត ដង្ហែតាមព្រះមាគ៌ានយោបាយដ៏ភ្លឺស្វាង នៃ សម្តេចព្រះអគ្គមគ្គុទ្ទេសក៍ជាតិ ដើម្បីជោគជ័យ និងសុខុមាលភាពគ្រប់ពេលវេលាតរៀងទៅកុំបីឃ្លៀងឃ្លាត ។

សូមព្រះតេជៈតំកល់លើត្បូង

# ពិធីបុណ្យរំឭកខួបកំណើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

កាលពីថ្ងៃសុក្រ ទី ១២ ខែឧសភា ១៩៦៧ វេលាម៉ោង ៨ ព្រឹក នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ មានប្រារព្ធធ្វើពិធីបុណ្យខួបឆ្នាំទី ៣៧ នៃការបង្កើតវិទ្យាស្ថាននេះ ហើយនិងពិធីថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋ ព្រះអគ្គសាសនូបត្ថម្ភក ។ ពិធីនេះប្រារព្ធធ្វើក្រោមអធិបតីភាពនៃសម្តេចព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សាកម្ពុជរដ្ឋ អធិបតីនៃក្រុមជំនុំព្រះត្រៃបិដក និងព្រះតេជព្រះគុណ អ៊ុក-ម៉ូត អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនសិក្សាធិការ ដែលមានបុគ្គលិកទាំងព្រះសង្ឃទាំងគ្រហស្ថនិងពុទ្ធបរិស័ទធ្វើការក្នុងក្រសួងធម្មការ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ អគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតជួបជុំផង ។ មុនការប្រារព្ធដាក់បាត្រព្រះសង្ឃចំនួន ៣៧អង្គ និងការចំរើនសត្តប្បករណាភិធម្ម ភត្តានុមោទនា សហជីវិន លាង-ហ៊ប-អាន នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្នុងនាមព្រះសង្ឃ គ្រហស្ថជាបុគ្គលិកនៃវិទ្យាស្ថាន បានថ្លែងសុន្ទរកថាស្តីអំពីប្រវត្តិវិទ្យាស្ថាន គោលបំណងនៃពិធីបុណ្យ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# សុន្ទរកថា

សូមនមស្ការ សម្តេចព្រះពោធិវង្ស ជាអម្ចាស់

សូមប្រណិប័តន៍ ឯកឧត្តម ទេសរដ្ឋមន្ត្រី

សូមជំរាបព្រះតេជព្រះគុណអនុរដ្ឋលេខាធិការ

សូមជំរាបសហជីវិន សហជីវិនីទាំងឡាយ

ខ្ញុំព្រះករុណា ខ្ញុំបាទមានបីតិសោមនស្សក្រៃលែង និងសូមថ្លែងអំណរព្រះគុណ-អំណរគុណចំពោះសម្តេចជាអម្ចាស់ ឯកឧត្តម ព្រះតេជព្រះគុណ និងសហជីវិន សហជីវិនីទាំងអស់ ដែលទ្រង់បាននិងបានឆ្លៀតឱកាសយ៉ាងមមាញឹក និមន្តនិងអញ្ជើញមកជាកិត្តិយស ក្នុងពិធីបុណ្យខួបរំលឹកឆ្នាំទី ៣៧ នៃការបង្កើតវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលយើងខ្ញុំព្រះករុណា ខ្ញុំបាទ ប្រារព្ធធ្វើឡើងក្នុងពេលនេះ ។ ការនិមន្ត និងអញ្ជើញមកនេះ បញ្ជាក់នូវព្រះហឫទ័យ នូវចិត្តសន្តោសមេត្តារបស់សម្តេច ឯកឧត្តម ព្រះតេជព្រះគុណ សហជីវិន-សហជីវិនី ចំពោះវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ នាំឱ្យយើងខ្ញុំព្រះករុណា-ខ្ញុំបាទ រឹងរឹតតែមានកម្លាំងប្រឹងប្រែង បំរើមុខងារក្នុងវិជ្ជាស្ថាននេះ ខ្លាំងក្លាថែមឡើងទៀត ។

បន្ទាប់ពីនេះ សូមមេត្តាអនុញ្ញាត ដើម្បីខ្ញុំព្រះករុណា ខ្ញុំបាទ ថ្លែងបន្តិចអំពីប្រវត្តិដើមនៃវិជ្ជាឋាននេះ :

ដូចជាសម្តេច ឯកឧត្តម ព្រះតេជព្រះគុណ និងសហជីវិនទាំងអស់ ជ្រាបស្រាប់មកហើយ មន្ទីរពុទ្ធសាសនបណ្ឌិត្យនេះ កាលដើមឡើយហៅថា "ព្រះរាជបណ្ណាល័យ" ដែលរាជការបានបង្កើតឡើងតាំងពីឆ្នាំ ១៩២១ ហើយដែលបានធ្វើពិធីសម្ពោធនៅថ្ងៃ ១៣ សីហា ១៩២៥ ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ។ តាំងពីចាប់ប្រកបដំណើរការមក ព្រះរាជបណ្ណាល័យក៏បានលេចឮឈ្មោះទៅគ្រប់ទិសទីទាំងក្នុងប្រទេស ទាំងក្រៅប្រទេស រហូតមកដល់គ្រាសព្វថ្ងៃ ហើយក៏នៅតែមានអង្គការបរទេសសរសេរសំបុត្រស្នាមមកទាក់ទង តាមឈ្មោះសំបុត្រថា "ព្រះរាជបណ្ណាល័យ" នោះដែរ ។ កាលកើតឡើងជាដំបូងនោះ ព្រះរាជបណ្ណាល័យមានមុខការជាអ្នកថែរក្សាគម្ពីរ - ក្រាំង - សាស្ត្រា និងសៀវភៅឯកសារប្រភេទដូចគ្នានេះ មកតម្កល់ថែរក្សាទុកផង ។ ម្យ៉ាងហើយ ចំនួនឯកសារក៏កាន់តែមានក្រាស់ក្រែលឡើងជាលំដាប់ ឯសៀវភៅភាសាបាលី និងភាសាដទៃ ៗ ទៀតសោត ក៏កាន់តែកើនច្រើនឡើង ។ ព្រោះមានការទាក់ទងជាមួយអង្គការបរទេសកាន់តែសាយភាយឡើងដែរ ធ្វើឲ្យបណ្ណាល័យនេះ ទៅជាមជ្ឈមណ្ឌលវប្បធម៌មួយ ដែលគេស្គាល់ជាង

គេនៅក្នុងប្រទេសឥណ្ឌូចិន កាលសម័យនោះ ។ មិនតែប៉ុណ្ណោះ ព្រះរាជបណ្ណាល័យបានចាត់ការបោះពុម្ពផ្សាយសៀវភៅធម៌ផង ដែលចាត់ជាការបោះពុម្ពផ្សាយជាគ្រាដំបូងបំផុតនៅប្រទេសកម្ពុជាយើង ជាពិសេសគឺការបោះពុម្ពព្រះត្រៃបិដក ដែលជាការងារយ៉ាងធំ ហើយយ៉ាងពិនិត្យពិច័យបំផុតរបស់ក្រុមជំនុំព្រះត្រៃបិដក ។

លុះមកដល់ គ.ស. ១៩៣០ ព្រះបាទសម្តេចព្រះមុនីវង្ស ព្រះអង្គទ្រង់មាន ព្រះរាជបំណងចង់ពង្រីកព្រះពុទ្ធសាសនាក្នុងប្រទេសយើង ព្រះអង្គទ្រង់ត្រាស់បង្កើតឲ្យមានវិជ្ជាឋានមួយ ហៅថា " ពុទ្ធសាសនបណ្ឌិត្យ " តាំងនៅជាមួយគ្រឹះស្ថានព្រះរាជបណ្ណាល័យ ដើម្បីទទួលភារៈសិក្សាស្រាវជ្រាវ និងតម្រឹមតម្រង់ការប្រតិបត្តិព្រះពុទ្ធសាសនាឲ្យកាន់តែបានហ្មត់ចត់ឡើង នៅក្នុងប្រទេសយើង ។ ដូច្នេះកិច្ចការខាងបោះពុម្ពផ្សាយ និងការស្រាវជ្រាវគ្រប់បែបយ៉ាង ត្រូវផ្ទេរបន្តទៅឲ្យជាភារៈរបស់ពុទ្ធសាសនបណ្ឌិត្យ ឯព្រះរាជបណ្ណាល័យគ្រាន់តែជាអ្នកថែរក្សាប៉ុណ្ណោះ ។

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យបានសម្ពោធជាផ្លូវការកាលពីថ្ងៃទី ១២ ឧសភា គ.ស. ១៩៣០ នៅក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស បើគិតមកទាល់និងថ្ងៃនេះ ត្រូវជា ៣៧ ឆ្នាំ គត់ ។

លុះមកដល់ គ.ស. ១៩៤៣ ព្រះរាជបណ្ណាល័យត្រូវផ្ទេរសម្បត្តិដើមដែលជា គម្ពីរ សាស្ត្រា និងក្រាំងយកពីក្នុងព្រះរាជវាំងមកនោះ ប្រគល់ជូនទៅបណ្ណាល័យក្នុងព្រះបរមរាជវាំងវិញ ដូច្នេះឈ្មោះដើមដែលថា « ព្រះរាជបណ្ណាល័យ »នោះ ត្រូវអស់តាំងពីនោះមក ។ បណ្ណា-ល័យដែលសេសសល់ឯកសារទាំងប៉ុន្មាន ក៏នៅជាសម្បត្តិផ្ទាល់របស់ពុទ្ធសាសនបណ្ឌិត្យរហូតមក ។

ចំណែកអ្នកកាន់កាប់គ្រប់គ្រងមន្ទីរនេះ ដើមឡើយសុទ្ធសឹងតែជាជនជាតិបារាំង តែអ្នកទាំងនេះបានខិតខំយកចិត្តទុកដាក់ណាស់ ដោយធ្វើសហប្រតិបត្តិការជាមួយសម្ដេចព្រះវរបក្រណាឫទ្ធិ ឧកោត្តម-សុធារស, សម្ដេចព្រះធម្មលិខិត លី-ឯម កាលនៅជាព្រះញាណបវរវិជ្ជា, សម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ កាលនៅជាព្រះសំសត្ថា, សម្ដេចព្រះពោធិវង្ស កាលនៅជាព្រះគ្រូសំវិជ្ជា និង ព្រះឧត្តមមុនី អ៊ុំ-ស៊ូ កាលនៅជាព្រះវិមលបញ្ញា ។ ដូច្នេះ គឺព្រះអង្គដែលមានរាប់ព្រះនាមមកនេះហើយ ដែលបានផ្ដើមត្រួសត្រាយផ្លូវដឹកនាំក្រសួងឲ្យបានល្អគួរសមចំរើន សឹងមានកេរ្តិ៍ឈ្មោះល្អថ្លៃថ្លារហូតដល់មកសព្វថ្ងៃនេះ ។

នៅ គ.ស. ១៩៥០ រាជការបារាំង ក៏បានផ្ទេរវិជ្ជាស្ថានពុទ្ធសាស-នបណ្ឌិត្យជូនមករាជការខ្មែរ ពេលនោះ សហ. យៀន-ចឹម ដែលធ្លាប់ធ្វើជាគ្រូឈួយ អគ្គលេខាធិការ ជាតិបារាំងជាច្រើននាក់មកហើយនោះ

ទទួលកាន់កាប់ជាអគ្គលេខាធិការបន្តការងារយ៉ាងម៉ឺងម៉ាត់ រហូតដល់ គ.ស. ១៩៦៥ ទើបលោកត្រូវដល់កំណត់អាយុចូលនិវត្តន៍ ។ ភារៈនេះ ក៏ធ្លាក់មកលើសហជីវិន ក៉យ-ប៊ុក បន្តមកទៀតបានមួយឆ្នាំ ក៏ដល់អាយុនិវត្តន៍ទៅទៀត ទើបភារៈនេះ ត្រូវធ្លាក់មកលើខ្ញុំករុណា-ខ្ញុំបាទ ទទួលបន្តកិច្ចការដ៏ប្រសើរជាដំណតតពីរៀមច្បងទាំងនោះមក ។

សម្ដេចជាអម្ចាស់ ឯកឧត្ដម ព្រះតេជព្រះគុណ សហជីវិន សហជីវិនីទាំងឡាយ ។

គោលបំណងនៃពិធីបុណ្យពេលនេះ គ្មានអ្វីក្រៅពីការបង់រំឭកថ្ងៃកំណើតនៃវិជ្ជាឋាននេះ ដោយលើកយកកិត្តិគុណ អស់លោកអ្នកប្រាជ្ញទាំងអស់ ដែលលោកបានជួយឧបត្ថម្ភវិជ្ជាឋាន ឲ្យមានដំណើរល្អណាស់ ជាមធ្យោបាយផ្សាយ ពង្រីកវប្បធម៌ជាតិ ឲ្យសាយភាយទូលាយក្នុងព្រះរាជាណាចក្រផង ជាហេតុនាំឲ្យយើងខ្ញុំព្រះករុណា ខ្ញុំបាទពុំអាចបំភ្លេចលោកបានឡើយ ។ ព្រះនាមនិងនាមនៃអស់លោកអ្នកប្រាជ្ញ និងជាអ្នកឧបត្ថម្ភនោះមាន :

ព្រះតេជព្រះគុណព្រះមហាវិមលធម្ម ថោង, សម្ដេចព្រះធម្មលិខិត ល្វី-ឯម, សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ ជួន-ណាត, សម្ដេចព្រះរាជអយ្យកោ វរចក្រណារិទ្ធិ នរោត្តម-សុត្ថារស, សម្ដេចព្រះពោធិវង្ស ហួត-តាត ដែលព្រះអង្គគង់ជាប្រធានក្នុងទីនេះ, ព្រះឧត្តមមុនី អ៊ុំ-ស៊ូ,

ព្រះមហាព្រហ្មមុនី ទេព - អ៊ុ, ព្រះមុនីកោសល សោម - ឈុន, ព្រះធម្មលិខិត ម៉ឹង - សែស, ព្រះវិកូញ្ញាណ សោម - ឡុប, ព្រះមុនីកោសល សួរ-ហាយ, ព្រះញាណកោសល ញាណ-ឈើន, ព្រះបិដកសោភ័ណ ប៉ែន - សុខ, ព្រះមហា ប៉ាង-ខាត់, ព្រះសិរីសម្មតិ-វង្ស ប៉ុណ្ណ-សម្ភាជ, លោក ជុំ-ម៉ៅ, ភិរម្យ-ង៉ុយ, លោក សោ-ភ័ណមន្ត្រី ជួន-នុត, លោកឧកញ៉ា ឈឹម-ក្រសេម, ព្រះសាសនមុនី កឹម-តូ, ព្រះធម្មឧត្តម ហ៊ី-ជា, លោក អ៊ុច-រស់, លោក អ៊ុក-ម៉ូត, លោកយឿន ចឹម, លោកក៉ាយ-ប៊ុក, លោក ទិន-ហួត, លោក ញ៉ុក-ថែម, លោក ចាប-ពិន, លោក យូរ-អ៊ុន, លោក ប៊ូ-ប៉ូ, លោក ឈឹម-ស៊ុម, ឯកឧត្តម ឃឹម-ទិត, លោក ផេង-ជ្រើ, លោក សុន-ហ៊ាន, លោក មាឃ-ស៊ុន, លោក ម៉ាង-នាង លោក សឹង-ផន, លោក ញួង-សៀង និងអស់លោកច្រើនទៀតដែលពុំបានកត់អស់ ព្រោះពេលវេលាខ្លីពេក ។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមបួងសួងឧទ្ទិសបុញ្ញរាសីដែលកើតឡើងក្នុងពិធីបុណ្យនេះ :

ជាបឋមថ្វាយជាព្រះរាជកុសលចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង សូមព្រះអង្គបានប្រកបនិងបរមសុខក្នុងសិរីរាជ-សម្បត្តិ មានព្រះជន្មាទីឃាជាងរយព្រះវស្សា និងសូមថ្វាយចំពោះសម្តេចឪព្រះប្រមុខរដ្ឋជាទីគោរពស្នេហាបំផុត សូមព្រះអង្គបានប្រកប

ទីដ៏ជោគជ័យគ្រប់ប្រការ កុំបីមានសត្រូវណា មកបៀតបៀនព្រះអង្គបានឡើយ ។

ជាបន្ទាប់មកសូមឧទ្ទិស ចំពោះព្រះវិញ្ញាណក្ខន្ធ នៃព្រះអតីតព្រះមហាក្សត្រទាំងឡាយ មានព្រះករុណាព្រះបាទសម្តេចព្រះអង្គ-ឌួង ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ព្រះបាទសម្តេចព្រះមុនីវង្ស ព្រះបាទសម្តេចព្រះសុរាម្រិត សូមព្រះអង្គទ្រង់អនុមោទនានិងសូមទ្រង់ប្រកបដោយព្រះបរមសុខកុំបីឃ្លៀងឃ្លាតឡើយ ។

មួយចំណែកទៀត សូមឧទ្ទិសផ្សាយកុសល ជូនដល់វិញ្ញាណ-ក្ខន្ធអស់លោក ដែលមានគុណលើមន្ទីរពុទ្ធសាសនបណ្ឌិត្យ ហើយដែលបែកស្លាប់ទៅហើយនោះ សូមឲ្យបានស្ថិតទៅក្នុងសុគតិភពជាភិយោភាព ។ ទីបំផុត សូមផ្សាយកុសលចំពោះសម្តេច ជូនឯក-ឧត្តម ព្រះតេជព្រះគុណ សហជីវិន សហជីវិនីទាំងអស់ សូមឲ្យបានសម្រេចសមបំណង ដូចចិត្តប៉ងប្រាថ្នាកុំបីឃ្លៀងឃ្លាតឡើយ ។

---

# ចុតហ្មាយនៃពុទ្ធសាសនបណ្ឌិត្យ

បន្ទាប់ពីពិធីបុណ្យរំឭកថ្ងៃកំណើតនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យមក សហជីវិននាយកនៃវិទ្យាស្ថាននេះ ក៏បានធ្វើជាចុតហ្មាយ ថ្វាយព្រះពរចំពោះ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង, សម្តេចសហជីវិនព្រះប្រមុខរដ្ឋ និង សម្តេចព្រះសង្ឃរាជ ដូចមានសេចក្តីចម្លង ចុះជូនទាំងស្រុង តទៅនេះ :

*សូមព្រះតេជៈតំកល់លើត្បូង*

*សូមព្រះរាជទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទ*

*នៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត*

*សូមទ្រង់ជ្រាប ។*

*ទូលព្រះបង្គំជាខ្ញុំ ព្រមទាំងបុគ្គលិក ព្រះសង្ឃ និង គ្រហស្ថ ជាសហការីទាំងអស់ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ ក្រោយដែលបាន ទទួលព្រះឱវាទ នៃសម្តេចព្រះពោធិវង្ស ហួត តាត អគ្គាធិការ នៃពុទ្ធិកសិក្សាកម្ពុជរដ្ឋ និងជាអធិបតី នៃក្រុមជំនុំព្រះត្រៃបិដក ហើយនិងដោយបានទទួលការណែនាំផ្ទាល់ ប្រកបដោយសេចក្តីអបអរសាទរនៃឯកឧត្តម អ៊ឹង ហ៊ុនសាង ទេសរដ្ឋមន្ត្រីក្រសួងធម្មការ និង ព្រះតេជព្រះគុណ អ៊ុក - ម៉ូត អនុរដ្ឋលេខាធិការក្រសួងធម្មការ បាន រួបរួមគ្នា ប្រារព្ធធ្វើពិធីបុណ្យរាប់បាត្រ ព្រះសង្ឃរាជាគណៈ ឋានានុក្រម រួមទាំងពីរគណៈចំនួន ៣៧ អង្គ ក្រោមព្រះអធិបតីភាព នៃសម្តេចព្រះ*

ពោធិវង្ស កាលពីព្រឹកថ្ងៃសុក្រ ទី ១៤ ខុសភា ១៩៦៧ នៅនា បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ។ ពិធីបុណ្យនេះ មានគោលបំណងសំខាន់ដូចតទៅ គឺ :

- រំលឹកដល់ខួបទី ៣៧ នៃឆ្នាំកំណើតវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលបានកើតឡើងពីខែមករា គ.ស. ១៩៣០ ដោយស្នាព្រះហស្ដដ៏ខ្ពង់ ខ្ពស់បំផុតនៃព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ-មុនីវង្ស ហើយដែល ទ្រង់បានសព្វព្រះរាជហឫទ័យបើកពិធីសម្ពោធជាផ្លូវការ យ៉ាងឧឡារិកនៅ ថ្ងៃទី ១២ ឧសភា ១៩៣០ ។

- ថ្វាយព្រះរាជកុសល ចំពោះព្រះវិញ្ញាណក្ខន្ធ នៃព្រះអតីតមហា ក្សត្រគ្រប់ព្រះអង្គ ដែលទ្រង់មានព្រះមហាករុណាធិគុណដ៏ធំធេង ចំពោះ ប្រទេសជាតិ ក្នុងវិស័យវប្បធម៌-អក្សរសាស្ត្រ ព្រមទាំងទ្រង់មានព្រះ គុណបំណាច់ឧបត្ថម្ភផ្ចាល់ព្រះអង្គ នូវមជ្ឈមណ្ឌលព្រះពុទ្ធសាសនា និង វប្បធម៌ជាតិ គឺមានព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ព្រះបាទ សម្ដេចព្រះស៊ីសុវត្ថិ-មុនីវង្ស ព្រះបាទសម្ដេចព្រះនរោត្តម-សុរាម្រិត និង សម្ដេចក្រុមព្រះវរចក្រណារិទ្ធ នរោត្តម-សុធារស ជាដើម ។

-ថ្វាយព្រះរាជកុសល ចំពោះសម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ ជីវិតលើត្បូង ដែលទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភ និងជាព្រះមាតា នៃវប្បធម៌ សិល្បៈ និងអារ្យធម៌ជាតិ ព្រមទាំងចំពោះសម្ដេចព្រះឧបយុវ-រាជ ព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ ។

- ថ្វាយព្រះរាជកុសល : ជូនកុសល ចំពោះគរុ អ្នកប្រាជ្ញ រាជបណ្ឌិត្យ ទាំងបព្វជិត ទាំងគ្រហស្ថ ទោះធ្វើមរណកាលទៅហើយ ឬ មានជន្មាយុនៅឡើយ ដែលបានខិតខំបំរើវិស័យព្រះពុទ្ធសាសនា វប្បធម៌ និងអក្សរសាស្ត្រជាតិ មានសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ និងសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ ជាប្រធាន ។

សូមទ្រង់ព្រះមេត្តាប្រោស

ពិធីបុណ្យនេះ ទូលព្រះបង្គំជាខ្ញុំទាំងឡាយ បានសម្រេចកំណត់ទុកជាប្រពៃណីរបស់វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលនឹងត្រូវធ្វើរៀងរាល់ឆ្នាំតទៅ នៅថ្ងៃទី ១២ ឧសភា នៃសុរិយគតិដើម្បីជាសក្ខីភាពនៃកតញ្ញុតា ចំពោះព្រះមហាករុណាធិគុណរបស់ព្រះមហាក្សត្រ និង បុព្វបុរស ដែលមានសគុណចំពោះជាតិ សាសនា ព្រះរាជបល្ល័ង្ក ព្រមទាំងជាសញ្ញានៃសាមគ្គីភាព របស់បុគ្គលិកក្នុងក្រសួង ។

ទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមលំឱនកាយក្រាបបង្គំថ្វាយ នូវបុញ្ញរាសីដ៏ឧត្តម ដែលកើតអំពីពិធីបុណ្យរាប់បាត្រព្រះសង្ឃពេលនេះ ចំពោះសម្តេចជាអម្ចាស់ជីវិតលើត្បូង សូមព្រះអង្គទ្រង់គង់នៅក្នុងព្រះបរមសុខសួស្តី ជោគជ័យមង្គល មហាប្រសើរ មានជន្មាទីឃាយុជាងរយព្រះវស្សា មានព្រះសុខភាពបរិបូណ៌ ដើម្បីទ្រង់គង់នៅជាមហាម្លប់ជី

ត្រជាក់ត្រជុំពំនាក់និងជ្រករកាន នៃបណ្ដាកូនចៅព្រះអង្គ អស់កាលជាអង្វែងគ្រប់ ៗ កាលជានិរន្ដរ៍ ។

គួរពុំគួរសូមទ្រង់ព្រះមេត្ដាប្រោស

សូមព្រះរាជតានក្រោមបង្គំទូលថ្វាយ នៅថ្ងៃទី ១៣ ធ្នូ ១៩៦៧

ទូលព្រះបង្គំជាខ្ញុំ លាង-ហ៉ាបអាន

នាយកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

---

២— បុគ្គលិកថ្វាយសម្ដេចសហជីវិន. –

សូមក្រាបបង្គំទូល

សម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

ទូលព្រះបង្គំ ព្រមទាំងបុគ្គលិក ព្រះសង្ឃនិងគ្រហស្ថ ជាសហការីទាំងអស់ នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ ក្រោយដែលបានទទួលព្រះរាជទានទៃសម្ដេចព្រះពោធិវង្ស ហួត តាត អគ្គាធិការនៃពុទ្ធិកសិក្សាកម្ពុជ និងជាអធិបតីនៃក្រុមជំនុំព្រះត្រៃបិដក និងក្រោយដែលបានទទួលការណែនាំផ្ទាល់ ដោយសេចក្ដីអបអរសាទរនៃឯកឧត្ដមអ៊ុង-ហុងសាង ទេសរដ្ឋមន្ត្រីក្រសួងធម្មការ និងព្រះតេជព្រះគុណអ៊ុក-ម៉ូត អនុរដ្ឋលេខាធិការក្រសួងធម្មការ បានរួបរួមគ្នាប្រារព្ធ

ធ្វើពិធីបុណ្យរាប់បាត្រព្រះសង្ឃរាជាគណៈ បានទុក្រម រួមទាំងពីរគណៈ ចំនួន ៣៧ អង្គ ក្រោយព្រះអធិបតីភាពនៃសម្តេចព្រះពោធិវង្ស កាលពីព្រឹកថ្ងៃ សុក្រទី ១២ ឧសភា ១៩៦៧ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ។ ពិធីបុណ្យនេះ មានគោលបំណងសំខាន់ ដូចតទៅ គឺ :

– រំលឹកខួបទី ៣៧ នៃឆ្នាំកំណើតវិជ្ជាបានពុទ្ធសាសនបណ្ឌិត្យ ដែលបានកើតឡើងពីខែ មករា ១៩៣០ ដោយស្នាព្រះហស្តដ៏ខ្ពង់ខ្ពស់បំផុត នៃព្រះករុណាព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ មុនីវង្ស ហើយដែលទ្រង់សព្វព្រះរាជហឫទ័យ បើកពិធីសម្ពោធជាផ្លូវការយ៉ាងឱឡារិកនៅថ្ងៃទី ១២ ឧសភា ១៩៣០ ។

– ថ្វាយព្រះរាជកុសល ចំពោះព្រះអតីតមហាក្សត្រគ្រប់ព្រះអង្គ ដែលទ្រង់មានព្រះមហាករុណាធិគុណ ចំពោះប្រទេសជាតិ ក្នុងវិស័យវប្បធម៌–អក្សរសាស្ត្រ ព្រមទាំងទ្រង់មានព្រះគុណចំណាច់ឧបត្ថម្ភផ្ទាល់ព្រះអង្គនូវមជ្ឈមណ្ឌលព្រះពុទ្ធសាសនា និង វប្បធម៌ជាតិ គឺមានព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ-មុនីវង្ស ព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត និងសម្តេចព្រះរាជអយ្យកោ វរចក្រណារិទ្ធិ នរោត្តម-សុធារស ជាដើម ។

– ថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះមហាក្សត្រិយានី ជា

អម្ចាស់ជីវិតលើត្បូង ដែលទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ និងជាព្រះមាតានៃវប្បធម៌ សិល្បៈ និងអារ្យធម៌ជាតិ ព្រមទាំងចំពោះសម្ដេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ ។

–ថ្វាយព្រះរាជកុសល - ជូនកុសលចំពោះគរុ អ្នកប្រាជ្ញ រាជបណ្ឌិតជាបព្វជិត និងគ្រហស្ថ ទោះទទួលមរណភាពទៅហើយក្តី ឬ មានជន្មាយុនៅឡើយក្តី ដែលបានខិតខំបំរើវិស័យព្រះពុទ្ធសាសនា វប្បធម៌ និងអក្សរសាស្ត្រជាតិ មានសម្ដេចព្រះសង្ឃរាជជាគម្ពី ១ គណៈមហានិកាយ និង សម្ដេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ ជាប្រធាន ។

សូមទ្រង់ព្រះមេត្តាប្រោស

ពិធីបុណ្យនេះ ទូលបង្គំទាំងឡាយ បានសម្រេចកំណត់ទុកជាបុណ្យប្រពៃណីរបស់វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលនឹងត្រូវធ្វើនៅថ្ងៃទី ១២ ខែសីហា រៀងរាល់ឆ្នាំតទៅ ដើម្បីជាសក្ខីភាពនៃកតញ្ញូតាធម៌ ចំពោះព្រះមហាករុណាធិគុណរបស់ព្រះមហាក្សត្រ និងបុព្វបុរសដែលមានសគុណចំពោះជាតិ – សាសនា – ព្រះរាជបល្ល័ង្ក ព្រមទាំងជាសញ្ញានៃសាមគ្គីភាពរបស់បុគ្គលិកក្នុងក្រសួង ។

ទូលព្រះបង្គំទាំងឡាយ សូមលំអុតលំឱនក្រាបបង្គំថ្វាយ នូវបុញ្ញាភិសង្ខត្តម ដែលកើតអំពីពិធីបុណ្យរាប់បាត្រព្រះសង្ឃពេលនេះ ចំពោះសម្ដេចសហជីវិនជាអម្ចាស់ សូមព្រះអង្គគង់នៅក្នុងព្រះបរមសុខសួស្តី

ជោគជ័យមង្គល មហាប្រសើរ មានព្រះជន្មាទីឃាយុជាងរយព្រះវស្សា មានព្រះសុខភាពបរិបូណ៌ ដើម្បីទ្រង់គង់នៅជាម្លប់ដ៏ត្រជាក់ត្រជុំ ជាទីពំ-នឹងពំនាក់ជ្រកកោន នៃកូនចៅព្រះអង្គគ្រប់ៗកាល ជានិរន្តរ៍តទៅ ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

សូមក្រាបបង្គំទូលថ្វាយ នៅភ្នំពេញ ថ្ងៃទី ១៣ ឧសភា ១៩៦៧

ទូលព្រះបង្គំ លាង-ហាប់អាន

នាយកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

---

៣– ចុតហ្មាយថ្វាយសម្តេចព្រះសង្ឃរាជ –

សូមព្រះតេជៈគុណលើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទ

នៃសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ

សូមទ្រង់ជ្រាប ។

ទូលព្រះបង្គំជាខ្ញុំ ព្រមទាំងបុគ្គលិក ព្រះសង្ឃ និង គ្រហស្ថ ជាសហការីទាំងអស់នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ក្រោយដែលបានទទួលព្រះឱវាទនៃសម្តេចព្រះពោធិវង្ស និងក្រោយដែលបានទទួលការណែនាំផ្ទាល់របស់ព្រះតេជៈព្រះគុណ អ៊ុំ-ស៊ូម អនុប្រធានលេខាធិការ ក្រសួងធម្មការ បានប្រារព្ធធ្វើពិធីបុណ្យខួប ទី ៣៧ រំលឹកដល់ឆ្នាំកំណើតនៃ

ពុទ្ធសាសនបណ្ឌិត្យ ដែលបានកើតឡើងក្នុងឆ្នាំ ១៩៣០ កាលពីព្រឹកថ្ងៃ សុក្រ ទី ១២ ឧសភា ១៩៦៧ នៅបណ្ណាល័យនៃវិជ្ជាឋាននេះក្រោមអធិបតីភាពនៃសម្តេចព្រះពោធិវង្ស ព្រមទាំងរំលឹកដល់គុណូបការនៃករី អ្នកប្រាជ្ញ រាជបណ្ឌិតទាំងឡាយ ដែលបានខិតខំយកព្រះទ័យ-ចិត្តទុកដាក់ពុះពារឧបសគ្គគ្រប់បែបគ្រប់យ៉ាង ក្នុងវិស័យពុទ្ធសាសនានិង អក្សរសាស្ត្រជាតិ ដោយបានទុកកេរ្តិ៍មរតកគឺស្នាព្រះហស្ត ស្នាដៃជាសៀវភៅធម៌អាថ៌ ជាសៀវភៅវេយ្យាករណ៍ ជាក្បួនខ្នាតសំខាន់ ៗ ដ៏ច្រើនមហិមា សម្រាប់កូនចៅជាន់ក្រោយ ពិសេសគឺសម្តេចជាម្ចាស់និងសម្តេចព្រះពោធិវង្ស ដែលជាអាទិកម្មិកបុគ្គលនៃព្រះរាជបណ្ណាល័យនិង ពុទ្ធសាសនបណ្ឌិត្យ នេះឯង ។

ក្នុងពិធីដ៏តូចនេះ មានការរាប់បាត្រព្រះសង្ឃចំនួន ៣៧ អង្គដោយគម្រប់នឹងអាយុកាលនៃពុទ្ធសាសនបណ្ឌិត្យ ដើម្បីសំដែងនូវកត-ញ្ញុតា និង គារវភាព ឧទ្ទិសកុសលថ្វាយ-ជូន ចំពោះករី អ្នកប្រាជ្ញរាជបណ្ឌិត ជាបុព្វបុរសទាំងឡាយនោះផង ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំទាំងឡាយ បានសម្រេចកំណត់យកពិធីបុណ្យខួបនេះ ទុកជាបុណ្យប្រពៃណីរបស់វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលតទៅមុខនឹងត្រូវធ្វើនៅថ្ងៃទី ១២ ឧសភា រៀងរាល់ឆ្នាំ ដើម្បីគម្រប់នឹង

ថ្ងៃបុណ្យសម្ពោធនៃវិជ្ជាឋាននេះ ដែលបានធ្វើកាលពីថ្ងៃទី ១២ ឧសភា ១៩៣០ ។

ទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមព្រះរាជទានក្រាបបង្គំក្រោមល្អងធូលីព្រះបាទ ថ្វាយនូវភាគផលកុសលកសិដ៏ឧត្តម ដែលកើតអំពីបុណ្យរាប់បាត្រព្រះសង្ឃនោះបំពោះសម្តេចជាអម្ចាស់ សូមព្រះអង្គទ្រង់គង់នៅគង់ព្រះបរមសុខ មានព្រះសុខភាពបរិបូណ៌ មានព្រះជន្មាយុយឺនយូរជាពីរយព្រះវស្សា ដើម្បីទ្រង់គង់ជាម្លប់ត្រជាក់ត្រជុំ ជាទីជ្រកកោននៃពុទ្ធបរិស័ទទាំងឡាយអស់កាលជាអង្វែងតទៅ ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះរាជទានក្រាបបង្គំទូលថ្វាយ នៅភ្នំពេញថ្ងៃទី ១៣ ឧសភា ១៩៦៧

ទូលព្រះបង្គំជាខ្ញុំ ឈាង-ហ៊ាបអាន

នាយកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ